

Australian Aid | ASEAN-Australia Counter Trafficking

# តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ

## សៀវភៅណែនាំសម្រាប់រដ្ឋសមាជិកអាស៊ាន

**ខែមិថុនា ឆ្នាំ២០២២**

**អ្នកនិពន្ធ៖ លីស្សា លីស្ទ័រ** (Leisha Lister) **ទីប្រឹក្សាជាន់ខ្ពស់នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស** (ASEAN-ACT)

កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងត្រូវបានអនុវត្តដោយក្រុមហ៊ុនខាដណូអភិវឌ្ឍន៍អន្តរជាតិ (Cardno International Development) ដែលគឺជាក្រុមហ៊ុន DT Global Company មួយ។ ឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនៈដែលបានសម្តែងនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនមែនគឺជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីទេ។



Australian Aid | ASEAN-Australia Counter Trafficking

# តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ

## សៀវភៅណែនាំសម្រាប់រដ្ឋសមាជិកអាស៊ាន

# មាតិកា




ទស្សនៈរួម ............................................................ ៦

បទបញ្ញត្តិនៃអនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (អនុសញ្ញា ACTIP) ............................ ៧

គោលការណ៍សំខាន់ៗ............................................ ១២

សូចនាករទាំង ៨ នៃតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ ......... ១៣

ឧបសម្ព័ន្ធ ១៖ សូចនាករនៃតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ ឧបករណ៍ស្វ័យវាយតម្លៃ ........................................ ៥០

សូចនាករទី ១ ................................ ១៤
- ទស្សនៈរួម ................................ ១៤
- គោលការណ៍ ................................ ១៤
- ឧទាហរណ៍ ................................ ១៤

សូចនាករទី ២ ................................ ១៧
- ទស្សនៈរួម ................................ ១៧
- គោលការណ៍ ................................ ១៧
- ឧទាហរណ៍ ................................ ១៨

សូចនាករទី ៣ ................................ ២២
- ទស្សនៈរួម ................................ ២២
- គោលការណ៍ ................................ ២២
- ឧទាហរណ៍ ................................ ២៣

សូចនាករទី ៤ ................................ ២៦
- ទស្សនៈរួម ................................ ២៦
- គោលការណ៍ ................................ ២៧
- ឧទាហរណ៍ ................................ ២៧

សូចនាករទី ៥ ................................ ៣៣
- ទស្សនៈរួម ................................ ៣៣
- គោលការណ៍ ................................ ៣៤
- ឧទាហរណ៍ ................................ ៣៤

សូចនាករទី ៦ ................................ ៣៦
- ទស្សនៈរួម ................................ ៣៦
- គោលការណ៍ ................................ ៣៦
- ឧទាហរណ៍ ................................ ៣៧

សូចនាករទី ៧ ................................ ៣៨
- ទស្សនៈរួម ................................ ៣៨
- គោលការណ៍ ................................ ៣៩
- ឧទាហរណ៍ ................................ ៤០

សូចនាករទី ៨ ................................ ៤៥
- ទស្សនៈរួម ................................ ៤៥
- គោលការណ៍ ................................ ៤៦
- ឧទាហរណ៍ ................................ ៤៧

# ទស្សនៈរួម

> “ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលយកចិត្តទុកដាក់លើជនរងគ្រោះ តម្រូវឱ្យចៅក្រមកំណត់ថា ជនរងគ្រោះគឺជាចំណុចយ៉ាងសំខាន់សម្រាប់ការពិចារណា នៅពេលអនុវត្តកិច្ចការងាររបស់ពួកគេ ដោយសង្កត់ធ្ងន់លើការអនុវត្តនានា ដែលដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះកិច្ចការពារជនរងគ្រោះពីការទទួលគ្រោះថ្នាក់បន្ថែមទៀត។ សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះមិនត្រឹមតែជាគោលបំណងតែមួយគត់សំរាប់តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះប៉ុណ្ណោះឡើយ ប៉ុន្តែការកំណត់សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះជាស្នូលនៃអន្តរាគមន៍យុត្តិធម៌ព្រហ្មទណ្ឌដែលទំនងជាអាចបង្កើន ការសហការពីជនរងគ្រោះជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។[១]”

## គោលបំណងនៃអភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ

- ការពារ និងពង្រឹងសិទ្ធិរបស់ជនរងគ្រោះ និងសាក្សីនៅក្នុងសេចក្តីសម្រេចនៃសំណុំរឿងព្រហ្មទណ្ឌ។
- កាត់បន្ថយលទ្ធភាពនៃភាពរងគ្រោះឡើងវិញដែលបង្កឡើងដោយវិស័យយុត្តិធម៌ព្រហ្មទណ្ឌ។
- ជួយវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស តុលាការ ឱ្យយល់ និងដឹងអំពី តួនាទីរបស់ជនរងគ្រោះ និង សាក្សី និង តម្រូវការរបស់ពួកគេ នៅក្នុងអំឡុងពេលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ធ្វើជាមគ្គុទ្ទេសក៍ចំពោះវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស តុលាការ នៅក្នុងការអនុវត្តអភិក្រមដែលយកចិត្តទុកដាក់លើជនរងគ្រោះ ក្នុងការដោះស្រាយករណីជួញដូរមនុស្សក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

## អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ និងការអនុវត្តល្អៗជាអន្តរជាតិ

> “សិទ្ធិមនុស្សរបស់ជនត្រូវបានជួញដូរ ត្រូវជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងទាំងអស់ក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស... វិធានការប្រឆាំងអំពើជួញដូរមនុស្សមិនត្រូវជះឥទ្ធិពលអវិជ្ជមានទៅលើសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ ជាពិសេស សិទ្ធិរបស់ជនទាំងឡាយ ដែលត្រូវបានជួញដូរ និងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ ជនត្រូវបានជម្លៀសក្នុងប្រទេស ជនភៀសខ្លួន និងជនស្វែងរកសិទ្ធិជ្រកកោន។[២]”

នៅក្នុងករណីជួញដូរមនុស្ស ជនរងគ្រោះរមែងតែងជាប្រភពតែមួយគត់នៃភ័ស្តុតាង ហេតុនេះវាមានការលំបាកក្នុងការផ្តន្ទាទោសជនល្មើស។ ការមានអភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះមានន័យថា ជាការកំណត់ជនរងគ្រោះជាចំណុចសំខាន់ ឬជាអាទិភាព សម្រាប់កិច្ចការគ្រប់យ៉ាងដែលត្រូវធ្វើ។ អភិក្រមនេះអាចរួមមានការផ្តល់ព័ត៌មានដល់

---

១ UNODC, "Blueprint for Action: An Implementation Plan for Criminal Justice Systems to Prevent and Respond to Violence against Women", in UNODC, Strengthening Crime Prevention and Criminal Justice Responses to Violence against Women (2014), available at https://www.unodc.org/documents/justice-and-prison-reform/Strengthening_Crime_Prevention_and_Criminal_Justice_Responses_to_Violence_against_Women.pdf.

២ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស ឆ្នាំ២០០២

ជនរងគ្រោះ ដើម្បីឱ្យពួកគេអាចធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់អំពីការចូលរួមនៅក្នុងដំណើរការនេះ ការពន្យល់អំពីសិទ្ធិ និងផលប្រយោជន៍របស់ពួកគេ ដើម្បីធានានូវការបំពេញតម្រូវការមូលដ្ឋានរបស់ពួកគេ និងដើម្បីធ្វើឱ្យប្រាកដថាំពោះការរក្សាការសម្ងាត់ និងឯកជនភាពរបស់ជនរងគ្រោះយ៉ាងម៉ឺងម៉ាត់។ ប្រសិនបើស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអាចអនុវត្តអភិក្រមដែលយកចិត្តទុកដាក់លើជនរងគ្រោះនៅក្នុងការងាររបស់ពួកគេបាន នោះពួកគេនឹងអាចការពារសិទ្ធិរបស់ជនរងគ្រោះ និងធានានូវកិច្ចការពារសេចក្តីថ្លៃថ្នូរ ឯកជនភាព និងសុវត្ថិភាពរបស់ពួកគេបាន។

## អនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (អនុសញ្ញា ACTIP)

អនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (អនុសញ្ញា ACTIP) ត្រូវបានរៀបចំឡើងដើម្បីទទួលស្គាល់នូវបញ្ហារីកធំឡើងនៃអំពើជួញដូរមនុស្សនៅក្នុងរដ្ឋសមាជិកអាស៊ាន និងពាក់ព័ន្ធនឹងរដ្ឋសមាជិកអាស៊ាន។

ដោយត្រូវបានចុះហត្ថលេខាដោយប្រជាជាតិអាស៊ានទាំងដប់នៅខែវិច្ឆិកា ឆ្នាំ២០១៥ ACTIP កំណត់នូវកាតព្វកិច្ចផ្លូវច្បាប់ក្នុងការជួយរដ្ឋសមាជិកអាស៊ាន ដើម្បីដោះស្រាយជាមួយនឹងបញ្ហាប្រឈម អាទិភាព និងយុទ្ធសាស្ត្រជាតិផ្សេងៗពីគ្នានៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ មាត្រា ១ ចែងអំពីគោលបំណងស្នូលនៃ ACTIP និងទទួលស្គាល់នូវសេចក្តីត្រូវការ ការពង្រឹងកិច្ចការពារ និងជំនួយសម្រាប់ជនរងគ្រោះនៃអំពើជួញដូមនុស្ស ជាពិសេស ស្ត្រី និងកុមារ។

សូចនាករទាំង ៨ ដែលយកចិត្តទុកដាក់លើជនរងគ្រោះនៅក្នុងសៀវភៅណែនាំនេះកើតចេញមកពីកាតព្វកិច្ចនានានៅក្នុងអនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ។

# បទបញ្ញត្តិនៃអនុសញ្ញា ACTIP

*មាត្រា ១ (គោលបំណង)* - ចែងអំពី គោលបំណងស្នូលនៃអនុសញ្ញា ACTIP និងទទួលស្គាល់សេចក្តីត្រូវការពង្រឹងកិច្ចការពារ និងជំនួយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ។

- មាត្រា ១៦ - ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងការផ្តន្ទាទោស ព្រមទាំងសំដៅទៅដល់សេចក្តីត្រូវការការធានាថា អាជ្ញាធរទាំងអស់ដែលដោះស្រាយករណីជួញដូរមនុស្សទទួលបានការបំពាក់បំប៉នជាមួយនឹងចំណេះដឹង និងជំនាញសមស្រប ដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយពួកគេដោះស្រាយករណីជួញដូរមនុស្សប្រកបដោយប្រសិទ្ធផល និងរក្សាឯកជនភាពរបស់ជនរងគ្រោះ។

# ការទប់ស្កាត់អំពើជួញដូរមនុស្ស

*មាត្រា ១១ (ការទប់ស្កាត់អំពើជួញដូរមនុស្ស)* - ដោះស្រាយលើការទប់ស្កាត់អំពើជួញដូរមនុស្ស និងតម្រូវឱ្យរដ្ឋសមាជិកអនុវត្តវិធានការនានា ដើម្បីការពារជនរងគ្រោះពីភាពរងគ្រោះជាថ្មីម្តងទៀត និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងពង្រឹងវិធានការច្បាប់ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស។

មាត្រា ១១ នៃអនុសញ្ញា ACTIP តម្រូវឱ្យសមាជិកអាស៊ាន៖

- បង្កើតគោលនយោបាយ កម្មវិធីគ្រប់ជ្រុងជ្រោយ និងមានវិធានការពាក់ព័ន្ធ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះ (ជាពិសេស ស្ត្រី និងកុមារ) ពីភាពរងគ្រោះជាថ្មីម្តងទៀត។
- ធ្វើការស្រាវជ្រាវ និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងកត្តាហានិភ័យនៃអំពើជួញដូរ ដូចជាភាពក្រីក្រ និង
- ពង្រឹងវិធានការច្បាប់ និងការអប់រំ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

*មាត្រា ១២ (ផ្នែកកិច្ចសហការ)*

មាត្រានេះនៃអនុសញ្ញា ACTIP មិនដាក់កាតព្វកិច្ចវិជ្ជមានលើសមាជិកអាស៊ានឡើយ និងបង្ហាញឱ្យឃើញថា បទបញ្ញត្តិពាក់ព័ន្ធត្រូវបានអនុវត្ត "ដោយអនុលោមជាមួយនឹងច្បាប់ជាតិ"។ មាត្រានេះកំណត់នូវវិស័យនៃកិច្ចសហការដែលអាចមាន ឧទាហរណ៍៖

១. ការអនុវត្តវិធានការនានា ដើម្បីបញ្ឈប់សេចក្តីត្រូវការការផ្គត់ផ្គង់សម្រាប់ឧស្សាហកម្មជួញដូរមនុស្ស

២. ការអនុវត្តវិធានការនានា ដើម្បីពង្រឹងកិច្ចសហការថ្នាក់តំបន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេត និងផ្តន្ទាទោស និង

៣. ការកសាងសមត្ថភាពទូទៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

*មាត្រា ១៣ (កិច្ចសហការឆ្លងដែន ការត្រួតពិនិត្យ និងសុពលភាពនៃឯកសារ)*

មាត្រា ១៣ នៃអនុសញ្ញា ACTIP តម្រូវឱ្យសមាជិកអាស៊ាន៖

៤. ខិតខំប្រឹងប្រែងធ្វើកិច្ចសហការឆ្លងដែន និងកិច្ចការដទៃទៀត តាមរយៈការបង្កើតបណ្តាញទំនាក់ទំនង និងការផ្លាស់ប្តូរព័ត៌មានចារកម្ម និង

៥. អនុវត្តការត្រួតពិនិត្យព្រំដែនប្រកបដោយប្រសិទ្ធភាព ការត្រួតពិនិត្យនានាពាក់ព័ន្ធនឹងការចេញឯកសារអត្តសញ្ញាណ និងឯកសារធ្វើដំណើរ និងមានវិធានការដើម្បីទប់ស្កាត់ការក្លែង ការកែប្រែ ឬការប្រើប្រាស់ដោយក្លែងបន្លំនូវឯកសារអត្តសញ្ញាណ ឬឯកសារធ្វើដំណើរ។

# កិច្ចការពារជនរងគ្រោះ

***មាត្រា ១៤ (កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស)*** - មានលក្ខណៈជាក់លាក់ចំពោះកិច្ចការពារជនរងគ្រោះពាក់ព័ន្ធនឹងសុវត្ថិភាពផ្លូវកាយរបស់ពួកគេ ដោយការពារអត្តសញ្ញាណរបស់ពួកគេ ធានានូវការផ្តល់តម្រូវការជាក់លាក់របស់ជនរងគ្រោះ ដូចជា កុមារ និងជនមានពិការភាព។ មាត្រា ១៤ ក៏តម្រូវឱ្យរដ្ឋសមាជិកធានាថា មានវិធានការនានា ដើម្បីឱ្យជនរងគ្រោះទទួលបានសំណងចំពោះការខូចខាត។

មាត្រា ១៤ នៃអនុសញ្ញា ACTIP តម្រូវឱ្យសមាជិកអាស៊ានបង្កើតគោលការណ៍ណែនាំ ឬនីតិវិធីជាតិ សម្រាប់ការកំណត់អត្តសញ្ញាណយ៉ាងសមស្របចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយនៅពេលដែលអំពើជួញដូរមនុស្សកើតឡើងនៅក្នុងប្រទេសលើសពីមួយ សមាជិកអាស៊ានគប្បីគោរព និងទទួលស្គាល់ការកំណត់អត្តសញ្ញាណរបស់ជនម្នាក់ ដែលធ្វើឡើងដោយសមាជិកអាស៊ានមួយទៀត។ បន្ថែមលើនេះ មាត្រានេះមានបំណងការពារជនរងគ្រោះ តាមរយៈការផ្តល់អនុសាសន៍ថា សមាជិកអាស៊ានគប្បីៈ

i. ពិចារណាលើវិធានការនានា ដើម្បីជួយឱ្យជនរងគ្រោះបន្តស្ថិតនៅក្នុងដែនដីរបស់ខ្លួនជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ និងធានានូវការគោរពសុវត្ថិភាពផ្លូវកាយរបស់ជនរងគ្រោះ

ii. ធានានូវឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរក្សាការសម្ងាត់ចំពោះដំណើរការផ្លូវច្បាប់ពាក់ព័ន្ធនឹងជនរងគ្រោះនោះ

iii. មិនធ្វើឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះសកម្មភាពខុសច្បាប់ ដែលពួកគេបានប្រព្រឹត្ត ដោយសារស្ថានភាពនៃការជួញដូររបស់ពួកគេឡើយ

iv. មិនឃុំខ្លួនជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយមិនសមហេតុផលនៅក្នុងកន្លែងឃុំឃាំង ឬនៅក្នុងពន្ធនាគារឡើយ និង

v. ផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនូវការថែទាំ និងការគាំទ្រ និងជួយដល់សមាហរណកម្មរបស់ពួកគេ។

***មាត្រា ១៥ (មាតុភូមិនិវត្តន៍ និងការវិលត្រលប់របស់ជនរងគ្រោះ)***

មាត្រា ១៥ នៃអនុសញ្ញា ACTIP តម្រូវឱ្យសមាជិកអាស៊ានៈ

vi. បញ្ជាក់ថា តើជនរងគ្រោះម្នាក់ គឺជាពលរដ្ឋ ឬជាអ្នករស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសរបស់ខ្លួន ដោយឥតពន្យារពេល

vii. សម្របសម្រួល និងទទួលយកជនរងគ្រោះ ដែលជាពលរដ្ឋ ឬអ្នកមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសរបស់ខ្លួន ដោយឥតពន្យារពេល និងដោយយកចិត្តទុកដាក់ចំពោះសុវត្ថិភាពរបស់ពួកគេ

viii. នៅពេលដែលជនរងគ្រោះគ្មានឯកសារសមស្រប ផ្តល់ដល់ជនរងគ្រោះនូវឯកសារធ្វើដំណើរចាំបាច់ និងការអនុញ្ញាត ដើម្បីឱ្យពួកគេអាចចូលមកកាន់ដែនដីរបស់ខ្លួនសារជាថ្មី និង

ix. អនុម័តច្បាប់ ឬវិធានការដទៃទៀត ទៅតាមភាពចាំបាច់ ដើម្បីបង្កើតកម្មវិធីមាតុភូមិនិវត្តន៍។

## ការអនុវត្ត

***មាត្រា ១៦ (ការអនុវត្តច្បាប់ និងការផ្តន្ទាទោស)***

មាត្រា ១៦ នៃអនុសញ្ញា ACTIP តម្រូវឱ្យសមាជិកអាស៊ាន៖

i. អនុម័តវិធានការនានា ដែលចាំបាច់ ដើម្បីបំពាក់ដល់អាជ្ញាធរ និងប្រព័ន្ធច្បាប់របស់ខ្លួននូវធនធានគ្រប់គ្រាន់ក្នុងការឆ្លើយតបនឹងអំពើជួញដូរមនុស្ស

ii. ចាត់វិធានការ ដើម្បីរកឃើញ រារាំង និងដាក់ទណ្ឌកម្មចំពោះការចូលរួមរបស់បុគ្គលនានានៅក្នុងអំពើជួញដូរមនុស្ស

iii. ចាត់គ្រប់វិធានការចាំបាច់ទាំងអស់ ដើម្បីការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសាក្សីដែលពាក់ព័ន្ធជាមួយនឹងអំពើជួញដូរមនុស្ស

iv. សហការជាមួយគ្នាទៅវិញទៅមក ដើម្បីលើកទឹកចិត្តជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យចូលមកដោយស្ម័គ្រចិត្ត និងស្នាក់នៅជាបណ្តោះអាសន្ននៅក្នុងដែនដីពាក់ព័ន្ធ សម្រាប់គោលបំណងនៃការផ្តន្ទាទោសជនជួញដូរមនុស្ស និង

v. បង្កើតរយៈពេលអាជ្ញាយុកាលដែលមានរយៈពេលវែងនៅក្រោមច្បាប់ជាតិរបស់ខ្លួនពាក់ព័ន្ធនឹងដំណើរការសម្រាប់បទល្មើសនានានៅក្រោមអនុសញ្ញា ACTIP ។

***មាត្រា ១៧ (ការដកហូត និងការរឹបអូស)***

មាត្រា ១៧ នៃអនុសញ្ញា ACTIP តម្រូវឱ្យសមាជិកអាស៊ាន៖

i. អនុម័តវិធានការនានា ដែលចាំបាច់ ដើម្បីជួយដល់ការកំណត់អត្តសញ្ញាណ ការស្វែងរក ការបង្កក និង/ឬការដកហូតប្រាក់ចំណេញ ដែលទទួលបានមកពីបទល្មើសនៅក្រោមអនុសញ្ញា ACTIP ឬទ្រព្យសម្បត្តិដែលទទួលបានមកពីបទល្មើសនៅក្រោមអនុសញ្ញា ACTIP និង

ii. ផ្តល់ភាពអង់អាចដល់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ខ្លួន ក្នុងការបញ្ជាឱ្យមានការផ្តល់កំណត់ត្រាធនាគារ កំណត់ត្រាហិរញ្ញវត្ថុ ឬពាណិជ្ជកម្ម រួមទាំងការកំណត់ថា ការបដិសេធចំពោះការផ្តល់កំណត់ត្រាបែបនេះដោយឈរលើភាពសម្ងាត់របស់ធនាគារ មិនគប្បីទទួលបានការអនុញ្ញាតឡើយ។

***មាត្រា ១៩ (បត្យាប័ន)***

នៅក្រោមមាត្រា ១៩ នៃអនុសញ្ញា ACTIP៖

iii. បទល្មើសជួញដូរមនុស្សណាមួយ ដែលត្រូវបានកំណត់ដោយអនុលោមជាមួយនឹងមាត្រា ៥ (ការចាត់ទុកជាបទល្មើសនៃអំពើជួញដូរមនុស្ស) នៃអនុសញ្ញា ACTIP ត្រូវបានចាត់ទុកថាជាបទល្មើសដែលអាចធ្វើបត្យាប័នបាន ដែលសមាជិកអាស៊ានគប្បីធ្វើ ដើម្បីបញ្ចូលគ្រប់សន្ធិសញ្ញាបត្យាប័ន ដែលសម្រេចបានជាមួយនឹងសមាជិកអាស៊ានមួយទៀត។

iv. ប្រសិនបើគ្មានសន្ធិសញ្ញាបត្យាប័នរវាងសមាជិកអាស៊ានពាក់ព័ន្ធអនុសញ្ញា ACTIPគប្បីត្រូវបានចាត់ទុកថាជាមូលដ្ឋានផ្លូវច្បាប់ ទាក់ទងនឹងបត្យាប័ន និង

v. ប្រសិនបើសមាជិកអាស៊ានមិនធ្វើបត្យាប័នជនល្មើសដែលរងការចោទប្រកាន់ ដោយសារគាត់គឺជាពលរដ្ឋម្នាក់នៃពលរដ្ឋរបស់ខ្លួន សមាជិកអាស៊ាននោះត្រូវមានកាតព្វកិច្ចដាក់ករណីនេះទៅដល់អាជ្ញាធរជាតិរបស់ខ្លួនដើម្បីផ្តន្ទាទោសជនល្មើសដែលរងការចោទប្រកាន់នោះ។

*មាត្រា ២២ (ការទុកដាក់ប្រាក់ចំណេញពីបទល្មើស ឬទ្រព្យសម្បត្តិ ដែលត្រូវបានដកហូត)*

នៅក្រោមមាត្រា ២២ នៃអនុសញ្ញា ACTIP៖

vi. រដ្ឋសមាជិកអាស៊ានដែលដកហូតប្រាក់ចំណេញពីបទល្មើស ឬទ្រព្យសម្បត្តិ នៅក្រោម ACTIP គប្បីទុកដាក់ប្រាក់ចំណេញ ឬទ្រព្យសម្បត្តិនោះ ដោយអនុលោមទៅតាមច្បាប់ជាតិ និងនីតិវិធីរដ្ឋបាលរបស់ខ្លួន និង

vii. ប្រសិនបើមានសំណើពីសមាជិកអាស៊ានមួយ សមាជិកអាស៊ានដទៃទៀតគប្បីផ្តល់អាទិភាពលើការប្រគល់ប្រាក់ចំណេញ ឬទ្រព្យសម្បត្តិដែលត្រូវបានដកហូត សម្រាប់ការផ្តល់សំណង និងជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬការផ្តល់ប្រាក់ចំណេញ ឬទ្រព្យសម្បត្តិដែលត្រូវបានដកហូតទាំងនោះទៅដល់ម្ចាស់ស្របច្បាប់វិញ។

## ការតាមដានត្រួតពិនិត្យ និងភាពអនុលោមតាម

*មាត្រា ២៤ (ការតាមដានត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការរាយការណ៍)*

មាត្រា ២៤ នៃអនុសញ្ញា ACTIP តម្រូវឱ្យកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពី បទល្មើសឆ្លងដែន ដែលមានការគាំទ្រពីលេខាធិការដ្ឋានអាស៊ាន លើកកម្ពស់ តាមដានត្រួតពិនិត្យ ពិនិត្យឡើងវិញ និងរាយការណ៍ជាប្រចាំអំពីការអនុវត្តអនុសញ្ញា ACTIP ជូនដល់កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីបទល្មើសឆ្លងដែន។

# គោលការណ៍សំខាន់ៗ

សូចនាករនៃការយកចិត្តទុកដាក់លើជនរងគ្រោះ (VSI) កើតចេញមកពីពិធីសារ ដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលបំពេញបន្ថែមចំពោះអនុសញ្ញាសហប្រជាជាតិប្រឆាំងនឹងបទល្មើសឆ្លងដែនដែលមានអង្គការចាត់តាំង។

សូចនាករនៃការយកចិត្តទុកដាក់លើជនរងគ្រោះក៏ប្រើប្រាស់គោលការណ៍នានានៅក្នុងគោលការណ៍ណែនាំសហប្រជាជាតិស្តីពីយុត្តិធម៌នៅក្នុងបញ្ហានានាពាក់ព័ន្ធនឹងកុមាររងគ្រោះ និងសាក្សីនៃបទល្មើស[៣] គោលការណ៍ណែនាំជាអនុសាសន៍ និងគោលការណ៍ណែនាំស្តីពី សិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស[៤] និងកញ្ចប់ឧបករណ៍របស់ UNODC ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។[៥]

គោលការណ៍ជាមូលដ្ឋាននៃអភិក្រមដែលយកចិត្តទុកដាក់លើជនរងគ្រោះ គឺថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាជនរងគ្រោះនៃបទល្មើស ហេតុនេះ ពួកគេមានសិទ្ធិទទួលបានភាពយុត្តិធម៌។ ពួកគេគប្បីទទួលបានការប្រព្រឹត្តចំពោះដោយសេចក្តីមេត្តា និងការគោរព ពោលគឺសេវាទាំងអស់គប្បីយកចិត្តទុកដាក់លើជនរងគ្រោះ[៦] ហើយកិច្ចការពារពិសេសគប្បីផ្តោតលើជនទាំងឡាយ ដែលមានភាពងាយរងគ្រោះជាពិសេស ដូចជា កុមារ និងជនមានពិការភាព។

គោលការណ៍សំខាន់ៗនៃអភិក្រមនេះ គឺដើម្បី៖

- **ផ្តល់ភាពអង់អាច**ដល់ជនរងគ្រោះ តាមរយៈការគាំទ្រ និងការបង្កលក្ខណៈសម្រាប់ការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនេះ។
- **កាត់បន្ថយ**លទ្ធភាពនៃមានភាពរងគ្រោះជាលើកទីពីរនិងការប៉ះទង្គិចផ្លូវចិត្តជាថ្មីម្តងទៀតចំពោះជនរងគ្រោះ។
- **កសាង**ទំនុកចិត្តចំពោះប្រព័ន្ធតុលាការ និងយុត្តិធម៌។
- **ការពារ**សុចរិតភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

---

៣ ពិធីសារស្តីពី អំពើជួញដូរមនុស្សត្រូវបានមហាសន្និបាទផ្តល់ការអនុម័តនៅក្នុងសេចក្តីសម្រេច ៥៥/២៥ នៃថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ (ឧបសម្ព័ន្ធ ២) របស់ខ្លួន។ ពិធីសារនេះចូលជាធរមាននៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣។ ស្ថានភាពនៃការផ្តល់សច្ចាប័នចំពោះពិធីសារនេះមាននៅ៖ www.unodc.org/en/treaties/CTOC/signa-tures. See also the annotated guide available at: www.globalrights.org/ site/DocServer/Annotated_Protocol.pdf? docID=2723

៤ ECOSOC Resolution 2005/20

៥ គោលការណ៍ណែនាំជាអនុសាសន៍ និងគោលការណ៍ណែនាំស្តីពី សិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស របាយការណ៍របស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ជូនដល់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច (2002) (E/2002/68/Add.1)

៦ ជនរងគ្រោះគប្បីទទួលបានការប្រព្រឹត្តចំពោះដោយការថែទាំ និងការយកចិត្តទុកដាក់នៅទូទាំងដំណើរការយុត្តិធម៌ ដោយពិចារណាលើស្ថានភាពផ្ទាល់ខ្លួន តម្រូវការ ចំពោះមុខ អាយុ យេនឌ័រ ពិការភាព កម្រិតនៃភាពចាស់ទុំរបស់ពួកគេ និងដោយគោរពយ៉ាងពេញលេញចំពោះសុចរិតភាពផ្លូវកាយ ផ្លូវចិត្ត និងសីលធម៌របស់ពួកគេ។ ជនរងគ្រោះគប្បីទទួលបានការប្រព្រឹត្តចំពោះក្នុងនាមជាមនុស្សម្នាក់ ដែលមានតម្រូវការ បំណងប្រាថ្នា និងអារម្មណ៍រៀងៗខ្លួនរបស់ពួកគេ។

# សូចនាករទាំង ៨ នៃការយកចិត្តទុកដាក់លើជនរងគ្រោះ

មានវិស័យកម្រិតខ្ពស់បំផុតចំនួន ៨ ដែលអ្នកពាក់ព័ន្ធមកពីតុលាការ និងប្រព័ន្ធយុត្តិធម៌ដទៃទៀត គប្បីផ្តោតលើនៅពេលដោះស្រាយសំណុំរឿងជួញដូរមនុស្ស។ សូចនាករនៃការយកចិត្តទុកដាក់លើជនរងគ្រោះទាំងនេះ (VSI) ដើរតួនាទីជាក្របខណ្ឌការងារ និងចំណុចយោង ដើម្បីជួយវិស័យយុត្តិធម៌ ជាពិសេស តុលាការ ក្នុងការការពារសិទ្ធិរបស់ជនត្រូវបានជួញដូរ។




វីដេអូខ្លីមួយត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវទស្សនៈរួមអំពី សូចនាករទាំងនេះ និងអាចទស្សនាបានតាមរយៈការចូលទៅកាន់ https://www.youtube.com/watch?v=tZoiD2NfC0E

សូចនាករ

១

សុវត្ថិភាព និង ឯកជនភាព

## សូចនាករ ១៖ ការធានាសុវត្ថិភាព និងឯកជនភាពរបស់ជនត្រូវបានជួញដូរ

### ទស្សនៈរួម

វិស័យយុត្តិធម៌ចាំបាច់ត្រូវធានាថា ជនត្រូវបានជួញដូរទទួលបានកិច្ចការពារប្រកបដោយប្រសិទ្ធភាពពីគ្រោះថ្នាក់ ការគំរាមកំហែង ឬការបំភិតបំភ័យបន្ថែមទៀតពីសំណាក់ជនជួញដូរមនុស្ស និងបុគ្គលជាប់ពាក់ព័ន្ធ។ នេះមានន័យថា គប្បីគ្មានការបង្ហាញជាសាធារណៈអំពី អត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរ ហើយឯកជនភាពរបស់ពួកគេគប្បីទទួលបានការគោរព និងការពារក្នុងកម្រិតដែលអាចធ្វើបាន ស្របពេលដែលមានការពិចារណាលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌ផងដែរ។[៧] វាក៏មានន័យថា ការចាត់គ្រប់វិធានការសមហេតុផលទាំងអស់ដើម្បីធានានូវសុវត្ថិភាពរបស់ជនរងគ្រោះនៅពេលដែលពួកគេមកកាន់តុលាការនិងធានាថា ជំហាននានាត្រូវបានរៀបចំឡើង ដើម្បីកំណត់ និងកាត់បន្ថយហានិភ័យចំពោះជនត្រូវបានជួញដូរ នៅពេលដែលពួកគេគឺជាសាក្សីនៅក្នុងសំណុំរឿងមួយ។

### គោលការណ៍

***តើគប្បីអនុវត្តអ្វីខ្លះ?***

១.១. បិទទ្វារតុលាការ តុលាការដំណើរការជាលក្ខណៈឯកជន? នៅពេលដែលជនរងគ្រោះ ឬសាក្សីងាយរងគ្រោះកំពុងផ្តល់សក្ខីកម្ម (អនុសញ្ញា ACTIP មាត្រា ១៤.៦)

១.២. រៀបចំ និងអនុវត្តផែនការប៉ាន់ប្រមាណហានិភ័យ/ផែនការសុវត្ថិភាព សម្រាប់ជនរងគ្រោះ/សាក្សីដែលចែងលម្អិតអំពី ជំហានដែលត្រូវធ្វើ ដើម្បីការពារពួកគេនៅក្នុងអំឡុងពេលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ (អនុសញ្ញា ACTIP មាត្រា ១៤.៥)

១.៣. សេចក្តីសម្រេច/សាលក្រមនៅក្នុងសំណុំរឿងជួញដូរមនុស្ស និងដែលត្រូវផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ (អនុសញ្ញា ACTIP មាត្រា ១៤.៦)

១.៤. មាននីតិវិធីតុលាការ ដើម្បីហាមឃាត់ការបោះពុម្ពផ្សាយអំពីព័ត៌មានលម្អិតដែលមានអត្តសញ្ញាណរបស់ជនរងគ្រោះ/សាក្សី នៅតាមប្រព័ន្ធផ្សព្វផ្សាយ ឬនៅលើបណ្តាញទំនាក់ទំនងសង្គម (អនុសញ្ញា ACTIP មាត្រា ១៤.៦)

### ឧទាហរណ៍៖

ការបិទទ្វារតុលាការពីសាធារណជន - នៅអូស្ត្រាលី ក្រមព្រហ្មទណ្ឌខុមមិនវែល (Commonwealth Criminal Code) អនុញ្ញាតឱ្យតុលាការបដិសេធសមាជិកសាធារណជនទាំងអស់ ឬមួយចំនួនពីការចូលរួមនៅតុលាការ។ ក្រមបែបនេះមានសារសំខាន់ជាពិសេសចំពោះសំណុំរឿងពាក់ព័ន្ធនឹងកុមារ ឬជនរងគ្រោះ/សាក្សីងាយរងគ្រោះ ឧទាហរណ៍ ជនណាម្នាក់ ដែលចាំបាច់ត្រូវផ្តល់ភ័ស្តុតាងអំពី អំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ។

៧ Office of the High Commissioner for Human Rights, Recommended Principles and Guidelines on Human Rights and Human Trafficking. P11

**ព័ត៌មានអំពី យុទ្ធសាស្ត្រ ដែលតុលាការអនុវត្ត ដើម្បីការពារជនរងគ្រោះ និងសាក្សី** - តុលាការសឹង្ហបុរីបានរៀបចំ*កញ្ចប់ឧបករណ៍ផ្លូវច្បាប់ សម្រាប់សាក្សី*[៨] ដែលចែងលម្អិតអំពីរបៀបដែលតុលាការអាចចេញបញ្ជាឱ្យរៀបចំសវនាការក្នុងលក្ខណៈឯកជនឬ"តាមរយៈម៉ាស៊ីនថត" នៅពេលដែលដំណើរការនេះមានលក្ខណៈបិទទ្វារចំពោះសាធារណជន និងប្រព័ន្ធផ្សព្វផ្សាយ។ ពួកគេក៏អាចអនុវត្ត"ដីកាហាមឃាត់"ដើម្បីការពារសាក្សីងាយរងគ្រោះ តាមរយៈការហាមឃាត់ចំពោះការផ្សព្វផ្សាយព័ត៌មានលម្អិតពាក់ព័ន្ធនឹងអត្តសញ្ញាណផងដែរ។ ព័ត៌មានបែបនេះរួមមានឈ្មោះ អាសយដ្ឋាន រូបថតរបស់សាក្សី ឬព័ត៌មានដទៃទៀត ដែលទំនងជានាំឱ្យមានការកំណត់អត្តសញ្ញាណរបស់សាក្សីបាន។



*កញ្ចប់ឧបករណ៍ផ្លូវច្បាប់សម្រាប់សាក្សី*

**ព័ត៌មានអំពី សុវត្ថិភាពសម្រាប់ជនរងគ្រោះ និងសាក្សី** - នៅសហរដ្ឋអាមេរិក យុត្តាធិការមួយចំនួនផ្តល់ព័ត៌មានដល់សាក្សីស្តីពី របៀបការពារសុវត្ថិភាពរបស់ពួកគេ នៅពេលដែលពួកគេទៅកាន់តុលាការ។[៩]

**ការធ្វើដំណើរទៅកាន់តុលាការ**

- ព្យាយាមទៅកាន់តុលាការនៅពេលវេលាខុសគ្នាពីពេលវេលា ដែលអ្នកគិតថា ជនរំលោភបំពាននឹងទៅដល់ ដើម្បីជៀសវាងការមើលឃើញជននោះនៅតាមផ្លូវ ឬនៅស្របពេលធ្វើដំណើរទៅកាន់តុលាការ។ ប្រសិនបើជនរំលោភបំពានតែងតែមកយឺត សូមព្យាយាមមកដល់តុលាការឱ្យបានមុន ប្រសិនបើជនរំលោភបំពានតែងតែមកដល់មុន សូមព្យាយាមមកដល់តុលាការនៅពេលកៀកនឹងពេលវេលានៃការបើកសវនាការរបស់អ្នក ឬមកជាមួយនឹងមិត្តភក្តិ។ សូមចងចាំ៖ ប្រាកដថា អ្នកទុកពេលគ្រប់គ្រាន់ សម្រាប់ការឆ្លងកាត់ជួរមនុស្ស ម៉ាស៊ីនស្កេនរកលោហៈធាតុ ជាដើម ដើម្បីឱ្យអ្នកមកដល់សវនាការទាន់ពេល។ ប្រសិនបើអ្នកមកយឺត សំណុំរឿងនេះអាចត្រូវបានប្រកាសដោយគ្មានអ្នក និងត្រូវបានលើកចោល។ ការស្វែងរកអ្នកធ្វើការផ្នែកអំពើហិង្សាក្នុងគ្រួសារឱ្យទៅជាមួយអ្នក អាចជួយ រក្សាសុវត្ថិភាពអ្នកបាន។ ការហៅទូរស័ព្ទទៅកាន់បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ជាតិស្តីពី អំពើហិង្សាក្នុងគ្រួសារ (១-៨០០-៧៩៩-SAFE) ដើម្បីស្វែងរកជំនួយដែលនៅជិតអ្នក។ អ្នកក៏អាចរកបានបញ្ជីនៃអង្គការដែលធ្វើការផ្នែកអំពើហិង្សាក្នុងគ្រួសារនៅតំបន់របស់អ្នកនៅក្នុងទំព័រ**ស្វែងរកមតិគាំទ្រ និងជម្រក**របស់យើងផងដែរ។
- សូមពិនិត្យមើលថា តើនាយកដ្ឋាននគរបាល និងនាយកដ្ឋានអនុវត្តដីការបស់អ្នកនឹងនាំអ្នកទៅកាន់តុលាការដែរឬទេ។ សូមជួបជាមួយពួកគេនៅកន្លែងណាមួយក្រៅពីនៅការិយាល័យតុលាការ ហើយបន្ទាប់មកសុំឱ្យមន្ត្រីនាំអ្នកចូលក្នុងតុលាការ។ សុំឱ្យមន្ត្រីរងចាំអ្នករហូតដល់អ្នករកឃើញអាជ្ញាសាលា ឬសន្តិសុខនៅតុលាការ និងប្រាប់ពួកគេអំពីស្ថានភាពរបស់អ្នក។ ប្រសិនបើអាចធ្វើបាន សូមព្យាយាមអង្គុយនៅជិតមន្ត្រីតុលាការ ឬសន្តិសុខ ។
- នាំមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់ទៅជាមួយអ្នក ដើម្បីកុំឱ្យអ្នកនៅតែម្នាក់ឯង។
- ប្រសិនបើមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់របស់អ្នកមិនអាចចំណាយពេលនៅជាមួយអ្នកនៅតុលាការបាន សុំឱ្យបុគ្គលនោះបើកបរជូនអ្នកទៅកាន់តុលាការ។ ជាការល្អបំផុត គឺជ្រើសរើសអ្នកណាម្នាក់ ដែលជនរំលោភបំពានមិនស្គាល់រថយន្តរបស់គាត់។ ហើយ សុំឱ្យគាត់ដាក់អ្នកចុះនៅច្រកទ្វារចូលតុលាការ ដើម្បីកុំឱ្យអ្នកត្រូវដើរតែម្នាក់ឯងពីចំណតរថយន្ត។

**ផែនការសុវត្ថិភាព** - នៅអូស្ត្រាលី មន្ត្រីតុលាការគ្រួសារ សួរសំណួរមួយចំនួនទៅកាន់ជនរងគ្រោះ និងពិភាក្សាអំពីការរៀបចំនានា ដែលចាំបាច់ ដើម្បីជួយពួកគេក្នុងការចូលរួមនៅតុលាការដោយសុវត្ថិភាព។ មន្ត្រីនេះបង្កើត "ផែនការសុវត្ថិភាព" ដោយពិគ្រោះយោបល់ជាមួយនឹងជនរងគ្រោះ/សាក្សី ហើយផែនការនេះកំណត់អំពីប្រភេទនៃកិច្ចការពារ ដែលជនរងគ្រោះអាចរំពឹងថា នឹងទទួលបានពីតុលាការ លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង ប្រសិនបើពួកគេព្រួយបារម្ភអំពីសុវត្ថិភាពរបស់ពួកគេ ហើយក្នុងករណីខ្លះ អាចផ្តល់មន្ត្រីសន្តិសុខ ដើម្បីអមដំណើរពួកគេទៅ និងមកពីតុលាការផងដែរ។[១០]




៨ https://hagar.org.sg/wp-content/uploads/2021/06/General-Legal-Toolkit-Handbook-for-Vulnerable-Witnesses.pdf

៩ https://www.womenslaw.org/about-abuse/safety-tips/safety-court#1

១០ សូមមើល៖ https://www.fcfcoa.gov.au/sites/default/files/2021-08/Do-you-have-fears-for-your-safety-while-attending-court-0921V1.pdf

**ការបោះពុម្ពផ្សាយសាលក្រមក្នុងលក្ខណៈអនាមិកតាមប្រព័ន្ធអនឡាញ** - តុលាការកំពូលរបស់ឥណ្ឌូនេស៊ីបោះពុម្ពផ្សាយសេចក្តីសម្រេចតុលាការស្តីពីអំពើជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ តាមរយៈមូលដ្ឋានទិន្នន័យមួយ ដែលគេហៅថា *Direktori Putusan*។[១១] មូលដ្ឋានទិន្នន័យនេះអនុញ្ញាត សម្រាប់ការស្រាវជ្រាវទៅតាមប្រភេទករណី ឆ្នាំ និងតំបន់។ ការបោះពុម្ពផ្សាយសេចក្តីសម្រេចអំពីសំណុំរឿងជួញដូរមនុស្សមានសារសំខាន់ ដោយសារវាអនុញ្ញាតឱ្យមានតម្លាភាពកាន់តែខ្លាំងអំពី ដំណើរការតុលាការ កសាងទំនុកចិត្តចំពោះប្រព័ន្ធតុលាការ និងពង្រឹងការយល់ដឹងរបស់សាធារណជនអំពីដំណើរការតុលាការ។ ការធ្វើឱ្យសាលក្រមមានលក្ខណៈជាសាធារណៈក៏អាចលើកកម្ពស់ការយល់ដឹង និងរារាំងអ្នកដទៃទៀតពីការចូលរួមបទល្មើសដែលមានសកម្មភាពស្រដៀងគ្នានេះ និងជាប្រភពដ៏មានតម្លៃ សម្រាប់ការអប់រំច្បាប់។




ប្រទេសភាគច្រើនធ្វើអនាមិកភាពលើសេចក្តីសម្រេចអំពីអំពើជួញដូរមនុស្ស មុនពេលបោះពុម្ពផ្សាយសេចក្តីសម្រេចទាំងនោះតាមប្រព័ន្ធអនឡាញ។ មានវិធីមួយចំនួន ដើម្បីធ្វើអនាមិកភាពសាលក្រម រួមមាន៖

១. ការប្រើប្រាស់អក្សរកាត់នៃឈ្មោះរបស់ភាគីប៉ុណ្ណោះ (ប្រទេសស៊ែប៊ី)
២. ការកែប្រែសាលក្រម ដើម្បីឱ្យមិនអាចមើលឃើញព័ត៌មានអត្តសញ្ញាណទាំងអស់ (សហរដ្ឋអាមេរិក)
៣. ការប្រើប្រាស់ឈ្មោះក្លែងក្លាយ ដែលមានការទទួលស្គាល់នៅលើទំព័រគម្របនៃសាលក្រម (អូស្ត្រាលី)។

**ក) ឧទាហរណ៍របស់ប្រទេសស៊ែប៊ីអំពី សាលក្រមអនាមិកភាពដោយប្រើប្រាស់ឈ្មោះអក្សរកាត់របស់ភាគីប៉ុណ្ណោះ**


MAGISTRATE COURT IN NOVI SAD

07 Case No. 3-1973/11

IN THE NAME OF THE PEOPLE

Magistrate Court in Novi Sad, judge Ivana Ivanović, in compliance with article 85 item 3 of Petty Offense Law («Official Gazette of the Republic of Serbia» No. 101/05, 116/08 and 111/09) in the judicial proceedings against defendant M. M. from N. S. because of violation of the article 15 item 1 of Public Order Law («Official Gazette of the Republic of Serbia» No. 51/92, 53/93, 67/93, 48/94 и 101/05) on the January 11th, 2012, has made the following

JUDGMENT

Defendant M. M. the daughter of A. born on ... in D. personal number ... with the residence in N. S.

IS FOUND GUILTY:

Because on ... in N. S. she disturbed public order by loudly playing music on a musical device. The sound was heared outside apartment and thus the defendant disturbed the public order and peace of the surrounding residents and by doing so the defendant has broken article 15, item 1 of The Public Order Law. The Court, by applying the cited law,

HAS SENTENCED

the defendant to pay a fine in the amount of 50.00 EUR (fifty euros).

**ខ) ឧទាហរណ៍របស់សហរដ្ឋអាមេរិកអំពី សាលក្រមដែលត្រូវបានកែប្រែ**


[redacted]
Las Vegas, Nevada 89109
[redacted]
ATTORNEY FOR DEFENDANT

UNITED STATES DISTRICT COURT
DISTRICT OF NEVADA

[redacted] PLAINTIFF
v. NO. [redacted]
[redacted]
DOES 1- DEFENDANTS

EMERGENCY MOTION AND MEMORANDUM
IN SUPPORT OF MOTION TO SET ASIDE
SUMMARY JUDGMENT AND FOR LEAVE
TO AMEND OR WITHDRAW RESPONSE
TO ADMISSIONS

Comes the Defendant, [redacted] by counsel, and for his motion to Set Aside Summary Judgment states as follows:

1. On July 5th, 2006, Plaintiff [redacted] filed a Motion for Summary Judgment in this Court.

ការពិចារណាពាក់ព័ន្ធមួយទៀត គឺថាតើ "ដីកានេះចាំបាច់ដើម្បីការពារសុវត្ថិភាពរបស់បុគ្គលណាម្នាក់ដែរឬទេ"៖ s ៨(១)(c). "សុវត្ថិភាព" រួមទាំងសុវត្ថិភាពផ្លូវចិត្តផងដែរ៖ AB (ឈ្មោះក្លែងក្លាយ) v R (លេខ ៣) នៅ [៥៩]។ នៅពេលពិចារណាលើ s ៨(១)(c) "អភិក្រមគណនាហានិភ័យ" គប្បីត្រូវបានទទួលយកមកប្រើប្រាស់ ហើយអភិក្រមនេះត្រូវការការពិចារណាអំពី ចរិត ភាពជិតកើតឡើង និងកម្រិតនៃលទ្ធភាពរបស់គ្រោះថ្នាក់/ការឈឺចាប់ ដែលកំពុងកើតឡើងចំពោះបុគ្គលនោះ។ ប្រសិនបើ គ្រោះថ្នាក់ដែលត្រូវរំពឹងទុកថានឹងកើតឡើង មានលក្ខណៈធ្ងន់ធ្ងរខ្លាំង វាអាចជាការបញ្ជាក់ថា ដីកាគឺចាំបាច់ បើទោះបីជាហានិភ័យមិនកើតឡើងលើសពីលទ្ធភាពធម្មតាក្តី៖ AB (ឈ្មោះក្លែងក្លាយ) v R (លេខ ៣) នៅ [៥៩] Darren Brown (ឈ្មោះក្លែងក្លាយ) v R (លេខ ២) [២០១៩] NSWCCA ៦៩ នៅ [៣៧]។

[១១] https://putusan3.mahkamahgung.go.id

សូចនាករ

# ២

ភស្តុតាង និង ដំណើរការ

## សូចនាករ ២៖ ភស្តុតាងល្អបំផុត - វិធីដែលជនត្រូវបានជួញដូរ កត់ត្រា និងបង្ហាញភស្តុតាងរបស់ពួកគេនៅក្នុងដំណើរការតុលាការ

### ទស្សនៈរួម

ជនរងគ្រោះដោយអំពើជួញដូរមនុស្សតែងតែមានអារម្មណ៍ថាងាយរងគ្រោះ និងមានអារម្មណ៍រងការសន្ទប់ជាខ្លាំងដោយសារការមិនយល់ដឹងច្បាស់អំពីប្រព័ន្ធយុត្តិធម៌ និងអាចរងគ្រោះជាថ្មីម្តងទៀត តាមរយៈការប្រព្រឹត្តបែបមិនយកចិត្តទុកដាក់ ឬរើសអើងពីសំណាក់អ្នកផ្តល់សេវាយុត្តិធម៌មួយចំនួន។ ចាំបាច់ត្រូវរៀបចំវិធានការនានាដើម្បីទប់ស្កាត់ការប៉ះទង្គិចផ្លូវចិត្តបន្ថែមដែលអាចកើតឡើងពីការចូលរួមនៅការជំនុំជម្រះ និងការផ្តល់ភស្តុតាង។

ដើម្បីធានាថា ដំណើរការជំនុំជម្រះពង្រីកកិច្ចសហការរបស់ជនរងគ្រោះ តុលាការចាំបាច់ត្រូវផ្តល់បរិយាកាសតុលាការបែបមេត្រីភាព និងអំណោយផល ដើម្បីឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សមានអារម្មណ៍សុវត្ថិភាព និងជាសុកភាពក្នុងការរៀបរាប់ឡើងវិញអំពី អ្វីដែលពួកគេបានជួបប្រទះ និងចាំបាច់ត្រូវមាននីតិវិធី ដើម្បីកាត់បន្ថយភាពរងគ្រោះជាថ្មីម្តងទៀត ហើយនៅទីបំផុតមានការអនុវត្តច្បាប់នានាក្នុងលក្ខណៈគ្មានការរើសអើង។

### គោលការណ៍

***តើគប្បីអនុវត្តអ្វីខ្លះ?***

ដើម្បីអនុវត្តគោលការណ៍នេះ តុលាការគប្បីធានាថា៖

២.១. សំណុំរឿងជួញដូរមនុស្ស គឺជាអាទិភាព ឬទទួលបានការចាត់ការយ៉ាងរហ័ស។ តាមរយៈការឆ្លើយតបយ៉ាងរហ័ស និងសមស្របចំពោះសំណុំរឿងជួញដូរមនុស្ស និងតាមរយៈការចាត់ការយ៉ាងរហ័សចំពោះសំណុំរឿងនានាដែលពាក់ព័ន្ធនឹងជនរងគ្រោះងាយរងគ្រោះ ជនរងគ្រោះកាន់តែមានបំណងរាយការណ៍អំពី ករណីទាំងនេះ ហើយទំនុកចិត្តលើតុលាការក្នុងការដោះស្រាយសំណុំរឿងនេះប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពនឹងត្រូវបានពង្រឹង (ARTIP មាត្រា ១៦.៣)

២.២. វិធានការនានាត្រូវបានរៀបចំ ដើម្បីធានាថា ជនរងគ្រោះទទួលបានឱកាស និងការគាំទ្រនៅក្នុងដំណើរការព្រហ្មទណ្ឌ តាមរយៈ៖

ក) ការប្រើប្រាស់សាក្សីជំនាញ (ដូចជា អន្តរការី) ក្នុងការផ្តល់ភស្តុតាងនៅពេលចាំបាច់អំពី ថាមវន្ត និងភាពស្មុគស្មាញនៃអំពើជួញដូរមនុស្ស ព័ត៌មានអំពីសាក្សីងាយរងគ្រោះ ដូចជា ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត ឥទ្ធិពលលើកុមារ ភស្តុតាងនៃអំពើហិង្សាផ្លូវភេទពីវេជ្ជបណ្ឌិតកោសល្យវិច្ច័យ និងវេជ្ជបណ្ឌិតវេជ្ជសាស្ត្រជាដើម។ (ARTIP មាត្រា ១៤.១០)

ខ) ការអនុញ្ញាតឱ្យជនរងគ្រោះម្នាក់មានបុគ្គលគាំទ្រ ដែលជាជម្រើសរបស់ពួកគេ ដើម្បីនៅជាមួយពួកគេ នៅពេលពួកគេផ្តល់សក្ខីកម្ម នៅតុលាការ (ទោះជានៅក្នុងដំណើរការបិទទ្វារក្តី) និងនៅទូទាំងការជំនុំជម្រះ[១២] (ARTIP មាត្រា ១៤.១០)

១២ ក្នុងយុត្តាធិការមួយចំនួន បច្ចេកទេសទូទៅមួយ គឺសម្រាប់មេធាវីការពារចុងចោទកោះហៅសមាជិកគ្រួសាររបស់ជនរងគ្រោះ ដែលជាសាក្សីសក្តានុពល ដើម្បីឱ្យពួកគេមិនអាចគាំទ្រជនរងគ្រោះនៅតុលាការ និងដាក់សម្ពាធបន្ថែមលើជនរងគ្រោះ។ តុលការ និងព្រះរាជអាជ្ញាចាំបាច់ត្រូវដឹងអំពី យុទ្ធសាស្ត្រនេះរបស់មេធាវីការពារមួយចំនួន និងបដិសេធការស្នើសុំបែបនេះ។

គ) ការធានាថា មានអ្នកបកប្រែភាសាប្រកបដោយគុណវុឌ្ឍិ ដើម្បីឱ្យជនរងគ្រោះអាចយល់ និងចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការព្រហ្មទណ្ឌ (ARTIP មាត្រា ១៤.១០ខ)

២.៣. វិធានការនានាត្រូវបានរៀបចំ ដើម្បីធានាថា ជនរងគ្រោះ (ដែលមានបំណងចូលរួម) អាចចូលរួមដោយមិនមើលឃើញជនត្រូវចោទ តាមរយៈការប្រើប្រាស់៖

ក) ផ្ទាំងស្ក្រីនសម្រាប់សាក្សី ដើម្បីបញ្ចាំងអំពីជនត្រូវចោទ (ARTIP មាត្រា ១៤.៦)

ខ) បច្ចេកវិទ្យាវីដេអូខុនហ្វឺរិន ដើម្បីឱ្យសាក្សីអាចផ្តល់ភ័ស្តុតាងពីចម្ងាយពីទីកន្លែងមួយទៀត ឬពីបន្ទប់មួយទៀត (ARTIP មាត្រា ១៦.៧)

គ) ភ័ស្តុតាងជាវីដេអូដែលត្រូវបានថតជាមុន ត្រូវបានចាក់បញ្ចាំងនៅតុលាការអំពី ការរៀបរាប់ភ័ស្តុតាងឡើងវិញរបស់ជនរងគ្រោះ (ARTIP មាត្រា ១៦.៧)

ឃ) ច្រកចូល និងបន្ទប់រង់ចាំដោយឡែក សម្រាប់ជនរងគ្រោះ/សាក្សីនៃអំពើជួញដូរមនុស្សក្នុងអំឡុងពេលនៃអង្គជំនុំជម្រះទាំងមូល នឹងជាពិសេស នៅមុន និងក្រោយពេលនៃការផ្តល់ភ័ស្តុតាង (AR-TIP មាត្រា ១៦.៧)

២.៤. ការប្រើប្រាស់ "របាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ" ដើម្បីធានាថា ចៅក្រមមានការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយអំពី ផលប៉ះពាល់លើជនរងគ្រោះ ដែលបង្កឡើងដោយជនល្មើស (ដើម្បីទទួលបានសំណងចំពោះការរងការខូចខាត) (ARTIP មាត្រា ១៤.១៣)

## ឧទាហរណ៍៖

យុត្តាធិការជាច្រើនបានណែនាំឱ្យអនុវត្តវិធានការពិសេសមួយចំនួន ដូចជា ការប្រើប្រាស់ផ្ទាំងសំពត់សការផ្តល់ភ័ស្តុតាងតាមរយៈតំណភ្ជាប់វីដេអូ ឬការចាក់កិច្ចសម្ភាសរបស់នគរបាលដែលត្រូវបានថតទុក ការមិនស្លៀកសំលៀកបំពាក់ឯកសណ្ឋានតុលាការផ្លូវការ និងការរៀបចំឱ្យច្រកចូលសាធារណៈនៅតុលាការគ្មានអ្វី/មនុស្សនៅទីនោះ។ វិធានការពិសេសទាំងនេះត្រូវបានវាយតម្លៃនៅប្រទេសអង់គ្លេស និងប្រទេសវេល[១៣] និងបានបង្ហាញថា ទទួលបានភាពជោគជ័យនៅក្នុងការកាត់បន្ថយភាពថប់បារម្ភរបស់ជនរងគ្រោះ។

**ភ័ស្តុតាងជាវីដេអូដែលត្រូវបានថតទុក** - នៅក្នុងយុត្តាធិការជាច្រើននៅជុំវិញពិភពលោក មានបទបញ្ញត្តិនៅក្នុងច្បាប់ ដែលអនុញ្ញាតឱ្យសាក្សីងាយរងគ្រោះផ្តល់ភ័ស្តុតាងរបស់ពួកគេនៅក្រោមលក្ខខណ្ឌនានា ដែលធ្វើឱ្យបទពិសោធន៍នេះកាន់តែងាយស្រួលសម្រាប់ពួកគេ។ បទបញ្ញត្តិនេះរួមទាំងការផ្តល់ភស្តុតាងជាចម្បងតាមរយៈវិធីនៃការថតកិច្ចសម្ភាសទុកជាមុន ដែលធ្វើឡើងដោយនគរបាល។ វីដេអូថតទុកជាមុនបែបនេះអាចត្រូវបានកែសម្រួល ដើម្បីលុបចោលសេចក្តីថ្លែងរបស់ជនរងគ្រោះ ដែលមិនត្រូវបានតុលាការទទួលយកមុនពេលចាក់បញ្ចាំងនៅតុលាការ។ ភ័ស្តុតាងប្រភេទនេះក៏អាចត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញា បុគ្គលិកសង្គម និងអ្នកវិជ្ជាជីវៈគាំទ្រជនរងគ្រោះផងដែរ ដើម្បីកុំឱ្យជនរងគ្រោះនិយាយអំពីរឿងរ៉ាវរបស់ពួកគេម្តងហើយម្តងទៀត។

តាមច្បាប់រដ្ឋប្បវេណី សេចក្តីថ្លែងរបស់ជនរងគ្រោះត្រូវថតនៅចំពោះមុខចៅក្រម ដោយមានវត្តមានរបស់មេធាវីការពារចុងចោទ ដើម្បីអាចសួរសំណួរដល់ជនរងគ្រោះនៅពេលណាមួយ។ នៅក្នុងប្រទេសដែលមានច្បាប់ទូទៅ សេចក្តីថ្លែងថតទុកមុនត្រូវបានបញ្ចូល នៅក្នុងអំឡុងពេលនៃការសាកសួរចម្បង ប៉ុន្តែជនរងគ្រោះត្រូវត្រៀមលក្ខណៈរួច ដើម្បីឆ្លើយសំណួរពីមេធាវីការពារចុងចោទនៅក្នុងអំឡុងពេនៃការសាកសួរពីភាគីបដិបក្ខ។

១៣ Olivia Smith and Tina Skinner, "Observing Court Responses to Victims of Rape and Sexual Assault", Feminist Criminology, vol. 7, No. 4 (2012).

តុលាការនៅប្រទេសអង់គ្លេស និងវេល បានដាក់ចេញវិធានការពិសេសទាំងនេះ ដែលជៀសវាងការប៉ះទង្គិចលើផ្លូវចិត្តជនរងគ្រោះ និងសាក្សីងាយរងគ្រោះពាក់ព័ន្ធនឹងការចូលរួមនៅក្នុងតុលាការ និងអនុញ្ញាតឱ្យកុមារ និងសាក្សីងាយរងគ្រោះដទៃទៀតថតវីដេអូអំពី ការសាកសួរពីភាគីបដិបក្ខជាមុន និងចាក់បញ្ចាំងនៅក្នុងពេលជំនុំជម្រះ។ ការថតនេះកើតឡើងនៅកៀកនឹងពេលវេលា ដែលបទល្មើសបានកើតឡើង បើអាចធ្វើបាន ដើម្បីជួយរំលឹកដល់ការចងចាំ និងកាត់បន្ថយភាពតានតឹងក្នុងចិត្តពាក់ព័ន្ធនឹងការផ្តល់ភ័ស្តុតាងនៅបន្ទប់សវនាការ។[១៤] អ្នកអាចសិក្សាបន្ថែមអំពី ភ័ស្តុតាងថតទុកជាមុននៅក្នុងវេប៊ីណារបស់ ASEAN ACT ពោលគឺវិធីផ្សេងៗទៀតនៃការបង្ហាញអំពី សក្ខីកម្មរបស់ជនរងគ្រោះ នៅ

https://aseanactpartnershiphub.com/events/

**បច្ចេកវិទ្យាវីដេអូខុនហ្វឺរិន** - ភ្ជាប់ទំនាក់ទំនងភាគីនានាទៅកាន់ដំណើរការតុលាការដោយមិនចាំបាច់ឱ្យពួកគេធ្វើដំណើរទៅកាន់តុលាការ ដែលជាការកាត់បន្ថយបន្ទុកចំណាយ និងបង្កើនប្រសិទ្ធផលនៃដំណើរការនេះ។ បច្ចេកវិទ្យានេះអាចបង្កើនលទ្ធភាព ដែលសាក្សីសំខាន់ៗនៅក្នុងសំណុំរឿងជួញដូរមនុស្សនឹងត្រៀមលក្ខណៈ ដើម្បីផ្តល់ភស្តុតាងនៅតុលាការ។ ផលប្រយោជន៍មួយទៀតនៃសក្ខីកម្មតាមតំណភ្ជាប់វីដេអូគឺជាសមត្ថភាពក្នុងការភ្ជាប់ទំនាក់ទំនងជាមួយអ្នកបកប្រែ ដែលអាចស្ថិតនៅទីកន្លែងផ្សេងៗគ្នា។ ឧទាហរណ៍ការស្វែងរកអ្នកបកប្រែភាសាខ្មែរ សម្រាប់ជនរងគ្រោះកម្ពុជា ដែលផ្តល់សក្ខីកម្មនៅក្នុងតុលាការម៉ាឡេស៊ី ឬថៃ អាចមានការលំបាក។ សក្ខីកម្មតាមតំណភ្ជាប់វីដេអូអនុញ្ញាតឱ្យអ្នកបកប្រែទាំងនេះភ្ជាប់ទំនាក់ទំនងពីចម្ងាយ និងផ្តល់សេវាបកប្រែក្នុងតម្លៃកាន់តែទាបសម្រាប់តុលាការ។

**ផ្ទាំងសំពត់សឯកជនភាពជនរងគ្រោះ** - នៅក្នុងតុលាការទាំងឡាយ ដែលគ្មានបរិក្ខារផ្តល់សក្ខីកម្មតាមវីដេអូ ឬបរិក្ខារទូរទស្សន៍ក្រោមការត្រួតពិនិត្យ សាក្សីងាយរងគ្រោះម្នាក់គប្បីទទួលបានការអនុញ្ញាតឱ្យផ្តល់ភ័ស្តុតាងនៅក្នុងវិធីជំនួសដទៃទៀត ដូចជា នៅពីក្រោយផ្ទាំងសំពត់រក្សាឯកជនភាពនៅក្នុងបន្ទប់សវនាការ ឬពីអគារដទៃទៀត។ សាក្សីរងគ្រោះក៏គប្បីទទួលបានការអនុញ្ញាតឱ្យមានបុគ្គលគាំទ្រផងដែរពី ឪពុក ឬម្តាយ ឬមិត្តភក្តិដែលពួកគេជ្រើសរើស អង្គុយជាមួយពួកគេ នៅពេលដែលពួកគេកំពុងផ្តល់ភ័ស្តុតាង។




ការតម្លើង**ផ្ទាំងសំពត់សាររក្សាឯកជនភាពជនរងគ្រោះ**នៅក្នុងតុលាការមួយនៅប្រទេសអាល្លឺម៉ង់ ដោយសារគ្មានបរិក្ខារទូរទស្សន៍ក្រោមការត្រួតពិនិត្យ។ មន្ត្រីតុលាការកំពុងតម្លើង "ផ្ទាំងសំពត់សរក្សាឯកជនភាព" នៅក្នុងតុលាការ ដើម្បីទប់ស្កាត់ជនត្រូវចោទពីការបំភិតបំភ័យសាក្សី និងធានាថា សាក្សីអាចផ្តល់ភស្តុតាងដោយមិនចាំបាច់សម្លឹងមើលទៅកាន់ជនត្រូវចោទ។

១៤ https://www.gov.uk/government/news/new-courtroom-protections-for-vulnerable-victims-available-nationwide

**ការផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីវិធានការពិសេសៗដែលមាន** - *កញ្ចប់ឧបករណ៍ផ្លូវច្បាប់សម្រាប់សាក្សី*[១៥] របស់ប្រទេសសឹង្ហបុរីចែងលម្អិតអំពី របៀបដែលតុលាការសឹង្ហបុរីអាចអនុវត្ត "វិធានការបិទបាំង" ដើម្បីការពារសាក្សីងាយរងគ្រោះដោយជួយឱ្យសាក្សីផ្តល់ភ័ស្តុតាងតាមរយៈតំណភ្ជាប់វីដេអូ ឬដោយដាក់ផ្ទាំងសំពត់នៅរវាងសាក្សី និងជនត្រូវចោទ។ សាក្សីចាំបាច់ត្រូវដឹងអំពីវិធានការទាំងនេះតាំងពីដំបូង ដើម្បីឱ្យពួកគេអាចស្នើឱ្យមានការប្រើប្រាស់វិធានការទាំងនេះសម្រាប់ពួកគេ។


Witness Support Programme
Giving evidence through video-link
Use of "shielding measures"

*កញ្ចប់ឧបករណ៍ផ្លូវច្បាប់សម្រាប់សាក្សី*

**របាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ** - សាស្ត្រាចារ្យ Paul Cassell មកពីសហរដ្ឋអាមេរិកនិយាយនៅក្នុងវីដេអូ YouTube នេះអំពី របៀបដែលរបាយការណ៍អំពីផលប៉ះពាល់អាចផ្តល់ដល់ជនរងគ្រោះនូវឱកាស ដើម្បីឆ្លើយតបចំពោះជនត្រូវចោទ ដើម្បីប្រាប់តុលាការអំពីរបៀបដែលបទល្មើសនេះមានឥទ្ធិពលលើជីវិតរបស់ពួកគេ ហើយក្នុងករណីខ្លះ ចម្លើយរបស់ជនរងគ្រោះត្រូវបានផ្តល់តាមវិធី "ការបិទជិត"។ វាគឺជាមធ្យោបាយនៃការធានាថាមតិ និងចម្លើយរបស់ ជនរងគ្រោះត្រូវបានពិចារណានៅក្នុងដំណើរការព្រហ្មទណ្ឌ។




https://www.youtube.com/watch?v=UtGr6p81VBE

**មគ្គុទ្ទេសក៍ចំពោះរបាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ សម្រាប់ជនរងគ្រោះនៃបទល្មើស**[១៦] - រដ្ឋាភិបាលរដ្ឋ New South Wales របស់ប្រទេសអូស្ត្រាលីបានបង្កើតសៀវភៅមគ្គុទ្ទេសក៍ ដើម្បីជួយជនរងគ្រោះនៃបទល្មើសក្នុងការរៀបចំ "របាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ" ដែលចៅក្រមអាន បន្ទាប់ពីជនល្មើសត្រូវបានផ្តន្ទាទោស និងមុនពេលនៃការចេញសាលក្រម។ របាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះប្រាប់តុលាការអំពី របៀបដែលបទល្មើសមួយមានផលប៉ះពាល់លើជនរងគ្រោះ ហើយវាផ្តល់ឱកាសដល់ជនរងគ្រោះដើម្បីនិយាយអំពី របៀបដែលបទល្មើសនេះបានជះឥទ្ធិពលលើពួកគេ៖ ផ្នែកហិរញ្ញវត្ថុ ផ្លូវចិត្ត និងផ្លូវកាយ។


Victims Services Department of Communities and Justice
NSW GOVERNMENT
Victim impact statements
Guide

*មគ្គុទ្ទេសក៍ចំពោះរបាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ សម្រាប់ជនរងគ្រោះនៃបទល្មើស*

១៥ https://hagar.org.sg/wp-content/uploads/2021/06/General-Legal-Toolkit-Handbook-for-Vulnerable-Witnesses.pdf
១៦ https://victimsservices.justice.nsw.gov.au/documents/victims-rights/charter-of-victims-rights/victim-impact-statement-guide.pdf

**ការប្រើប្រាស់អន្តរការី** - អន្តរការីជួយសាក្សីក្នុងការបង្ហាញអំពី ភ័ស្តុតាងល្អបំផុតរបស់ពួកគេ។ នៅទីក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី អន្តរការី គឺជាមន្ត្រីតុលាការ ដែលបានធ្វើការបណ្តុះបណ្តាលយ៉ាងហ្មត់ចត់ ដើម្បីទទួលបានការទទួលស្គាល់។ តួនាទីរបស់ពួកគេ គឺដើម្បីសម្របសម្រួលទំនាក់ទំនងរវាងសាក្សី និងនគរបាល និងសាក្សី មេធាវី និងអ្នកដទៃទៀតនៅតុលាការនៅក្នុងអំឡុងពេលនៃដំណើរការជំនុំជម្រះព្រហ្មទណ្ឌ។ អន្តរការីមានបទពិសោធន៍សម្របសម្រួលការប្រាស្រ័យទាក់ទងជាមួយនឹងសាក្សីដែលមានភាពយឺតយ៉ាវផ្នែកភាសា បញ្ហាសុខភាពផ្លូវចិត្ត ពិការភាពក្នុងការរៀនសូត្រ បញ្ហាចេះដឹង និងការប៉ះទង្គិចផ្លូវចិត្ត។ អន្តរការី គឺជាអ្នកចូលរួមនៅក្នុងដំណើរការនេះ ដោយគ្មានភាពលម្អៀង និងជាអ្នកដែលផ្តោតលើការជួយដល់ការបង្ហាញភ័ស្តុតាងប្រកបដោយប្រសិទ្ធភាព។ ក្នុងនាមជាមន្ត្រីដែលគ្មានភាពលម្អៀងនៃស្ថាប័នតុលាការ ពួកគេស្ថិតក្រោមច្បាប់ និងត្រូវបានហាមឃាត់ពីការពិភាក្សាអំពីមាតិកានៃភ័ស្តុតាង។


PROCEDURAL GUIDANCE MANUAL (PGM)

INTERMEDIARY PROGRAM
ACT HUMAN RIGHTS COMMISSION


ACT HUMAN RIGHTS COMMISSION
Australian Capital Territory

ACT INTERMEDIARY PROGRAM
INFORMATION FOR FAMILIES AND COMMUNITY

**What is an intermediary?**

An intermediary is a skilled professional trained to make it easier for children to communicate with the police and in the courtroom.

The intermediary gives suggestions to the police and the court about how the child should be asked questions, so the child can understand their questions.

The intermediary is not a support person and 'cannot take anyone's side'. They are only focused on helping better communication with children, when children try to access justice.

**Why do children need intermediaries?**

We know that it is difficult and stressful for our children to talk in police interviews and at court.

Other things can stop a child communicating, like:

- Language Delays
- Mental Health Issues
- Trauma
- Very young age
- Cognitive Issues
- Attention Deficit Hyperactivity Disorder (ADHD)
- Learning Disabilities
- Autism

The intermediary helps children communicate.

**When can I ask for an intermediary for a child?**

If a child you know is going to talk to police in the Sexual Assault and Child Abuse Team (SACAT Team) ask police for an intermediary to help the child tell their story.

Intermediaries can also help children to communicate at court in sexual assault and violence cases.

*សៀវភៅណែនាំអំពី សេចក្តីណែនាំនីតិវិធី*[១៧]

**ការប្រើប្រាស់អ្នកបកប្រែ** - ការងាររបស់អ្នកបកប្រែ គឺចាំបាច់ក្នុងការធានានូវការទទួលបានភាពយុត្តិធម៌ និងភាពស្មើគ្នាផ្នែកនីតិវិធី។ ក្រុមប្រឹក្សាតុលាការអូស្ត្រាលីស្តីពី ពិពិធភាពវប្បធម៌ (JCCD) បានរៀបចំបទដ្ឋានជាតិ សម្រាប់ការធ្វើការងារជាមួយអ្នកបកប្រែនៅតុលាការ និងអង្គជំនុំជម្រះ[១៨] ដើម្បីបង្កើតបទដ្ឋានដែលត្រូវបានស្នើ និងការអនុវត្តល្អបំផុត សម្រាប់ការប្រើប្រាស់អ្នកបកប្រែនៅក្នុងតុលាការអូស្ត្រាលី។


JUDICIAL COUNCIL ON CULTURAL DIVERSITY

Recommended National Standards for
Working with Interpreters in Courts and Tribunals
SECOND EDITION

**ភាពតំណាងផ្លូវច្បាប់របស់ជនរងគ្រោះ** - មានភ័ស្តុតាងបង្ហាញថា ជនរងគ្រោះ ដែលទទួលបានការគាំទ្រឆ្លងកាត់ដំណើរការផ្លូវច្បាប់ កាន់តែទំនងជាចូលរួមនៅក្នុងការផ្តន្ទាទោស និងអាចផ្តល់ភ័ស្តុតាងពេញលេញ និងត្រឹមត្រូវបាន។ ភារកិច្ចរបស់ពួកគេអាចមានចាប់ពីការធ្វើជាអន្តរការីនៅក្នុងអំឡុងពេលនៃការសាកសួរ ដើម្បីផ្តល់ការស្វែងរកមតិគាំទ្រ និងភាពតំណាងនៅទូទាំងដំណើរការផ្លូវច្បាប់ទាំងមូល រួមទាំងការកាត់ទោស និងការអនុវត្តបដិទាន និងសំណង។

១៧ https://hrc.act.gov.au/wp-content/uploads/2020/05/1.-ACT-Intermediary-Procedural-Guidance-Manual-FEBRUARY-2020.pdf

១៨ https://jccd.org.au/wp-content/uploads/2022/05/JCDD-Recommended-National-Standards-for-Working-with-Interpreters-in-Courts-and-Tribunals-second-edition.pdf

សូចនាករ

៣

បុគ្គលិកវិស័យ
យុត្តិធម៌

# សូចនាករ ៣៖ ទំនាក់ទំនង - របៀបដែលមន្ត្រី និងចៅក្រម នៃស្ថាប័នវិស័យយុត្តិធម៌ទំនាក់ទំនងជាមួយជនរងគ្រោះ/សាក្សី

## ទស្សនៈរួម

ដោយគ្មានចំណេះដឹង ជំនាញ និងសមត្ថភាពសមស្រប មន្ត្រី និងចៅក្រមវិស័យយុត្តិធម៌នឹងមិនអាចផ្តល់សេវាសមស្រប សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានឡើយ។ ត្រូវតែផ្តល់ជូនការបណ្តុះបណ្តាលគ្រប់គ្រាន់ចំពោះ នគរបាល ព្រះរាជអាជ្ញា មន្ត្រីតុលាការ អ្នកវិជ្ជាជីវៈវេជ្ជសាស្ត្រ និងនាយកដ្ឋានរដ្ឋាភិបាលពាក់ព័ន្ធអំពី ច្បាប់ និងនីតិវិធី ដើម្បីធានាថា ជនរងគ្រោះទទួលបានភាពយុត្តិធម៌ និងទទួលបានការថែទាំ និងការគោរពយ៉ាងសមស្រប។ ការបណ្តុះបណ្តាលនេះគប្បីផ្តោតលើការការពារសិទ្ធិរបស់ជនរងគ្រោះ និងពិចារណាលើសេចក្តីត្រូវការ អំពី សិទ្ធិមនុស្ស និងបញ្ហាពាក់ព័ន្ធនឹងកុមារ និងយេនឌ័រ។

បន្ថែមលើការបណ្តុះបណ្តាល ដោយគ្មាននីតិវិធីប្រតិបត្តិបទដ្ឋាន បទដ្ឋានសេវា និងក្រមប្រតិបត្តិ ដែលចែងអំពីសេចក្តីរំពឹងទុក និងផលវិបាកចំពោះការរំលោភលើគណនេយ្យភាពវិជ្ជាជីវៈ និងការតាមដាន នៅពេលដែលមានការរំលោភលើលក្ខខណ្ឌទាំងនោះ បុគ្គលិកវិស័យតុលាការអាចបន្តជាមួយនឹងនិទណ្ឌភាព។

## គោលការណ៍

***តើគប្បីអនុវត្តអ្វីខ្លះ?***

៣.១. មានអង្គភាព/បុគ្គលិកពិសេស ដើម្បីដោះស្រាយសំណុំរឿងជួញដូរមនុស្សនៅតុលាការ (អនុសញ្ញា ACTIP មាត្រា ១៦.១)

៣.២. តុលាការគប្បីបង្កើតគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិបទដ្ឋាន (SOPs) សម្រាប់បុគ្គលិកតុលាការ និងចៅក្រមទាំងអស់អំពី របៀបដោះស្រាយសំណុំរឿងជួញដូរមនុស្ស។ SOPs ទាំងនេះគប្បីផ្តោតលើការអនុវត្តដែលយកចិត្តទុកដាក់លើជនរងគ្រោះ និងអភិក្រមដែលយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត។ SOPs គប្បីធានាថា មានការប្រកាន់ខ្ជាប់ខ្ជួនទៅតាមដំណើរការស៊ើបអង្កេតទាំងអស់ ការធ្វើការសម្ភាសចាំបាច់ទាំងអស់ ការប្រមូល និងការដំណើរការភ័ស្តុតាងទាំងអស់ ព្រះរាជអាជ្ញា និងចៅក្រមមានភ័ស្តុតាង និងឯកសារទាំងអស់ ដែលចាំបាច់ ដើម្បីបើកសវនាការសំណុំរឿង ហើយសាក្សីត្រៀមខ្លួនរួច ដើម្បីបន្តនៅពេលជំនុំជម្រះ (អនុសញ្ញា ACTIP មាត្រា ១១.១(ខ) និង ១៤.១០(គ))

៣.៣. តុលាការគប្បីរៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្តជាក់លាក់ និងក្រមប្រតិបត្តិ ដែលចែងអំពីបទដ្ឋានដែលត្រូវរំពឹងទុកពាក់ព័ន្ធនឹងអាកប្បកិរិយារបស់ចៅក្រម និងបុគ្គលិកតុលាការ និងផលវិបាកនៃការបរាជ័យក្នុងការប្រកាន់ខ្ជាប់ទៅតាមបទដ្ឋានទាំងនេះ នៅពេលដោះស្រាយសំណុំរឿងជួញដូរមនុស្ស។ បទដ្ឋានទាំងនេះគប្បីត្រូវបានផ្តល់ជូនជាសាធារណៈ ដូចនៅក្នុងធម្មនុញ្ញសិទ្ធិជនរងគ្រោះ (អនុសញ្ញា ACTIP មាត្រា ១៦.១)

៣.៤. ការបណ្តុះបណ្តាលអំពីអំពើជួញដូរមនុស្ស ដែលចៅក្រម និងបុគ្គលិកតុលាការទាំងអស់ទទួលបានត្រូវបានផ្អែកលើអភិក្រមដែលយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត និងត្រូវបានបញ្ចូលនៅក្នុងការផ្តល់ការទទួលស្គាល់ និងកម្មវិធីបណ្តុះបណ្តាលតុលាការ ដែលមានស្រាប់ (អនុសញ្ញា ACTIP មាត្រា ១៦.៦)

## ឧទាហរណ៍៖

**ការប្រព្រឹត្តចំពោះជនរងគ្រោះដោយសេចក្តីសេចក្តីថ្លៃថ្នូ និងការគោរព** - ចៅក្រមមានតួនាទីបង្កលក្ខណៈ និងបង្កើតបរិយាកាស សម្រាប់ការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការរបស់ពួកគេ។ អ្នកគ្រប់គ្នាដែលមានវត្តមាននៅតុលាការ មានសិទ្ធិចំពោះការឆ្លើយតបក្នុងវិធីមួយ ដោយគោរពសេចក្តីថ្លៃថ្នូរជាមនុស្ស និងសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ។ ច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រទេសមួយចំនួនចែងថា ការគិតគូរ និងការយកចិត្តទុកដាក់បន្ថែមគប្បីត្រូវបានអនុវត្ត នៅពេលដែលសាក្សីមានវ័យក្មេង និង/ឬបានរងឥទ្ធិពលអវិជ្ជមាន ឬការប៉ះទង្គិចផ្លូវចិត្តពីបទល្មើសពាក់ព័ន្ធ។ ឧទាហរណ៍ ផ្នែក ១៩ នៃក្រមប្រតិបត្តិ របស់សឹង្ហបុរី សម្រាប់ការរៀបចំដំណើរការព្រហ្មទណ្ឌ[១៩]៖

**ក្រមនៃការអនុវត្ត សម្រាប់ការរៀបចំដំណើរការព្រហ្មទណ្ឌដោយព្រះរាជអាជ្ញា និងមេធាវីការពារចុងចោទ**

១៩. ការគិតគូរ និងការយកចិត្តទុកដាក់បន្ថែមគប្បីត្រូវបានធ្វើ នៅពេលសាក្សីមានវ័យក្មេង និង/ឬបានរងឥទ្ធិពលអវិជ្ជមាន ឬការប៉ះទង្គិចផ្លូវចិត្តពីបទល្មើសពាក់ព័ន្ធ។ នៅពេលសាក្សី គឺជាកុមារ ឬយុវជនម្នាក់ ដូចការកំណត់នៅក្រោមច្បាប់ស្តីពីកុមារ និងយុវជន (Cap 38) ព្រះរាជអាជ្ញា និងមេធាវីការពារចុងចោទគប្បីសម្ភាសន៍កុមារដោយមានវត្តមានរបស់អ្នក គាំទ្រកុមារ ឬមន្ត្រីកិច្ចការពារកុមារ នៅពេលដែលអាចអនុវត្តបាន។ អ្នកគាំទ្រកុមារ និងមន្ត្រីកិច្ចការពារកុមារគប្បីទទួលបានការអនុញ្ញាតឱ្យស្នើសុំការឈប់សម្រាកនៅក្នុងអំឡុងពេលនៃកិច្ចសម្ភាស ប្រសិនបើពួកគេគិតថា សាក្សីត្រូវការការសម្រាក។

**គោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិបទដ្ឋាន** – ការកំណត់អំពីការទទួលខុសត្រូវធានាថា មានការយល់ច្បាស់អំពី សេចក្តីរំពឹងទុកពីចៅក្រម បុគ្គលដែលត្រូវបានទទួលស្គាល់ដោយច្បាប់និងបុគ្គលិកតុលាការ។ ឧទាហរណ៍ពីរខាងក្រោមគឺជាដំណកស្រង់ពីកញ្ចប់ឧបករណ៍នៃកម្មវិធីពង្រឹងតុលាការនៅតំបន់ប៉ាស៊ីហ្វិកដែលត្រូវបានរៀបចំឡើង សម្រាប់តុលាការនៅក្នុងប្រជាជាតិប៉ាស៊ីហ្វិក[២០] ដែលបង្ហាញនូវរបៀបដែលអាចលើកឡើងយ៉ាងច្បាស់អំពីការទទួលខុសត្រូវ។

### ការទទួលខុសត្រូវរបស់ចៅក្រម និងបុគ្គលដែលត្រូវបានទទួលស្គាល់ដោយច្បាប់

**ទស្សនៈរួម**..............................................................................................

- ចៅក្រម/បុគ្គលដែលត្រូវបានទទួលស្គាល់ដោយច្បាប់ទទួលខុសត្រូវចំពោះការធានាថា ជនរងគ្រោះ និងសាក្សីនៃអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទមានអារម្មណ៍ទទួលបានការគាំទ្រ និងកិច្ចការពារពីតុលាការនៅក្នុងអំឡុងពេលនៃដំណើរការតុលាការ ដើម្បីឱ្យពួកគេអាចចូលរួមដោយគ្មានការភ័យខ្លាច ស្របពេលដែលធានានូវភាពយុត្តិធម៌សម្រាប់ចុងចោទផងដែរ។
- ចៅក្រម/បុគ្គលដែលត្រូវបានទទួលស្គាល់ដោយច្បាប់មានការទទួលខុសត្រូវ ដែលពួកគេត្រូវការដើម្បីដោះស្រាយក្នុងលក្ខណៈបុរេសកម្ម ដោយធ្វើការងារយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកតុលាការនៅក្នុងបីដំណាក់កាល៖ មុនពេលសវនការ ក្នុងពេលសវនាការ និងក្រោយសវនាការ/ការវិនិច្ឆ័យ។
- ចៅក្រមមានការទទួលខុសត្រូវចំពោះការបន្តគ្រប់គ្រងលើសំណុំរឿងនេះនៅក្នុងដំណាក់កាលទាំងបី។

សម្រាប់ព័ត៌មានសាវតា និងសេចក្តីណែនាំបន្ថែម សូមមើលកញ្ចប់ឧបករណ៍សិទ្ធិមនុស្សនៃ PJST https://www.fedcourt.gov.au/pjsi/resources/toolkits/Human-Rights-Toolkit.pdf ជាពិសេស ជំពូក ៧

---

១៩ https://www.agc.gov.sg/docs/default-source/newsroom-doucments/media-releases/2013/code-of-practice-for-the-conduct-of-criminal-proceedings---final.pdf

២០ ឧទាហរណ៍ សូមមើលបញ្ជីផ្ទៀងផ្ទាត់ ៤ "នៅពេលជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទមកកាន់តុលាការ" សម្រាប់ប្រធានតុលាការ ចៅក្រម ចៅក្រមជាន់ទាប និងបុគ្គលិកតុលាការ៖ https://www.fedcourt.gov.au/pjsi/resources/toolkits/human-rights/Human-Rights-Toolkit-Amended-May-2021.pdf

គោលការណ៍ណែនាំសម្រាប់បុគ្គលិកតុលាការ កំណត់ការទទួលខុសត្រូវនានារបស់ពួកគេ ដោយប្រើប្រាស់ដំណើរការ "ដែលយកចិត្តទុកដាក់លើជនរងគ្រោះ" និងរួមមានបញ្ជីផ្ទៀងផ្ទាត់មួយ ដើម្បីធានាថា ជនរងគ្រោះ ឬសាក្សីស្ថិតនៅក្នុងស្ថានភាពមានសុវត្ថិភាព នៅពេលដែលពួកគេមកតុលាការ ដែលគេហៅថា "ផែនការសុវត្ថិភាព" ផងដែរ។ បញ្ជីផ្ទៀងផ្ទាត់នានានៅក្នុង SOPs គឺជាឧបករណ៍ដ៏ល្អ ដើម្បីធានាថា មានសេវាទាំងអស់ដែលមានដើម្បីការពារជនរងគ្រោះ និងសាក្សី។[២១]

**សៀវភៅតុលាការ (Benchbooks)** - នៅអូស្ត្រាលី សាលាតុលាការវិចតូរីយ៉ាបានបង្កើតសៀវភៅតុលាការសម្រាប់ចៅក្រម បុគ្គលិកតុលាការ និងអ្នកវិជ្ជាជីវៈផ្លូវច្បាប់ដទៃទៀតប្រើប្រាស់ ហើយសៀវភៅនេះផ្តល់ព័ត៌មាន និងឱវាទបន្ថែមពាក់ព័ន្ធនឹងច្បាប់ និងការអនុវត្តច្បាប់។[២២]

ជនរងគ្រោះនៃបទល្មើសនៅក្នុងបន្ទប់សវនាការ - សាលាចៅក្រមអូស្ត្រាលីក៏បានរៀបចំសៀវភៅតុលាការគ្រប់ជ្រុងជ្រោយមួយ ដែលចែងលម្អិតអំពី ការពិចារណានានាសម្រាប់មន្ត្រីតុលាការ និងបុគ្គលិកតុលាការក្នុងការកម្រិតការប៉ះទង្គិចផ្លូវចិត្តជាថ្មីម្តងទៀតចំពោះជនរងគ្រោះ និងពង្រឹងឱកាសនានា សម្រាប់ភាពល្អប្រសើរឡើងវិញនៅក្រោយពេលរងការប៉ះទង្គិចផ្លូវចិត្ត ដោយមិនប៉ះពាល់ដល់សុចរិតភាពរបស់ប្រព័ន្ធតុលាការព្រហ្មទណ្ឌឡើយ។[២៣]

## ការទទួលខុសត្រូវរបស់បុគ្គលិកតុលាការ

បុគ្គលិកតុលាការមានការទទួលខុសត្រូវរួមគ្នាជាមួយចៅក្រម/បុគ្គលដែលត្រូវបានទទួលស្គាល់ដោយច្បាប់ដើម្បីធានាថាជនរងគ្រោះនិងសាក្សីនៃអំពើហឹង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទមានអារម្មណ៍ទទួលបានការគាំទ្រនិងសុវត្ថិភាព (ផ្លូវកាយ និងផ្លូវចិត្ត) ក្នុងការចូលរួមក្នុងដំណើរការតុលាការដោយគ្មានការភ័យខ្លាច.........................................................................................

សម្រាប់ព័ត៌មានសារតា និងសេចក្តីណែនាំបន្ថែម សូមមើលកញ្ចប់ឧបករណ៍សិទ្ធិមនុស្សនៃ PJST https://www.fedcourt.gov.au/pjsi/resources/toolkits/Human-Rights-Toolkit.pdf ជាពិសេស ជំពូក ៧

### ការត្រៀមលក្ខណៈសម្រាប់សវនាការ

- រក្សាការសម្ងាត់របស់ជនរងគ្រោះ/សាក្សីដោយប្រុងប្រយ័ត្នបំផុត(ជាពិសេសនៅពេលដែលមានទំនាក់ទំនងណាមួយជាមួយជនសង្ស័យសមាជិកគ្រួសាររបស់ជនរងគ្រោះ ឬជនសង្ស័យ ឬសមាជិកដទៃទៀតក្នុងសហគមន៍)។

## ការត្រួតពិនិត្យមើលថាជនរងគ្រោះ/សាក្សីស្ថិតក្នុងស្ថានភាពមានសុវត្ថិភាព

☑ ប្រសិនបើពួកគេនៅបន្តស្ថិតនៅក្នុងបរិយាកាសគ្រួសារ សូមពិចារណាដោយប្រុងប្រយ័ត្នអំពី របៀបទំនាក់ទំនងជាមួយសាក្សី/ជនរងគ្រោះដោយសុវត្ថិភាព (ឧទា. ហៅទៅកាន់ទូរស័ព្ទរបស់ពួកគេ និងពិនិត្យជាមុនថាតើវាមានសុវត្ថិភាព/ជាពេលល្អដែរឬទេសម្រាប់ការជជែកជាមួយពួកគេ)។

☑ សិក្សាអំពី កន្លែងដែលជនរងគ្រោះ/សាក្សីកំពុងរស់នៅ និងតើពួកគេស្ថិតក្នុងស្ថានភាពមានសុវត្ថិភាពដែរឬទេ។ សួរពួកគេ៖

- ☐ តើពួកគេមានអារម្មណ៍មានសុវត្ថិភាពពីជនសង្ស័យ/ អ្នកណាម្នាក់ផ្សេងទៀតនៅជុំវិញខ្លួនរបស់ពួកគេដែរឬទេ
- ☐ តើអ្នកណាម្នាក់បានគំរាមកំហែងប្រើប្រាស់អំពើហិង្សាលើពួកគេដែរឬទេ ចាប់ពីពេលដែលពួកគេដាក់ពាក្យបណ្តឹងទៅកាន់នគរបាល/តុលាការ?
- ☐ ពិភាក្សាជាមួយបុគ្គលនេះអំពី ជម្រើសនានារបស់ពួកគេពាក់ព័ន្ធនឹងកន្លែងដែលកាន់តែមានសុវត្ថិភាព ឬរបៀបធ្វើឱ្យស្ថានភាពបច្ចុប្បន្នរបស់ពួកគេកាន់តែមានសុវត្ថិភាព។ (សូមមើលសេចក្តីណែនាំខាងក្រោមអំពី ការរៀបចំផែនការសុវត្ថិភាព)

### សម្គាល់ ៣៖ បទពិសោធន៍នៅបន្ទប់សវនាការ និងទំនុកចិត្តរបស់សាធារណជន

**ចំណុចសំខាន់ៗសម្រាប់ការពិចារណា៖ ការចូលរួមជាមួយសាក្សី និងជនរងគ្រោះនៃបទល្មើស**

ដឹកនាំដោយឧទាហរណ៍៖ លើកទឹកចិត្តបុគ្គលិកតុលាការឱ្យខិតខំធ្វើឱ្យមានទំនាក់ទំនងច្បាស់លាស់ ដោយការគោរព និងសមស្របជាមួយជនរងគ្រោះ និងភ្ញៀវ។

ទទួលស្គាល់ជនរងគ្រោះ៖ នៅក្នុងករណីសមស្រប សូមពិចារណាផ្តោតចំណាប់អារម្មណ៍ទៅលើជនរងគ្រោះ ដោយរក្សាទំនាក់ទំនងទឹកមុខសមស្រប និងអរគុណជនរងគ្រោះចំពោះការចូលរួមរបស់ពួកគេ។

ពិចារណាអំពីជនរងគ្រោះនៅក្នុងការគ្រប់គ្រងសំណុំរឿង៖ សូមទទួលបានព័ត៌មានអំពី តម្រូវការជាក់លាក់របស់ជនរងគ្រោះ និងពិចារណាអំពី តួនាទីរបស់ពួកគេនៅក្នុងដំណើរការនេះ។

ពិចារណាលើតម្រូវការជាក់លាក់៖ តើជនរងគ្រោះមានតម្រូវការជាក់លាក់ ដែលអាចត្រូវផ្តល់ ដើម្បីពង្រីកការចូលរួមរបស់ពួកគេជាមួយដំណើរការតុលាការដែរឬទេ?

រៀបចំការអនុវត្តដែលយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត៖ ការអនុវត្តដែលយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត គឺជាការអនុវត្តមួយដែលសមស្របចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃសេវាមួយ របៀបនៃការផ្តល់សេវា និងវិធីជាច្រើន ដែលភាពតានតឹងក្នុងចិត្តអាចបង្កការប៉ះទង្គិចផ្លូវចិត្តចំពោះមនុស្ស ដែលសរីរសាស្ត្រ និងចិត្តសាស្ត្ររបស់ពួកគេបានរងបញ្ហារួចហើយ និងមិនអាចគ្រប់គ្រងបាន។ សម្រាប់ព័ត៌មានបន្ថែម សូមមើល ការប៉ះទង្គិចផ្លូវចិត្ត និងច្បាប់។ សាលាតុលាការដំណើរការកម្មវិធីនានា ដើម្បីគាំទ្រមន្ត្រីតុលាការក្នុងការរៀបចំការអនុវត្តដែលយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត។

ដឹង និងពិចារណាប្រើប្រាស់អន្តរការី និងសវនាការក្រោមវិធាននានា៖ សាលាតុលាការបានរៀបចំ វីដេអូអំពីការអនុវត្តល្អៗ ដែលអាចទស្សនាបានតាមប្រព័ន្ធអនឡាញ។

ដឹងអំពីសេវាគាំទ្រ៖ ពិចារណាសួរថា តើមានការប្រើប្រាស់សេវាគាំទ្រដែរឬទេ និងតើបុគ្គលិកតុលាការ ឬមន្ត្រីតុលាការគួរធ្វើសេចក្តីថ្លែងការទូទៅអំពីសេវាគាំទ្រនៅពេលចាប់ផ្តើមសវនាការដែរឬទេ។

កាត់បន្ថយទំនាក់ទំនងរបស់ជនរងគ្រោះជាមួយជនត្រូវចោទ៖ សូមពិចារណាថាតើបុគ្គលិកអាចធ្វើការរៀបចំរូបវន្ត ដើម្បីកាត់បន្ថយទំនាក់ទំនងនេះបានដែរឬទេ។

ដឹង និងពិចារណាប្រើប្រាស់ពិធីសារវប្បធម៌៖
សូមមើល៖ កំណត់ត្រាណែនាំ ៦៖ សារវតាចម្រុះគ្នាផ្នែកវប្បធម៌ និងភាសា។

ពិចារណាលើការប្រើប្រាស់ភាសា៖ ដឹងអំពី ដំណឹង ដែលភាសា និងចំណាត់ការអាចបញ្ជូនទៅដល់ជនរងគ្រោះមកពីសារវតាខុសៗគ្នា។

ដឹងថា តុលាការមិនមែនជាកន្លែងការងាររបស់ជនរងគ្រោះឡើយ៖ យល់ថាជនរងគ្រោះអាចមានប្រតិកម្មផ្លូវចិត្តចំពោះដំណើរការតុលាការ។ ពិចារណាកំណត់សេចក្តីរំពឹងទុកពាក់ព័ន្ធនឹងអាកប្បកិរិយាសមស្របនៅក្នុងតុលាការ និងការឆ្លើយតបចំពោះអ្នកចូលរួមទាំងអស់។

ព្រមានអ្នកសង្កេតការអំពី ភ័ស្តុតាង៖ ភ័ស្តុតាងមួយចំនួនអាចបង្កភាពតានតឹងក្នុងចិត្តជាពិសេសចំពោះជនរងគ្រោះ ដូចជា រូបថត ឬការថតសោតទស្សន៍។ ពិចារណាជូនដំណឹងដល់អ្នកសង្កេតការថា នៅពេលណាដែលអាចមានការបង្ហាញអំពីភ័ស្តុតាង ដែលបង្កភាពតានតឹងក្នុងចិត្ត ដោយពន្យល់អំពីមូលហេតុ ដែលត្រូវតែបង្ហាញភ័ស្តុតាងនោះ និងផ្តល់ឱកាសឱ្យអ្នកសង្កេតការចាកចេញពីបន្ទប់សវនាការជាបណ្តោះអាសន្ន។ អាចអនុញ្ញាតឱ្យមានការផ្អាករយៈពេលខ្លី សម្រាប់ការចាកចេញដោយស្ងាត់ៗ។

**ការពិចារណារបស់តុលាការបែបបើកចំហរ**

ទោះបីជាតុលាការបើកចំហរចំពោះសាធារណជនក្តី មន្ត្រីតុលាការអាចរិតត្បិតចំពោះព័ត៌មានអំពី ជនរងគ្រោះជាក់លាក់ ពីការផ្សព្វផ្សាយជាសាធារណៈ ហើយក្នុងករណីខ្លះ រិតត្បិតចំពោះការចូលទៅកាន់បន្ទប់សវនាការ ដែលបានរៀបចំដើម្បីដោះស្រាយបញ្ហានោះផងដែរ។
ការរិតត្បិតចំពោះព័ត៌មាន គឺជាបញ្ហាចាំបាច់ និងសំខាន់សម្រាប់ជនរងគ្រោះ ជាពិសេស កុមារ ជនមានភាពចេះដឹងខ្សោយ និងជនរងគ្រោះនៃបទល្មើសផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ។ មន្ត្រីតុលាការក៏អាចពិចាណាប្រើប្រាស់ឈ្មោះក្លែងក្លាយសម្រាប់ជនរងគ្រោះ និងសាក្សី និងលុបព័ត៌មានអត្តសញ្ញាណរបស់ពួកគេចេញពីសាលក្រម ឬឯកសារតុលាការសាធារណៈផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពី តុលាការបើកចំហរនៅតុលាការ និងអង្គជំនុំជម្រះវិចតូរីយ៉ា សូមមើល៖

- អំណាចនៃការចេញដីកា ដែលអនុញ្ញាតឱ្យមានតុលាការបើកចំហរ - សៀវភៅសម្រាប់តុលាការបើកចំហរ និង
- សវនាការបញ្ជូនសំណុំរឿង និងគោលការណ៍នៃតុលាការបើកចំហរ - សៀវភៅណែនាំស្តីពី ដំណើរការក្តីព្រហ្មទណ្ឌវិចតូរីយ៉ា។

កំណត់ត្រាណែនាំ ៦- ១៤ មានព័ត៌មានលម្អិតបន្ថែមអំពី ជំហាននានា ដែលតុលាការអាចធ្វើ ដើម្បីជួយជនរងគ្រោះ ដែលមានតម្រូវការចម្រុះ រួមមានកុមាររងគ្រោះ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងជនរងគ្រោះដែលមានសារវតាចម្រុះគ្នាផ្នែកវប្បធម៌ និងភាសា រួមទាំងជនជាតិដើម ( Aboriginal and Torres Strait Islander)។

---

[២១] https://worldjusticeproject.org/sites/default/files/documents/PJSI%20-%20Human%20Rights%20Checklists.pdf

[២២] See for example: https://www.judicialcollege.vic.edu.au/resources

[២៣] https://www.judicialcollege.vic.edu.au/resources/victims-and-witnesses

**"អ្វីដែលយើងអាច និងមិនអាចធ្វើបាន"** - នៅឥណ្ឌូនេស៊ី និងអូស្ត្រាលី តុលាការបានកំណត់អំពីអ្វីដែលបុគ្គលិករដ្ឋបាលតុលាការអាចធ្វើបានចំពោះគូក្តី សាក្សី និងអតិថិជនរបស់តុលាការ។ ឯកសារប្រភេទនេះធ្វើឱ្យមានការបង្ហាញយ៉ាងច្បាស់អំពីសិទ្ធិរបស់ជនរងគ្រោះ/សាក្សី និងអ្វីដែលពួកគេអាចរំពឹងថា នឹងទទួលបានពីតុលាការ និងបុគ្គលិកតុលាការ និងការទទួលខុសត្រូវរបស់តុលាការ។[២៤]




**ធម្មនុញ្ញនៃសិទ្ធិជនរងគ្រោះ** គឺជាវិធីល្អបំផុតក្នុងការកំណត់សិទ្ធិរបស់ជនរងគ្រោះ និងសាក្សី និងជួយពួកគេឱ្យមើលឃើញថា តុលាការគិតពិចារណាលើតម្រូវការរបស់ពួកគេយ៉ាងហ្មត់ចត់។ ឧទាហរណ៍ពីប្រទេសកាណាដា កំណត់សិទ្ធិសំខាន់ៗចំនួនបួនរបស់ជនរងគ្រោះ៖ ព័ត៌មាន កិច្ចការពារ ការចូលរួម និងបដិទាន ព្រមទាំងសិទ្ធិរបស់ពួកគេក្នុងការដាក់បណ្តឹងចំពោះការរំលោភ ឬការបដិសេធសិទ្ធិរបស់ពួកគេនៅក្រោមធម្មនុញ្ញនេះ។ ធម្មនុញ្ញនេះមានរួចហើយសំរាប់សាធារណជន និងត្រូវបានបោះពុម្ពផ្សាយនៅលើគេហ៍ទំព័ររបស់តុលាការ។[២៥]




២៤ ឧទាហរណ៍ សូមមើល តុលាការសាសនានៃមេដាន ប្រទេសឥណ្ឌូនេស៊ី - https://pa-medan.go.id/index.php/kepaniteraan/hak-hak-pencari-keadilan; តុលាការសហព័ន្ធអូស្ត្រាលី - https://www.fcfcoa.gov.au/pubs/can-cannot និងតុលាការដីធ្លី - https://www.lec.nsw.gov.au/lec/coming-to-court/what-court-staff-can-and-can-t-do.html.

២៥ https://crcvc.ca/general_resources/know-your-rights/

សូចនាករ

៤

ព័ត៌មាន និង សេវា

i

## សូចនាករ ៤៖ ព័ត៌មាន និងសេវាដែលត្រូវផ្តល់ដល់ជនត្រូវបានជួញដូរ នៅពេលដែលពួកគេមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ផ្លូវការ

### ទស្សនៈរួម

ការទទួលបានព័ត៌មាន គឺជាចំណុចចាប់ផ្តើមយ៉ាងសំខាន់ សម្រាប់ការចូលរួមរបស់ជនរងគ្រោះដោយអំពើជួញដូរនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ហេតុនេះ ស្ថាប័នយុត្តិធម៌ទាំងអស់ រួមទាំងតុលាការ ចាំបាច់ត្រូវមានវិធានការនានា ដែលផ្តល់ព័ត៌មានដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពី តុលាការពាក់ព័ន្ធ និងដំណើរការនីតិវិធីរដ្ឋបាល និងផ្តល់ជំនួយ ដើម្បីជួយឱ្យមានការបង្ហាញ និងការពិចារណាអំពីទស្សនៈ និងកង្វល់របស់ពួកគេនៅដំណាក់កាលសមស្របនៃដំណើរការព្រហ្មទណ្ឌ។[២៦]

- នៅពេលដែលអាចធ្វើបាន ក្នុងតួនាទីដឹកនាំរបស់ខ្លួន ចៅក្រមគប្បីរៀបចំកិច្ចការក្រោមយុត្តិធិការរបស់ពួកគេ៖[២៧]

- ជនរងគ្រោះ និងសាក្សីទទួលបានព័ត៌មាន និងសម្ភារដែលមិនប្រើប្រាស់ពាក្យពេជន៍ច្បាប់ ពាក់ព័ន្ធនឹងសិទ្ធិរបស់ពួកគេ រួមទាំងព័ត៌មានអំពី៖[២៨]
    - ដំណើរការជំនុំជម្រះ
    - ទ្រង់ទ្រាយរូបវ័ន្តនៃតុលាការ/បន្ទប់សវនាការ
    - សោហ៊ុយសម្រាប់សាក្សី ប្រសិនបើមាន
    - មូលនិធិសំណង/ឧបាស្រ័យ
    - ជំនួយហិរញ្ញវត្ថុដែលមានចំពោះពួកគេ ដើម្បីជួយពួកគេសម្រេចបានសិទ្ធិរបស់ពួកគេក្នុងការទទួលបានឧបាស្រ័យគ្រប់គ្រាន់ និងសមស្រប។
- បង្កើតកន្លែងទទួល/ជនបង្គោល ដើម្បីផ្តល់ព័ត៌មានដល់ជនរងគ្រោះ និងសាក្សីអំពី សេវាសាធារណៈ និងសេវាសហគមន៍ដែលមានសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ រួមមានអន្តរាគមន៍វិបត្តិ ការពិគ្រោះយោបល់ និងសេវាគាំទ្រដទៃទៀតសម្រាប់ជនរងគ្រោះ។
- ធានាថា ជនរងគ្រោះ និងសាក្សីទទួលបានការ គួរសម ការគោរព និងភាពយុត្តិធម៌គ្រប់ពេល។

ចៅក្រមចាំបាច់ត្រូវយល់ថា ជនត្រូវបានជួញដូរមានសិទ្ធិតាមផ្លូវច្បាប់ជាអន្តរជាតិក្នុងការទទួលបានឧបាស្រ័យគ្រប់គ្រាន់ និងសមស្រប។ ជាញឹកញាប់ សិទ្ធិនេះមិនបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសម្រាប់ជនត្រូវបានជួញដូរឡើយ ដោយសារពួកគេរមែងតែងខ្វះព័ត៌មានអំពី លទ្ធភាព និងដំណើរការ សម្រាប់ការទទួលបានសំណង។ នៅពេលអាចធ្វើបាន ចៅក្រមគប្បីធានាថា ជនរងគ្រោះដាក់ពាក្យស្នើសុំឧបាស្រ័យ និងមានការដោះស្រាយចំពោះការស្នើសុំនៅក្នុងពេលជំនុំជម្រះ។

---

២៦ សូមមើល៖ ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាសហប្រជាជាតិប្រឆាំងអង្គការឧក្រិដ្ឋកម្មឆ្លងដែន។ ប្រទេសវៀតណាមបានយល់ព្រមចំពោះអនុសញ្ញានេះនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២។

២៧ UNODCCP, Handbook on Justice for Victims. .https://www.unodc.org/pdf/criminal_justice/UNODC_Handbook_on_Justice_for_victims.pdf

២៨ រដ្ឋមួយចំនួនបានកំណត់ភារកិច្ចផ្លូវច្បាប់របស់អាជ្ញាធារ ដែលពាក់ព័ន្ធនៅក្នុងដំណើរការព្រហ្មទណ្ឌ ដើម្បីផ្តល់ព័ត៌មានដល់ជនរងគ្រោះនៃបទល្មើស។ អត្ថប្រយោជន៍មួយនៃអភិក្រមបែបនេះ គឺ វាលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីអំពីការទទួលខុសត្រូវរបស់ពួកគេចំពោះជនរងគ្រោះ។

## គោលការណ៍
### *តើគប្បីអនុវត្តអ្វីខ្លះ?*

៤.១. តុលាការគប្បីផ្តល់ព័ត៌មាន និងសម្ភារសមស្របក្នុងទម្រង់ចម្រុះគ្នាសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានលក្ខណៈសាមញ្ញៗ គ្មានពាក្យពេជន៍ច្បាប់ និងជាភាសា ដែលពួកគេអាចយល់បាន[២៩] ពាក់ព័ន្ធនឹង៖

- ក) តើអំពើជួញដូរមនុស្សគឺជាអ្វី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ រួមទាំងទីតាំងផ្លូវច្បាប់របស់ជនរងគ្រោះ សិទ្ធិរបស់ពួកគេ ជម្រើសរបស់ពួកគេ (ចូលរួម ឬមិនចូលរួម) សេវាគាំទ្រដែលមានសម្រាប់ជនរងគ្រោះ និងពេលវេលាតាមការប៉ាន់ស្មាននៃការជំនុំជម្រះក្តីជួញដូរមនុស្ស (អនុសញ្ញា ACTIP មាត្រា ១៤.៩ និង ១៤.១០(ខ))
- ខ) គោលការណ៍មិនដាក់ទណ្ឌកម្ម ដើម្បីឱ្យជនរងគ្រោះយល់ថា ពួកគេនឹងមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬរដ្ឋបាលចំពោះសកម្មភាពខុសច្បាប់ ដែលពួកគេបានប្រព្រឹត្តឡើយ ប្រសិនបើសកម្មភាពទាំងនោះមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងអំពើជួញដូរមនុស្ស (អនុសញ្ញា AC-TIP មាត្រា ១៤.៧)
- គ) សិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងការស្វែងរកបដិទាន/ សំណង (ប្រសិនបើមាន) សម្រាប់ការបាត់បង់ និងការប៉ះទង្គិចផ្លូវចិត្ត ព្រមទាំងដំណើរការដាក់ពាក្យសុំ[៣០] (អនុសញ្ញា AC-TIP មាត្រា ១៤.១៣)

៤.២. តុលាការបានចាត់តាំងជនបង្គោល/អ្នកគ្រប់គ្រងករណី/អ្នកសម្របសម្រួលសាក្សីជនរងគ្រោះដែលនឹងបន្តទំនាក់ទំនងជាមួយជនរងគ្រោះ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពី ស្ថានភាពនៃសំណុំរឿង និងផ្តល់ព័ត៌មានអំពីការបញ្ជូនទៅរកសេវាគាំទ្រជនរងគ្រោះ ដែលមានសម្រាប់ពួកគេ (អនុសញ្ញា ACTIP មាត្រា ១៦.១)

## ឧទាហរណ៍៖

**ការទប់ស្កាត់ភាពរងគ្រោះជាលើកទីពីរនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ** - បន្ទប់សវនាការអាចជាកន្លែងដែលគួរឱ្យភ័យខ្លាចសម្រាប់ជនរងគ្រោះ។ តុលាការព្រហ្មទណ្ឌ នីតិវិធី និងការជំនុំជម្រះអាចមានលក្ខណៈផ្លូវការ និងតាមបែបប្រពៃណី។ ចៅក្រមមានឱកាសកាន់តែច្រើនក្នុងការកាត់បន្ថយភាពថប់បារម្ភរបស់ជនរងគ្រោះ ប្រសិនបើចៅក្រមយល់អំពី របៀបនៃការរៀបចំ និងការអនុវត្តរបស់ខ្លួនដែលជាការរួមចំណែកបង្កើត ស្ថានភាពគ្មានផាសុកភាព ដែលអាចឲជនរងគ្រោះប្រឈមមុខ នឹងភាពរងគ្រោះជាលើកទីពីរ។

តារាងខាងក្រោមផ្តល់នូវសេចក្តីសង្ខេបអំពីកត្តា ឬទិដ្ឋភាពនានាអំពីបែបបទនៃការជំនុំជម្រះព្រហ្មទណ្ឌ ដែលរួមចំណែកបង្កើត ស្ថានភាពគ្មានផាសុកភាពសម្រាប់ជនរងគ្រោះ។ តារាងនេះបង្ហាញថា កត្តាជាច្រើនក្នុងចំណោមកត្តាទាំងនេះ ដែលរួមចំណែកចំពោះការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ ទំនងជាមិនអាចជៀសវាងបានឡើយ ឧទា. ជនរងគ្រោះត្រូវតែពណ៌នាប្រាប់មនុស្សដែលពួកគេមិនសូវស្គាល់ ឬមិនស្គាល់ទាល់តែសោះ អំពីព័ត៌មានលម្អិតនៃអំពើហិង្សា។ មេធាវីការពារចុងចោទត្រូវតែមានឱកាស ដើម្បីសួរសំណួរអ្នកប្តឹង។ ទោះបីជាយ៉ាងណាក្តី របៀបរបបមួយចំនួននៃការជំនុំជម្រះ ឬទិដ្ឋភាពមួយចំនួននៃរបៀបរបបទាំងនេះ មិនមានភាពចាំបាច់ឡើយ។

---

២៩ ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅតែមានភាពងាយរងគ្រោះខ្លាំង នៅពេលសេវាដែលពួកគេទទួលបាន មានភាសាដែលពួកគេមិនអាចយល់បាន។ ការពិចារណាផ្នែកភាសា និងវប្បធម៌ គឺជាកត្តាយ៉ាងសំខាន់នៅក្នុងការផ្តល់សេវា និងការផ្តល់ព័ត៌មាន។ សេវានានា ដែលត្រូវបានផ្តល់រួមជាមួយនឹងមន្ត្រីទំនាក់ទំនងមកពីក្រុមវប្បធម៌ និងភាសារបស់ជនរងគ្រោះ ផ្តល់ឱកាសឱ្យជនរងគ្រោះទទួលបានការយល់ដឹងកាន់តែច្បាស់អំពី ដំណើរការការិយាធិបតេយ្យ ដែលពួកគេត្រូវឆ្លងកាត់។ ក្នុងករណីជាច្រើន ការផ្តល់សេវាបកប្រែរបស់អ្នកបកប្រែដែលមានភេទដូចគ្នាជាមួយជនរងគ្រោះអាចមានសារសំខាន់។

៣០ ដោយអនុលោមទៅតាមគោលការណ៍ ៨ ដល់ ១៣ នៃសេចក្តីប្រកាសអំពី គោលការណ៍មូលដ្ឋាននៃភាពយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទល្មើស និងការបំពានអំណាច (សេចក្តីសម្រេចនៃមហាសន្និបាត 40/34 ឧបសម្ព័ន្ធ) សំណងគប្បីរួមមានការប្រគល់ទ្រព្យត្រលប់មកវិញ ឬការទូទាត់ចំពោះគ្រោះថ្នាក់ ឬការបាត់បង់ ការសងចំពោះការចំណាយដែលកើតចេញពីភាពរងគ្រោះ ការផ្តល់សេវា និងការស្តារសិទ្ធិឡើងវិញ។ នៅពេលដែលគ្មានសំណងពីជនល្មើស ឬប្រភពដទៃទៀត រដ្ឋទាំងឡាយគប្បីប្រឹងប្រែងផ្តល់សំណងហិរញ្ញវត្ថុដល់ជនរងគ្រោះ គ្រួសាររបស់ពួកគេ ឬអ្នកក្នុងបន្ទុក (ក្នុងករណីជនរងគ្រោះស្លាប់) សូមមើល៖ www.un.org/documents/ga/res/40/a40r034.htm and Office of the High Commissioner for Human Rights, Recommended Principles and Guidelines on Human Rights and Human Trafficking. P11

**ព័ត៌មានអំពីដំណើរការជំនុំជម្រះ** - ព័ត៌មានអំពីដំណើរការជំនុំជម្រះគប្បីត្រូវបានរៀបចំឡើងក្នុងទម្រង់ជាច្រើន ឧទាហរណ៍ តាមរយៈវីដេអូ នៅលើគេហ៍ទំព័រ បណ្តាញទំនាក់ទំនងសង្គម ជាដើម ព្រមទាំងព័ត៌មាននៅក្នុងទម្រង់បោះពុម្ព។ ជាញឹកញាប់ វិស័យយុត្តិធម៌រៀបចំសម្ភារនេះ រួមជាមួយនឹងសេវាគាំទ្រជនរងគ្រោះ។ សម្ភារដែលត្រូវបានបោះពុម្ព ត្រូវបានផ្តល់ដល់សេវាគាំទ្រ និងអង្គការមិនមែនរដ្ឋាភិបាលនានា ហេតុនេះ ជនរងគ្រោះមានព័ត៌មានអំពីដំណើរការជំនុំជម្រះព្រហ្មទណ្ឌតាំងពីដំបូង។ ព័ត៌មាននេះគប្បីមានក្នុងទម្រង់ខុសៗគ្នា និងជាភាសាជាច្រើន ដើម្បីបំពេញទៅតាមតម្រូវការរបស់ជនរងគ្រោះ និងសាក្សីទាំងអស់។




**វីដេអូតាមប្រព័ន្ធអនឡាញអំពី តួនាទីរបស់សាក្សីនៅក្នុងសំណុំរឿងមួយ** - បង្កើតឡើងដោយតុលាការនៅប្រទេសថៃ ដើម្បីផ្តល់ព័ត៌មានដល់សាក្សី និងកាត់បន្ថយការភ័យខ្លាច ដែលពួកគេអាចមានពាក់ព័ន្ធនឹងការចូលរួមទៅកាន់តុលាការ។ វីដេអូនេះត្រូវបានបញ្ជូនតាមរយៈទំព័រហ្វេសបុករបស់ពួកគេ។[៣២]



**ព័ត៌មានសម្រាប់ជនរងគ្រោះនៃបទល្មើសដែលទៅកាន់តុលាការ** - ដំណើរការយុត្តិធម៌ ដែលបង្កើតឡើងដោយតុលាការនៃរដ្ឋ New South Wales ប្រទេសអូស្ត្រាលី៖ កម្រងនៃវីដេអូចំនួន ១០ នៅលើ YouTube ដើម្បីជួយជនរងគ្រោះនៃបទល្មើស នៅពេលទៅកាន់តុលាការនៅរដ្ឋ New South Wales ប្រទេសអូស្ត្រាលី។ វីដេអូនេះបង្ហាញអំពី ទ្រង់ទ្រាយរបស់តុលាការ វាពន្យល់អំពី ដំណើរការនៃការជំនុំជម្រះ និងទស្សនទានសំខាន់ៗ ដូចជា ភស្តុតាងចម្បង ការសាកសួរពីភាគីបដិបក្ខ និងការត្រួតពិនិត្យឡើងវិញ។[៣៣]




**ក្រសួងយុត្តិធម៌ (ចក្រភពអង់គ្លេស)**៖ ដោយមើលឃើញតាមរយៈការយល់ឃើញរបស់សាក្សី ភាពយន្តជីវចលនេះពន្យល់អំពី អ្វីដែលត្រូវរំពឹងពី ដំណើរការតុលាការទាំងមូល និងបង្ហាញពីដំណើររបស់ស្ត្រីវ័យក្មេងម្នាក់ចាប់ពីការផ្តល់សេចក្តីថ្លែង ទៅទូទាំងដំណើរការតុលាការព្រហ្មទណ្ឌ និងបន្ទាប់ពីការជំនុំជម្រះ។ វាក៏ពន្យល់អំពីសេវាពិសេសៗដែលត្រូវបានផ្តល់ ដូចជា បន្ទប់រងចាំដោយឡែក ភស្តុតាងជាវីដេអូ ការគាំទ្រសាក្សី/អ្នកគ្រប់គ្រងករណី។ល។[៣៤]

---
៣២ https://www.facebook.com/watch/?v=261359598249050
៣៣ https://www.youtube.com/watch?v=2tgMHlHyiuE
៣៤ https://www.youtube.com/watch?v=t8gMFYl6Nm4

**ព័ត៌មានសម្រាប់ជនរងគ្រោះ និងសាក្សី** - ការទៅកាន់តុលាការ គឺជាការពិបាក សម្រាប់សាក្សី និងជនរងគ្រោះ។ ពួកគេចាំបាច់ត្រូវទទួលបានព័ត៌មានទាំងអស់ ដែលពួកគេត្រូវការ អំពី ដំណើរការរបស់តុលាការ។ តុលាការមណ្ឌល និងតុលាការគ្រួសាររបស់រដ្ឋសហព័ន្ធ ផ្តល់កញ្ចប់ព័ត៌មានដល់អ្នកស្វែងរកភាពយុត្តិធម៌ទាំងអស់ ដែលគ្មានអ្នកតំណាងផ្លូវច្បាប់។ ឯកសារនេះ (មានជាច្រើនភាសា) ផ្តល់ព័ត៌មានលម្អិតអំពី របៀបត្រៀមលក្ខណៈសម្រាប់តុលាការ អ្វីដែលត្រូវស្លៀកពាក់ សុវត្ថិភាពផ្ទាល់ខ្លួន អ្វីដែលត្រូវធ្វើនៅពេលទៅដល់តុលាការ ពាក្យពេចន៍ទូទៅដែលត្រូវប្រើប្រាស់នៅតុលាការ អ្វីដែលមិនត្រូវធ្វើនៅក្នុងបន្ទប់សវនាការ និងរបៀបនិយាយជាមួយចៅក្រម។ វាក៏ផ្តល់ព័ត៌មានអំពីកន្លែងដើម្បីទៅរកដំបូន្មានផ្លូវច្បាប់ដោយឥតគិតថ្លៃផងដែរ។[៣៥]

**គ្រោងការណ៍ប្រាក់ឧបត្ថម្ភសាក្សី (ការគាំទ្រហិរញ្ញវត្ថុ)** - តាមរយៈគេហទំព័រសាធារណៈរបស់ខ្លួន តុលាការសឹង្ហបុរីផ្តល់ព័ត៌មានលម្អិតអំពី សំណងហិរញ្ញវត្ថុសម្រាប់សាក្សី។ តុលាការនេះផ្តល់បញ្ជីផ្ទៀងផ្ទាត់ និងការពន្យល់អំពី របៀបដាក់ពាក្យស្នើសុំ។[៣៦] ទម្រង់នេះមានលក្ខណៈសាមញ្ញណាស់សម្រាប់ការបំពេញ និងព្រះរាជអាជ្ញា និងមេធាវីការពារក្តីណែនាំ និងជួយសាក្សីរបស់ពួកគេក្នុងការដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភ។

ព្រឹត្តិបត្រព័ត៌មាន

FEDERAL CIRCUIT AND FAMILY COURT OF AUSTRALIA

## ការទៅកាន់តុលាការ - គន្លឹះសម្រាប់សវនាការតុលាការរបស់អ្នក

**ព្រឹត្តិបត្រព័ត៌មាន គឺសម្រាប់បុគ្គលទាំងឡាយ ដែលធ្វើតំណាងឱ្យខ្លួនឯងនៅតុលាការ។ វាគ្របដណ្តប់លើកិច្ចការមួយចំនួន ដែលអ្នកអាចធ្វើ ដើម្បីត្រៀមលក្ខណៈសម្រាប់សវនាការតុលាការរបស់អ្នក ព្រមទាំងអ្វីដែលគួរ និងមិនគួរធ្វើនៅក្នុងបន្ទប់សវនាការ។**

### ការត្រៀមខ្លួនឱ្យរួចរាល់

សូមត្រៀមលក្ខណៈ និងត្រៀមខ្លួនរួចរាល់ ដើម្បីបង្ហាញសំណុំរឿងរបស់អ្នកនៅថ្ងៃដែលអ្នកចូលរួមនៅក្នុងសវនាការតុលាការ។ សូមធ្វើការស្រាវជ្រាវឱ្យច្រើនតាមអាចធ្វើបាន និងប្រមូលព័ត៌មានទាំងអស់ សម្រាប់សំណុំរឿងរបស់អ្នក។

សូមប្រាកដថា អ្នកមានឯកសារទាំងអស់របស់អ្នកដែលមានការរៀបចំយ៉ាងច្បាស់ និងគំនូសសម្គាល់លើឯកសារនានា ដែលអ្នកបានដាក់ជូនតុលាការរួចហើយ។ សូមយកសៀវភៅកត់ត្រា និងប៊ិចទៅជាមួយអ្នកផងដែរ។

មនុស្សមួយចំនួនគិតថា ការអង្គុយនៅក្នុងបន្ទប់សវនាការនៅមុនពេលសវនាការ អាចជួយសម្រាលសំពាធបាន ប្រសិនបើអ្នកមិនធ្លាប់ទៅតុលាការពីមុនមក។ សវនាការតុលាការមួយចំនួនត្រូវបានរៀបចំឡើងនៅក្នុងតុលាការបើកចំហ ហេតុនេះអ្នកអាចធ្វើបែបនេះបានគ្រប់ពេល។

### អ្វីដែលត្រូវស្លៀកពាក់

គ្មានវិធានច្បាប់អំពី អ្វីដែលត្រូវស្លៀកពាក់នៅតុលាការឡើយ។ ប៉ុន្តែតុលាការ គឺជាកន្លែងផ្លូវការមួយ ហើយអ្នកគប្បីស្លៀកពាក់លក្ខណៈផ្លូវការទៅតាមនោះដែរ។

### កុមារនៅតុលាការ

ជាទូទៅ តុលាការមិនមែនជាកន្លែងសមស្របសម្រាប់កុមារឡើយ។ សូមរៀបចំសម្រាប់ការថែទាំកូនរបស់អ្នកនៅពេលអ្នកទៅតុលាការ។

ប្រសិនបើកូនរបស់អ្នកត្រូវចូលរួមនៅក្នុងតុលាការ ដើម្បីនិយាយជាមួយអ្នកជំនាញផ្នែកកុមារនៅតុលាការ ឬមន្ត្រីតុលាការ សូមសាកសួរបុគ្គលិកនៅតុលាការ នៅមុនពេលនៃការណាត់ជួបជាមួយតុលាការរបស់អ្នកថា តើត្រូវរៀបចំការថែទាំកុមារនៅថ្ងៃនោះដែរឬទេ។

### សុវត្ថិភាពផ្ទាល់ខ្លួន

ប្រសិនបើអ្នកមានកង្វល់ណាមួយអំពី សុវត្ថិភាពរបស់អ្នក នៅពេលចូលរួមនៅតុលាការ សូមហៅទូរស័ព្ទទៅកាន់ ១៣០០ ៣៥២ ០០០ នៅមុនពេលនៃការណាត់ជួបនៅតុលាការ ឬ សវនាការតុលាការរបស់អ្នក។ ជម្រើសសម្រាប់សុវត្ថិភាពរបស់អ្នកនៅតុលាការនឹងត្រូវពិភាក្សា ហើយការរៀបចំផ្សេងៗនឹងត្រូវបានបង្កើតឡើង។ សូមមើលព្រឹត្តិបត្រព័ត៌មាននេះ តើអ្នកភ័យខ្លាចចំពោះសុវត្ថិភាពរបស់អ្នក នៅពេលចូលរួមនៅតុលាការដែរឬទេ?

### ការទៅដល់តុលាការ

អ្នកអាចបញ្ជាក់ទីតាំង តុលាការ តាមរយៈការចូលទៅកាន់ www.fcfcoa.gov.au/court-locations។ អ្នកគប្បីទៅដល់តុលាការយ៉ាងហោចណាស់ ៣០នាទីមុនពេលកំណត់ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ខ្លួនអ្នកសម្រាប់ដំណើរការលើបញ្ហាសន្តិសុខ ស្វែងរកបន្ទប់សវនាការ។ ប្រសិនបើអ្នកមានបញ្ហាណាមួយក្នុងការស្វែងរកបន្ទប់សវនាការ សូមសួរបុគ្គលិកតុលាការ។

នៅទីតាំងតុលាការភាគច្រើន អាចមានមេធាវីប្រចាំការដើម្បីជួយអ្នកនៅថ្ងៃសវនាការតុលាការរបស់អ្នក។ ជំនួយពីមេធាវីប្រចាំការមានកម្រិតកំណត់ ហើយអ្នកត្រូវតែបំពេញទៅតាមគោលការណ៍ណែនាំជាក់លាក់ ដើម្បីមានសិទ្ធិទទួលបានជំនួយនោះ។

អ្នកអាចនាំសមាជិកគ្រួសារ ឬមិត្តភក្តិរបស់អ្នកម្នាក់ (ដែលមានអាយុលើសពី ១៨ឆ្នាំ) ទៅជាមួយ ដើម្បីអង្គុយជាមួយអ្នក និងផ្តល់ការគាំទ្របាន។ ប្រសិនបើគ្មានការយល់ព្រមពីមន្ត្រីតុលាការទេ បុគ្គលគាំទ្ររបស់អ្នកមិនអាចអង្គុយជាមួយអ្នក បានឡើយ និងមិនអាចនិយាយជំនួសអ្នកបានឡើយ។

ឧបករណ៍ថតមិនទទួលបានការអនុញ្ញាតឱ្យយកចូលបន្ទប់សវនាការ ដោយគ្មានការអនុញ្ញាតពីមន្ត្រីនគរបាលឡើយ។

មុនពេលចូលក្នុងបន្ទប់សវនាការ អ្នកគួរ៖

- បិទគ្រឿងបរិក្ខារអេឡិចត្រូនិច រួមទាំងទូរស័ព្ទដៃ និង
- ដោះមួក ឬវ៉ែនតាខ្មៅចេញ លុះត្រាតែមានមូលហេតុផ្នែកវេជ្ជសាស្ត្រ ឬសាសនា។

សូមកុំយកអាហារ ឬភេសជ្ជៈចូលក្នុងបន្ទប់សវនាការ។

### ប្រាក់ឧបត្ថម្ភសាក្សីដោយអយ្យការ

សូមកត់សម្គាល់ថា សាក្សីត្រូវមានដីកាកោះហៅឱ្យចូលរួមក្នុងដំណើរការតុលាការ ដើម្បីមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសាក្សី។ សម្រាប់សាក្សីក្នុងស្រុក សូមយោងទៅកាន់ផ្នែកទី ២ សម្រាប់ការទាមទារប្រាក់ឧបត្ថម្ភសាក្សី។ សម្រាប់សាក្សីបរទេស សូមយោងទៅកាន់ផ្នែកទី ១ និង ២ សម្រាប់ការទាមទារប្រាក់ឧបត្ថម្ភសាក្សី។

#### ផ្នែកទី ១ | មុនពេលជំនុំជម្រះ៖ សម្រាប់តែសាក្សីបរទេស

ការដាក់ពាក្យស្នើសុំដោយ IO/ព្រះរាជអាជ្ញាជូនដល់ផ្នែកហិរញ្ញវត្ថុ គប្បីត្រូវធ្វើនៅរយៈពេលយ៉ាងហោចណាស់ ១៤ថ្ងៃ នៃថ្ងៃ ការងារ នៅមុនកាលបរិច្ឆេទជំនុំជម្រះ។

**១. ការបំពេញពាក្យសុំ**
មន្ត្រីស៊ើបអង្កេត (IO)/ព្រះរាជអាជ្ញាត្រូវបំពេញទម្រង់ពាក្យស្នើសុំនេះសម្រាប់សាក្សីបរទេស (ទម្រង់ W២) និងរៀបចំឯកសារគាំទ្រចាំបាច់នានា។* ព្រះរាជអាជ្ញាសាធារណៈប្រចាំការ (DPP) ត្រូវអនុម័តលើទម្រង់ W២ មុនពេលដាក់ពាក្យស្នើសុំនេះ។
*អាចទាញទម្រង់ និងបញ្ជីផ្ទៀងផ្ទាត់នៃឯកសារគាំទ្រខាងក្រោម

**២. ការដាក់ពាក្យសុំ**
IO/ព្រះរាជអាជ្ញាត្រូវដាក់ទម្រង់ W២ និងឯកសារគាំទ្រដែលចាំបាច់ជូនដល់ផ្នែកហិរញ្ញវត្ថុតាមរយៈ contact@statecourts.gov.sg។

**៣. ការដំណើរការពាក្យសុំ**
ផ្នែកហិរញ្ញវត្ថុដំណើរការពាក្យសុំ។

**៤. លទ្ធផលនៃពាក្យសុំ**
ក) ប្រសិនបើពាក្យស្នើសុំទទួលបានការយល់ព្រម៖ ផ្នែកហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ IO/ព្រះរាជអាជ្ញាអំពី បរិមាណដែលត្រូវបានអនុម័ត។
ខ) ប្រសិនបើពាក្យស្នើសុំទទួលបានការបដិសេធ៖ ផ្នែកហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ IO/ព្រះរាជអាជ្ញា ថា ពាក្យសុំនេះត្រូវបានបដិសេធ។

#### ផ្នែកទី ២ | ក្រោយពេលជំនុំជម្រះ៖ សម្រាប់សាក្សីក្នុងស្រុក និងបរទេសប៉ុណ្ណោះ

វិធាន (១០) នៃលិខិតបទដ្ឋានគតិយុត្តនានាចែងថា ត្រូវដាក់ទម្រង់ទាមទារ និងឯកសារគាំទ្រជូនដល់តុលាការក្នុងរយៈពេលមិនលើសពី ២ខែ បន្ទាប់ពីមានកំណើននៃប្រាក់ឧបត្ថម្ភដែលត្រូវទាមទារ (ឧទា. កាលបរិច្ឆេទចុងក្រោយ ដែលសាក្សីចូលរួមនៅតុលាការ)

**១. ការដាក់ទម្រង់ទាមទារប្រាក់ឧបត្ថម្ភ**
ក) សម្រាប់សាក្សីក្នុងស្រុក៖ សាក្សីត្រូវបំពេញទម្រង់ទាមទារប្រាក់ឧបត្ថម្ភសម្រាប់សាក្សីក្នុងស្រុក (ទម្រង់ W១) និងដាក់ទម្រង់ W១ និងឯកសារគាំទ្រ* ជូនដល់ IO/ព្រះរាជអាជ្ញា (មន្ត្រីពិនិត្យបញ្ជាក់)។
ខ) សម្រាប់សាក្សីបរទេស៖ សាក្សីត្រូវបំពេញទម្រង់ទាមទារប្រាក់ឧបត្ថម្ភសម្រាប់សាក្សីបរទេស (ទម្រង់ W៣) និងដាក់ទម្រង់ W៣ និងឯកសារគាំទ្រ* ជូនដល់ IO/ព្រះរាជអាជ្ញា (មន្ត្រីពិនិត្យបញ្ជាក់)។
*អាចទាញទម្រង់ និងបញ្ជីផ្ទៀងផ្ទាត់នៃឯកសារគាំទ្រខាងក្រោម។

**២. ការបញ្ជាក់លើទម្រង់ទាមទារ**
IO/ព្រះរាជអាជ្ញាបញ្ជាក់លើទម្រង់ទាមទារ និងឯកសារគាំទ្រ។

**៣. ការដាក់ទម្រង់ទាមទារ**
ក) ប្រសិនបើសំណុំរឿងនេះត្រូវបានចុះបញ្ជីនៅលើ ICMS៖ IO/ព្រះរាជអាជ្ញាត្រូវដាក់ទម្រង់ទាមទារនេះនៅលើ ICMS ជូនដល់ចៅក្រមជំនុំជម្រះដើម្បីផ្តល់ការអនុម័ត រួមជាមួយនឹងឯកសារគាំទ្រ។
ខ) ប្រសិនបើសំណុំរឿងនេះមិនត្រូវបានចុះបញ្ជីនៅលើ ICMS ទេ៖ IO/ព្រះរាជអាជ្ញាត្រូវដាក់ទម្រង់ទាមទារនេះជូនដល់មន្ត្រីតុលាការពាក់ព័ន្ធ ដែលបញ្ជូនទម្រង់នេះទៅកាន់ចៅក្រមជំនុំជម្រះ ដើម្បីផ្តល់ការអនុម័ត។

**៤. ការអនុម័តលើការទាមទារ**
ចៅក្រមជំនុំជម្រះពិនិត្យលើការទាមទារនេះ។

**៥. លទ្ធផលនៃការទាមទារ**
ក) ប្រសិនបើការទាមទារនេះទទួលបានការយល់ព្រម៖ ផ្នែកហិរញ្ញវត្ថុត្រូវដំណើរការការទាមទារនេះ និងផ្ទេរបរិមាណថវិកាដែលត្រូវបានអនុម័តទៅកាន់គណនីធនាគារដែលមានក្នុងទម្រង់ទាមទារ។
ខ) ប្រសិនបើការទាមទារនេះទទួលបានការបដិសេធ៖ ផ្នែកហិរញ្ញវត្ថុ/មន្ត្រីតុលាការត្រូវជូនដំណឹងដល់ IO/ព្រះរាជអាជ្ញាថា ការទាមទារនេះត្រូវបានបដិសេធ។

### ប្រាក់ឧបត្ថម្ភសាក្សីដោយមេធាវីការពារ

សូមកត់សម្គាល់ថា សាក្សីត្រូវមានដីកាកោះហៅឱ្យចូលរួមក្នុងដំណើរការតុលាការ ដើម្បីមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសាក្សី។ សម្រាប់សាក្សីក្នុងស្រុក សូមយោងទៅកាន់ផ្នែកទី ២ សម្រាប់ការទាមទារប្រាក់ឧបត្ថម្ភសាក្សី។ សម្រាប់សាក្សីបរទេស សូមយោងទៅកាន់ផ្នែកទី ១ និង ២ សម្រាប់ការទាមទារប្រាក់ឧបត្ថម្ភសាក្សី។

#### ផ្នែកទី ១ | មុនពេលជំនុំជម្រះ៖ សម្រាប់តែសាក្សីបរទេស

ការដាក់ពាក្យស្នើសុំដោយ DC ជូនដល់ផ្នែកហិរញ្ញវត្ថុ គប្បីត្រូវធ្វើនៅរយៈពេលយ៉ាងហោចណាស់ ១៤ថ្ងៃ នៃថ្ងៃ ការងារ នៅមុនកាលបរិច្ឆេទជំនុំជម្រះ។

**១. ការដាក់ពាក្យសុំ**
មេធាវីការពារក្តី (DC) ត្រូវបំពេញទម្រង់ពាក្យស្នើសុំនេះសម្រាប់សាក្សីបរទេស (ទម្រង់ W២) និងដាក់ទម្រង់ W២និងឯកសារគាំទ្រចាំបាច់នានា* ជូនផ្នែកហិរញ្ញវត្ថុតាមរយៈ contact@statecourts.gov.sg។
* អាចទាញទម្រង់ និងបញ្ជីផ្ទៀងផ្ទាត់នៃឯកសារគាំទ្រខាងក្រោម

**២. ការដំណើរការពាក្យសុំ**
ផ្នែកហិរញ្ញវត្ថុដំណើរការពាក្យសុំ។

**៣. លទ្ធផលនៃពាក្យសុំ**
ក) ប្រសិនបើពាក្យស្នើសុំទទួលបានការយល់ព្រម៖ ផ្នែកហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ DC អំពី បរិមាណដែលត្រូវបានអនុម័ត។
ខ) ប្រសិនបើពាក្យស្នើសុំទទួលបានការបដិសេធ៖ ផ្នែកហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ DC ថា ពាក្យសុំនេះត្រូវបានបដិសេធ។

#### ផ្នែកទី ២ | ក្រោយពេលជំនុំជម្រះ៖ សម្រាប់សាក្សីក្នុងស្រុក និងបរទេសប៉ុណ្ណោះ

វិធាន (១០) នៃលិខិតបទដ្ឋានគតិនានាចែងថា ត្រូវដាក់ទម្រង់ទាមទារ និងឯកសារគាំទ្រជូនដល់តុលាការក្នុងរយៈពេលមិនលើសពី ២ខែ បន្ទាប់ពីមានកំណើននៃប្រាក់ឧបត្ថម្ភដែលត្រូវទាមទារ (ឧទា. កាលបរិច្ឆេទចុងក្រោយ ដែលសាក្សីចូលរួមនៅតុលាការ)

**១. ការដាក់ទម្រង់ទាមទារប្រាក់ឧបត្ថម្ភ**
ក) សម្រាប់សាក្សីក្នុងស្រុក៖ សាក្សីត្រូវបំពេញទម្រង់ទាមទារប្រាក់ឧបត្ថម្ភសម្រាប់សាក្សីក្នុងស្រុក (ទម្រង់ W១) និងដាក់ទម្រង់ W១ និងឯកសារគាំទ្រ* ជូនដល់ DC (មន្ត្រីពិនិត្យ បញ្ជាក់)។
ខ) សម្រាប់សាក្សីបរទេស៖ សាក្សីត្រូវបំពេញទម្រង់ទាមទារប្រាក់ឧបត្ថម្ភសម្រាប់សាក្សីបរទេស (ទម្រង់ W៣) និងដាក់ទម្រង់ W៣ និងឯកសារគាំទ្រ* ជូនដល់ DC (មន្ត្រីពិនិត្យបញ្ជាក់)។
* អាចទាញទម្រង់ និងបញ្ជីផ្ទៀងផ្ទាត់នៃឯកសារគាំទ្រខាងក្រោម។

**២. ការពិនិត្យផ្ទៀងផ្ទាត់ទម្រង់ទាមទារ**
DC ពិនិត្យផ្ទៀងផ្ទាត់ និងដាក់ទម្រង់ទាមទារ និងឯកសារគាំទ្រជូនដល់មន្ត្រីតុលាការពាក់ព័ន្ធ (មន្ត្រីពិនិត្យបញ្ជាក់)។

**៣. ការបញ្ជាក់លើទម្រង់ទាមទារ**
មន្ត្រីតុលាការបញ្ជាក់ និងដាក់ទម្រង់ទាមទារនេះជូនចៅក្រមជំនុំជម្រះ ដើម្បីផ្តល់ការអនុម័ត។

**៤. ការអនុម័តលើការទាមទារ**
ចៅក្រមជំនុំជម្រះពិនិត្យលើការទាមទារនេះ។

**៥. លទ្ធផលនៃការទាមទារ**
ក) ប្រសិនបើការទាមទារនេះទទួលបានការយល់ព្រម៖ ផ្នែកហិរញ្ញវត្ថុត្រូវដំណើរការការទាមទារនេះ និងផ្ទេរបរិមាណថវិកាដែលត្រូវបានអនុម័តទៅកាន់គណនីធនាគារដែលមានក្នុងទម្រង់ទាមទារ។
ខ) ប្រសិនបើការទាមទារនេះទទួលបានការបដិសេធ៖ មន្ត្រីតុលាការត្រូវជូនដំណឹងដល់ DC ការទាមទារនេះត្រូវបានបដិសេធ។

---

៣៥ https://www.fcfcoa.gov.au/sites/default/files/2021-08/Going-to-court-tips-for-your-court-hearing-0921V1.pdf

៣៦ https://www.judiciary.gov.sg/docs/default-source/attending-court-docs/witnesses_allowances_flowchart.pdf

**ការស្វែងរកសំណង** - មជ្ឈមណ្ឌលយុត្តិធម៌សហគមន៍សឹង្ហបុរីគាំទ្រតុលាការសឹង្ហបុរី ដោយជួយដល់ជនរងគ្រោះនៃបទល្មើសក្នុងការដាក់ពាក្យទាមទារសំណង តាមរយៈគ្រោងការណ៍ជំនួយជនរងគ្រោះ។ គេហទំព័រនេះបង្ហាញលម្អិតអំពី អ្នកដែលអាចដាក់ពាក្យស្នើសុំ របៀបដាក់ពាក្យស្នើសុំ និងព័ត៌មានអំពីការផ្តល់ថវិកា។[៣៧]

**បដិទានជនរងគ្រោះ** - នៅ British Columbia ប្រទេសកាណាដា គេហទំព័ររដ្ឋាភិបាលផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពី (១) របៀបដាក់ពាក្យស្នើសុំបដិទាន (២) ពេលវេលាដើម្បីដាក់ពាក្យ (៣) ការបាត់បង់ និងការខូចខាត ដែលអាចទទួលបានសំណង (៤) ព័ត៌មានអំពី អ្វីដែលពួកគេនឹងទទួលបាន និង (៥) អ្វីដែលត្រូវធ្វើ ប្រសិនបើ ជនល្មើសមិនផ្តល់ការទូទាត់។ គេហទំព័រនេះក៏ផ្តល់តំណភ្ជាប់ទៅកាន់ពាក្យស្នើសុំ និងព័ត៌មានបន្ថែមទៀតផងដែរ។[៣៨]


BRITISH COLUMBIA
Menu

Home > Law, crime and justice > Criminal justice > B.C.'s criminal justice system > If You Are a Victim of a Crime > Victim of Crime >

- Understanding criminal justice
- If You Are a Victim of a Crime
  - Victim of Crime
    - First Steps
    - Staying Safe
    - How You May Feel
    - Victim Notification
    - Crime Victim Assistance Program
    - Crime Victim Assistance Program Application Forms
    - Victim Restitution
    - Victim Travel Assistance
    - Victim Services
    - Family Information Liaison Unit
    - Victim Services & Violence Against Women Program Directory
  - Your Rights
  - Coming Forward
  - Investigating the Crime
  - The Court Case
  - Court Decision
  - Child or Young Victim
  - Victim of Youth Crime
  - Publications for Victims of Crime
- If You Witnessed a Crime
- Reporting a Crime
- If You Are Accused of a Crime
- If You Are Convicted of a Crime
- Youth Justice

## Victim Restitution

Use this banner to exit this site quickly.

When a victim experiences a financial loss or damage, such as property damage, as a result of a crime, they have the right to have the court consider making a stand-alone restitution order at sentencing under section 738 or 739 of the Criminal Code.

Restitution *may* be ordered by the criminal court judge once an offender has been found guilty. The judge can order restitution in different ways – either as a condition of an offender's probation or conditional sentence, or as a stand-alone restitution order, enforceable by the victim in civil court if the restitution is not paid.

This page provides information on requesting and receiving restitution and also provides details on how the Restitution Program can be of assistance.

### Requesting restitution

#### How does a victim request restitution?

A victim can advise the police at the time of the investigation about the financial losses or damages they have suffered. Where criminal charges are approved, a victim may request restitution by completing a Statement on Restitution form (Form 34.1):

- In many cases Crown Counsel offices will mail the Statement on Restitution form to victims along with a Victim Impact Statement form after charges are approved
- A Victim Impact Statement is a written description of how a crime has affected the victim and is considered by the court at sentencing if the accused is found guilty or pleads guilty, however restitution can only be requested by completing the Statement on Restitution form
- Victim service workers can assist victims in completing both the Statement on Restitution form and the Victim Impact Statement

For the courts to consider making a restitution order, the victim's financial losses or damages that he or she has suffered as a result of the crime must be "readily ascertainable" or easily determined:

**Restitution Program Contact Information**

Restitution Program
Ministry of Public Safety & Solicitor General
PO Box 5550 Station Terminal
Vancouver, B.C. V6B 1H1

Lower Mainland: 604-660-4898

Toll Free: 1-844-660-4898

Fax: 604-660-5340

Email

**Related Links**

- Statement on Restitution
- Victim Impact Statement
- Community Impact Statement Program
- Small Claims Court
- Supreme Court of BC
- Department of Justice Canada - Restitution Orders
- VictimLinkBC
- Victim Services & Violence Against Women Program Directory
- Publications for Victims of Crime
- Information and Resources for Service Providers

**Criminal Justice Glossary**

៣៧ https://www.cjc.org.sg/services/social-support/victim-assistance-scheme/

៣៨ https://www2.gov.bc.ca/gov/content/justice/criminal-justice/bcs-criminal-justice-system/if-you-are-a-victim-of-a-crime/victim-of-crime/victim-restitution

**ដំបូន្មានផ្លូវច្បាប់ដោយឥតគិតថ្លៃ សម្រាប់ជនរងគ្រោះ និងសាក្សី** - នៅក្នុងប្រទេសជាច្រើន ដំបូន្មាន និងការគាំទ្រផ្លូវច្បាប់ដោយឥតគិតថ្លៃត្រូវបានផ្តល់ដល់ជនរងគ្រោះនៃបទល្មើស។ ដំបូន្មានផ្លូវច្បាប់នេះអាចពង្រីកទៅជួយដល់ជនរងគ្រោះក្នុងការទាមទារសំណង និងបដិទានបាន។[៣៩] ជាញឹកញាប់ សេវាជំនួយផ្លូវច្បាប់ដោយឥតគិតថ្លៃទាំងនេះត្រូវបានផ្តល់ដោយមេធាវីឯករាជ្យ ដែលស្ថិតនៅក្នុងតុលាការ។ នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ជំនួយផ្លូវច្បាប់ NSW ផ្តល់ដំបូន្មាន និងការគាំទ្រផ្លូវច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះនៃបទល្មើសហិង្សា។

នាយកដ្ឋានអគ្គព្រះរាជអាជ្ញា និងយុត្តិធម៌នៅរដ្ឋ NSW ប្រទេសអូស្ត្រាលី ផ្តល់ដល់ជនរងគ្រោះនូវសេវាគាំទ្រ ដែលអាចផ្តល់ការគាំទ្រ ព័ត៌មាន ការបញ្ជូន ការពិគ្រោះយោបល់ និងសេវាសំណងដល់ជនរងគ្រោះនៃបទល្មើសហិង្សា និងសាក្សីចំពោះបទល្មើសហិង្សា។ ពួកគេក៏ផ្តល់ព័ត៌មានយ៉ាងច្បាស់នៅលើគេហ៍ទំព័ររបស់ពួកគេផងដែរអំពី អ្វីដែលមានសម្រាប់ជនរងគ្រោះនៃបទល្មើស (សូមមើលខាងក្រោម)។[៤០]



## What can I get help with?

The table summarises the different types of supports that you may get and what information we need from you for each support type.

| Purpose | Benefits | Who is eligible to apply? | What information do I need to give? | How long do you have to claim? |
|---|---|---|---|---|
| **Type of help: Counselling** | | | | |
| To help in your recovery | Up to 22 hours of counselling and more for some victims | • Primary victims<br>• Secondary victims<br>• Family victims | • Application form<br>• Government issued ID | No time limit |
| **Type of help: Financial assistance for immediate needs** | | | | |
| To help pay for things you need urgently to be safe and healthy because of the violent crime | You may get up to $5,000 to help pay for:<br>• changing the locks on your doors<br>• moving house<br>• putting an alarm in your home<br>• emergency doctor, dentist and other medical bills<br>• crime scene clean up<br>You may get up to $9,500 to help pay for the funeral | • Primary victims<br>• Parents, step-parents and guardians<br>• Family victims | • Application form<br>• Government issued ID<br>• Police* or government/government-funded organisation report, or a medical report that provides details about what happened and shows how the violent crime has affected you (not required for family victims)<br>• Copies of tax invoices, receipts or treatment plans of costs you are claiming<br>• A description of how each cost relates directly to the violent crime | • Within 2 years from the violent crime†<br>• For children, within 2 years of turning 18 |

**ដំបូន្មានផ្លូវច្បាប់ដោយឥតគិតថ្លៃ សម្រាប់ជនរងគ្រោះ និងសាក្សី** - នៅប្រទេសជាច្រើន ដូចជា ប្រទេសវៀតណាម ដំបូន្មាន និងការគាំទ្រផ្លូវច្បាប់ដោយឥតគិតថ្លៃត្រូវបានផ្តល់ដល់ជនរងគ្រោះនៃបទល្មើស។ ដំបូន្មានផ្លូវច្បាប់នេះអាចពង្រីកទៅដល់ការជួយជនរងគ្រោះក្នុងការទទួលបានសំណង និងបដិទាន។ ដំបូន្មានផ្លូវច្បាប់ដោយគិតថ្លៃនៅប្រទេសវៀតណាមត្រូវបានផ្តល់ពីអង្គការជំនួយផ្លូវច្បាប់នានា ហើយប្រសិនបើសាក្សីមិនបានទទួលដំបូន្មានផ្លូវច្បាប់ទេ ចៅក្រមរមែងតែងណែនាំជនរងគ្រោះទៅកាន់សេវាសមស្រប ដើម្បីធានាថា ពួកគេអាចទទួលបានសិទ្ធិផ្លូវច្បាប់របស់ពួកគេ។

៣៩ ដំបូន្មានផ្លូវច្បាប់គប្បីមាន ជាផ្នែកមួយនៃសេវាលក្ខណៈរួមបញ្ចូលគ្នា ដែលផ្តល់ដោយកម្មវិធីជំនួយជនរងគ្រោះ។ ដោយសារជនរងគ្រោះនៃអំពើជួញដូរជាច្រើនខ្លាចអាជ្ញាធររដ្ឋាភិបាល និងអាជ្ញាធរការិយាធិបតេយ្យ ការផ្តល់ជំនួយ និងភាពតំណាងផ្លូវច្បាប់មានសារសំខាន់ជាពិសេស។ ការបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ជំនួយផ្លូវច្បាប់ និងទីភ្នាក់ងារអនុវត្តច្បាប់អាចសម្របសម្រួលយ៉ាងច្រើនដល់កិច្ចការពារជនរងគ្រោះ និងសិទ្ធិរបស់ពួកគេ។ ការរៀបចំពិធីសារ និងនីតិវិធីផ្លូវការ និងក្រៅផ្លូវការរវាងទីភ្នាក់ងារទាំងនេះគប្បីជាផ្នែកមួយនៃយុទ្ធសាស្ត្រជំនួយជនរងគ្រោះលក្ខណៈរួមបញ្ចូលគ្នា។

៤០ https://static1.squarespace.com/static/60c04522c28dde76edfa63a3/t/60fe3f9ab2fdf61c00407ce9/1627275162746/Victim_s+Support+Scheme.pdf

សូចនាករ

៥

ការស្តារផ្លូវកាយ ផ្លូវចិត្ត និងសង្គម របស់ជនរងគ្រោះ

## សូចនាករ ៥៖ សូចនាករនានា ដែលពាក់ព័ន្ធនឹងវិធានការ ដើម្បីផ្តល់សម្រាប់ការស្តារឡើងវិញផ្លូវកាយ ផ្លូវចិត្ត និងសង្គម របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ទស្សនៈរួម

ជនរងគ្រោះ និងសាក្សីអាចត្រូវការសេវា និងការគាំទ្រពិសេស ទាំងសម្ភារ និងផ្លូវចិត្ត។ សេវាប្រកបដោយប្រសិទ្ធភាព សម្រាប់ជនរងគ្រោះដោយអំពើជួញដូរ គឺពឹងផ្អែកលើអ្នកផ្តល់សេវាជាច្រើន ដែលធ្វើការងាររួមគ្នាក្នុងលក្ខណៈសម្របសម្រួលគ្នា ដើម្បីដោះស្រាយតម្រូវការជាក់លាក់របស់ជនរងគ្រោះ រួមទាំងការផ្តល់ដំបូន្មានផ្លូវច្បាប់ផងដែរ។

អភិក្រមដែលយកចិត្តទុកដាក់លើជនរងគ្រោះនៃអនុសញ្ញា ACTIP អាចសម្រេចបានតែតាមរយៈកិច្ចសហការពហុស្ថាប័នប៉ុណ្ណោះ ដូចជា នៅក្នុងក្របខណ្ឌការងារនៃយន្តការបញ្ជូនជាតិ ដែលពាក់ព័ន្ធនឹងកម្រងនៃតួអង្គរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាល ដែលធ្វើការងាររួមគ្នាក្នុងលក្ខណៈសម្របសម្រួលគ្នា ដើម្បីធានាថា ជនរងគ្រោះទាំងអស់ទទួលបានជំនួយ ដោយមិនគិតអំពីអង្គភាពដែលកំណត់អត្តសញ្ញាណរបស់ពួកគេឡើយ ដើម្បីធានានូវការបំពេញតម្រូវការរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

ដោយសារកង្វះទំនុកចិត្តលើការអនុវត្តច្បាប់នៅក្នុងតំបន់ជាក់លាក់ មានតែបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលអាចកសាងទំនាក់ទំនងនៃទំនុកចិត្តជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្សបាន។ អង្គការមិនមែនរដ្ឋាភិបាលមានជំនាញឯកទេស និងបទពិសោធន៍ក្នុងការព្យាបាល ពិគ្រោះយោបល់ និងផ្តល់កន្លែងស្នាក់នៅដល់ជនរងគ្រោះ ដែលអ្នកស៊ើបអង្កេតមានបំណងឱ្យពួកគេធ្វើជាសាក្សី។

បទពិសោធន៍ពីប្រទេសនានាបានបង្ហាញថា ការផ្តន្ទាទោសប្រកបដោយជោគជ័យប្រឆាំងនឹងជនជួញដូរមនុស្សពឹងផ្អែកលើចំណងទាក់ទងដ៏រឹងមាំ និងទំនាក់ទំនងល្អបំផុតរវាងស្ថាប័ននានា និងអ្នកផ្តល់សេវា។ វាក៏បង្ហាញថា កិច្ចព្រមព្រៀងសហការរវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ បង្កើនអត្រានៃការផ្តន្ទាទោសជនជួញដូរប្រកបដោយជោគជ័យផងដែរ។ ពិធីសារ និងអនុស្សារណៈនៃការយោគយល់គ្នាផ្លូវការរវាងស្ថាប័ននានាផ្តល់នូវមូលដ្ឋានដ៏រឹងមាំក្នុងការកសាងកិច្ចសហការពហុស្ថាប័ន។[៤១]

ប្រព័ន្ធយុត្តិធម៌ដែលត្រូវបានគ្រប់គ្រងយ៉ាងល្អទទួលស្គាល់នូវសេចក្តីត្រូវការក្នុងការសម្របសម្រួលការឆ្លើយតបចំពោះសំណុំរឿងជួញដូរមនុស្ស ហើយតុលាការអាចអនុវត្តគំនិតផ្តួចផ្តើម និងកំណែទម្រង់នានាដោយសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ដោយគ្មានហានិភ័យចំពោះឯករាជ្យភាពរបស់ពួកគេ។ តាមរយៈការធ្វើការងារក្នុងលក្ខណៈសម្របសម្រួល និងសហការគ្នា តុលាការអាចផ្តល់សេវាលក្ខណៈឆ្លើយតប និងប្រកបដោយប្រសិទ្ធភាព ដើម្បីបំពេញតម្រូវការរបស់ជនរងគ្រោះ តាមរយៈការផ្តល់ "ការិយាល័យច្រកចេញចូលតែមួយ" ដើម្បីទទួលបានសេវា។

៤១ សម្រាប់ព័ត៌មានបន្ថែមអំពី MOU / កិច្ចព្រមព្រៀងនានា សូមមើលកញ្ចប់ឧបករណ៍កាត់បន្ថយបទល្មើសនៃការិយាល័យមហាផ្ទៃចក្រភពអង់គ្លេសស្តីពី អំពើជួញដូរមនុស្ស ដែលមាននៅ www.crimereduction.gov.uk/toolkits/tp00.htm និងយន្តការបញ្ជូនជាតិ៖ កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីការពារសិទ្ធិជនត្រូវបានជួញដូរ សៀវភៅណែនាំអនុវត្តជាក់ស្តែង (Warsaw, OSCE, 2004) មាននៅ៖ www.osce.org/publications/odihr/2004/05/12351_131_en.pdf

## គោលការណ៍

### *តើគប្បីអនុវត្តអ្វីខ្លះ?*

**ទំនាក់ទំនងរបស់តុលាការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល** - នៅសឹង្ហបុរី តុលាការរដ្ឋមានទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលអង្គការនោះមានឈ្មោះ អង្គការ ព័ត៌មានផ្លូវច្បាប់អំពីសេវាសង្គម (Legal Information of Social Services (LinKs) ដើម្បីផ្តល់ការពិគ្រោះយោបល់ ការបញ្ជូន និងដំបូន្មានដើម្បីគាំទ្រស្ត្រី កុមារ និងគ្រួសារ ដែលរងផលប៉ះពាល់ពីបញ្ហាខុសៗគ្នាជាច្រើន។ ការបង្កើតទំព័រមួយនៅលើគេហ៍ទំព័ររបស់តុលាការជាមួយនឹងតំណរភ្ជាប់នានាទៅកាន់អង្គការមិនមែនរដ្ឋាភិបាលអាចជួយជនរងគ្រោះ និងសាក្សីឱ្យទទួលបានសេវានានា ដែលតុលាការមិនអាចផ្តល់ឱ្យបាន ដូចជា ការពិគ្រោះយោបល់ ជំនួយហិរញ្ញវត្ថុ និងផ្លូវច្បាប់។ MOU មួយអាចបង្កើតមាត្រដ្ឋាននៃការគាំទ្រ ដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ និងកំណត់អំពី របៀបដែលអង្គការចំនួនពីរនឹងធ្វើការងារជាមួយគ្នា។

## ឧទាហរណ៍៖

**ទំនាក់ទំនងរបស់តុលាការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល** - នៅសឹង្ហបុរី តុលាការរដ្ឋមានទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលអង្គការនោះមានឈ្មោះ អង្គការ ព័ត៌មានផ្លូវច្បាប់អំពីសេវាសង្គម (Legal Information of Social Services (LinKs) ដើម្បីផ្តល់ការពិគ្រោះយោបល់ ការបញ្ជូន និងដំបូន្មានដើម្បីគាំទ្រស្ត្រី កុមារ និងគ្រួសារ ដែលរងផលប៉ះពាល់ពីបញ្ហាខុសៗគ្នាជាច្រើន។ ការបង្កើតទំព័រមួយនៅលើគេហ៍ទំព័ររបស់តុលាការជាមួយនឹងតំណរភ្ជាប់នានាទៅកាន់អង្គការមិនមែនរដ្ឋាភិបាលអាចជួយជនរងគ្រោះ និងសាក្សីឱ្យទទួលបានសេវានានា ដែលតុលាការមិនអាចផ្តល់ឱ្យបាន ដូចជា ការពិគ្រោះយោបល់ ជំនួយហិរញ្ញវត្ថុ និងផ្លូវច្បាប់។ MOU មួយអាចបង្កើតមាត្រដ្ឋាននៃការគាំទ្រ ដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ និងកំណត់អំពី របៀបដែលអង្គការចំនួនពីរនឹងធ្វើការងារជាមួយគ្នា។[៤២]




៤២ https://www.cjc.org.sg/services/social-support/legal-information-and-knowledge-of-social-services-links/

**ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល** - នៅសឹង្ហបុរី ដោយទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល តុលាការរដ្ឋបានរៀបចំ "កញ្ចប់ឧបករណ៍សម្រាប់សាក្សី" ដើម្បីជួយសាក្សីនៅក្នុងត្រៀមសម្រាប់ការជំនុំជម្រះ។[៤៣]







**សម្ភារដែលត្រូវបានរៀបចំជាពិសេសសម្រាប់កុមារសាក្សី និងកុមាររងគ្រោះ** - គោលការណ៍ណែនាំសហប្រជាជាតិស្តីពី ភាពយុត្តិធម៌នៅក្នុងបញ្ហានានាពាក់ព័ន្ធនឹងកុមាររងគ្រោះ និងកុមារសាក្សីនៃបទល្មើស (សំណៅបែបកុមារមេត្រី)[៤៤] ផ្តល់ការពន្យល់ជាភាសាសាមញ្ញ និងសមស្របសម្រាប់កុមារអំពី អ្វីដែលគប្បីធ្វើ និងរបៀបដែលមនុស្សគប្បីធ្វើសកម្មភាពនៅក្នុងស្ថានភាពជាក់លាក់ ដើម្បីធានាថា កុមារដែលបានរងគ្រោះថ្នាក់ដោយសារបទល្មើស និងកុមារដែលបានឃើញអ្នកដទៃទៀតរងគ្រោះថ្នាក់ ទទួលបានកិច្ចការពារ និងការប្រព្រឹត្តដោយស្មើភាពគ្នា នៅពេលដែលពួកគេប្រាប់អំពីរឿងរ៉ាវរបស់ពួកគេទៅតុលាការដោយសម្រេចតាមគោលការណ៍ច្បាប់។ ឯកសារនេះក៏ជួយការពារកុមារនៅពេលដែលពួកគេនិយាយជាមួយនគរបាល មេធាវី បុគ្គលិកសង្គម និងអ្នកណាម្នាក់ផ្សេងទៀត ដែលពួកគេជួបនៅមុន និងក្រោយពេលពួកគេទៅកាន់តុលាការផងដែរ។







**កិច្ចគាំទ្រជនរងគ្រោះ** - នៅរដ្ឋ New South Wales ប្រទេសអូស្ត្រាលី កិច្ចគាំទ្ររបស់តុលាការចំពោះជនរងគ្រោះ និងសាក្សីនៃបទល្មើស (VWCCS) ត្រូវបានបង្កើតឡើង ដើម្បីជូនដំណឹង និងគាំទ្រជនរងគ្រោះ និងសាក្សីនៃបទល្មើស នៅពេលដែលពួកគេផ្តល់ភស្តុតាងនៅក្នុងតុលាការ NSW ។ អង្គការមិនមែនរដ្ឋភិបាល ដែលដំណើរការទាំងស្រុងដោយអ្នកស្ម័គ្រចិត្តដែលទទួលបានការបណ្តុះបណ្តាល ធ្វើការងារជាមួយទាំងបុគ្គល និងស្ថាប័ននានា (រួមទាំងតុលាការ) ហើយសេវាទាំងអស់ត្រូវបានផ្តល់ដោយគិតថ្លៃ។ អង្គការទាំងនោះទាក់ទងទៅ ជនរងគ្រោះនៃបទល្មើសតាមរយៈទំព័រហ្វេសបុករបស់ពួកគេ ដោយពួកគេទទួលបានការបញ្ជូន ដោយផ្ទាល់ពីព្រះរាជអាជ្ញា និងពីតុលាការផងដែរ។[៤៥]




---

៤៤ https://www.unodc.org/pdf/criminal_justice/Guidelines_E.pdf

៤៥ https://www.vwccs.org.au

សូចនាករ

៦

សេវាវេជ្ជសាស្ត្រ និង កោសល្យវិច្ច័យ

## សូចនាករ ៦៖ សូចនាករនានា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាវេជ្ជសាស្ត្រ និងកោសល្យវិច្ច័យ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ទស្សនៈរួម

ជនរងគ្រោះដោយអំពើជួញដូរមនុស្សជាច្រើនមានតម្រូវការវេជ្ជសាស្ត្រដែលចាំបាច់ត្រូវឆ្លើយតប។ ពួកគេអាចមានរបួសលើរាងកាយ ឬបានប្រឈមនឹងហានិភ័យនៃជំងឺ។ ពួកគេអាចបានរងបង្ខិតបង្ខំឱ្យប្រើប្រាស់គ្រឿងញៀន ដែលជាមធ្យោបាយមួយនៃការគ្រប់គ្រង ឬបានញៀនគ្រឿងញៀន ដើម្បីជួយពួកគេក្នុងការទប់ទល់ជាមួយនឹងស្ថានភាពដែលពួកគេបានស្ថិតនៅ។ ជនរងគ្រោះមួយចំនួនអាចមានបញ្ហាសុខភាពផ្លូវចិត្តពាក់ព័ន្ធនឹងការប៉ះទង្គិចផ្លូវចិត្ត ដែលជាលទ្ធផលនៃអំពើជួញដូរមនុស្ស។ ជនរងគ្រោះដទៃទៀតអាចមានបញ្ហាសុខភាពផ្លូវភេទ ដោយសារការប្រព្រឹត្តិ ផ្លូវភេទដែលគ្មានសុវត្ថិភាព និងប្រកបដោយអំពើហិង្សា រួមទាំងហានិភ័យកាន់តែខ្ពស់នៃការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគដទៃទៀត។

ការពិនិត្យ និងកិច្ចពិភាក្សាអំពីបញ្ហាវេជ្ជសាស្ត្រដំបូងគប្បីត្រូវបានធ្វើឡើងក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលសមស្រប ដែលអាចផ្តល់បុគ្គលគាំទ្រ និងអ្នកបកប្រែ (ប្រសិនបើចាំបាច់) ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ការពិនិត្យទាំងនេះគប្បីធានានូវការកំណត់ឃើញរបួសស្នាមទាំងអស់ ការប្រមូលភ័ស្តុតាងសមស្របនិងការផ្តួចផ្តើមរៀបចំផែនការព្យាបាលរួមទាំងការពិគ្រោះយោបល់ក្រោយពេលធ្វើតេស្ត។ ភ័ស្តុតាងកោសល្យវិច្ច័យគប្បីត្រូវប្រមូល តែក្នុងករណីដែលវានឹងជួយដល់សំណុំរឿង និងដោយមានការយល់ព្រមយ៉ាងសកម្មពីជនរងគ្រោះប៉ុណ្ណោះ។

សម្រាប់តុលាការ និងចៅក្រម ពួកគេចាំបាច់ត្រូវយល់អំពី ភាពអាចជឿជាក់បាន និងសុពលភាពនៃភ័ស្តុតាងវិទ្យាសាស្ត្រ។ ចៅក្រមគប្បីមានការយល់ដឹងអំពី គោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកសម្រាប់ការប្រមូលភ័ស្តុតាងកោសល្យវិច្ច័យយ៉ាងសមស្រប និងគុណវុឌ្ឍិសម្រាប់អ្នកវិជ្ជាជីវៈដែលមានជំនាញសមស្រប។ ចៅក្រម នគរបាល និងព្រះរាជអាជ្ញាក៏គប្បីទទួលបានការបណ្តុះបណ្តាលពីអ្នកវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រ និងកោសល្យវិច្ច័យដែលមានគុណវុឌ្ឍិសមស្របអំពី លក្ខខណ្ឌ និងដែនកំណត់នៃភ័ស្តុតាងប្រភេទនេះ។[៤៦]

### គោលការណ៍

***តើគប្បីអនុវត្តអ្វីខ្លះ ?***

៦.១. ព្រះរាជអាជ្ញា និងចៅក្រមទទួលបានការបណ្តុះបណ្តាលជាក់លាក់អំពី ភាពខ្លាំង និងភាពខ្សោយនៃភ័ស្តុតាងកោសល្យវិច្ច័យពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងផ្លូវកាយ (អនុសញ្ញា ACTIP មាត្រា ១៦.១ និង ១៦.៦)។

៦.២. ពិធីសារជាតិ សម្រាប់ការពិនិត្យកោសល្យវិច្ច័យលើការរំលោភផ្លូវភេទត្រូវបានរៀបចំឡើង និងផ្អែកលើគោលការណ៍ណែនាំរបស់ WHO

៦.៣. ការផ្លាស់ប្តូរព័ត៌មានផ្លូវការប្រចាំឆ្នាំរវាងស្ថាប័នផ្នែកជួញដូរមនុស្សថ្នាក់តំបន់ និងស្ថាប័នកោសល្យវិច្ច័យឯកទេសនៅតំបន់អាស៊ាន ដើម្បីអភិវឌ្ឍអ្នកឯកទេសថ្នាក់តំបន់ និងជំរុញកិច្ចសហការ (ACTIP មាត្រា ១២(ឆ))។

៤៦ សូមមើលផងដែរនូវគោលការណ៍ណែនាំរបស់ WHO សម្រាប់ការថែទាំវេជ្ជសាស្ត្រ-ផ្លូវច្បាប់ សម្រាប់ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទនៅ៖ www.who.int/violence_injury_prevention/publications/violence/med_ leg_guidelines/en/

## ឧទាហរណ៍៖

ASEAN ACT ផ្តល់សិក្ខាសាលាតាមប្រព័ន្ធអនឡាញ ដើម្បីណែនាំចៅក្រម និងព្រះរាជអាជ្ញាអំពីលក្ខខណ្ឌ និងដែនកំណត់នានានៃការពិនិត្យវាយតម្លៃកោសល្យវិច្ច័យ។ អនុសាស្ត្រាចារ្យ វេជ្ជបណ្ឌិត David Wells មកពីវិទ្យាស្ថានកោសល្យវិច្ច័យវិចតូរីយ៉ា ប្រទេសអូស្ត្រាលី បានផ្តល់បទបង្ហាញស៊ីជម្រៅអំពី ការថែទាំ និងសេវា ដែលចាំបាច់នៅក្នុងវិស័យនេះ។[៤៧]




នៅប្រទេសហ្វីលីពីន អភិបាលកិច្ចនៅក្នុងវិស័យយុត្តិធម៌ (GOJUST) បានរៀបចំ**សៀវភៅណែនាំកោសល្យវិច្ច័យ** ពីកន្លែងកើតហេតុនៃបទល្មើសទូទៅ[៤៨] និងបានធ្វើ**ការបណ្តុះបណ្តាលអំពីកោសល្យវិច្ច័យសម្រាប់ចៅក្រម** ព្រះរាជអាជ្ញា និងមេធាវីសាធារណៈ ដែលបានផ្តល់នូវទិន្នន័យព័ត៌មានដើមគ្រា ពី ប្រធានបទនេះ។




៤៧ https://www.youtube.com/watch?v=506AhUYtr7g
៤៨ សៀវភៅណែនាំកោសល្យវិច្ច័យនេះអាចទាញយកបានពី៖ https://www.scribd.com/document/431951965/Forensics-Manual

សូចនាករ

# ៧

បញ្ញត្តិពិសេស សម្រាប់កុមារ



## សូចនាករ ៧៖ ចនាករពិសេសៗ ដែលពាក់ព័ន្ធយ៉ាងជាក់លាក់ចំពោះកុមាររងគ្រោះ ឬកុមារសាក្សីនៃអំពើជួញដូរមនុស្ស

### ទស្សនៈរួម

កុមារត្រូវបានកំណត់ ថាជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចការកំណត់នៅក្នុងអនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ។[៤៩] គ្រោះថ្នាក់ផ្លូវកាយ ផ្លូវចិត្ត និងចិត្តសង្គមជាក់លាក់ដែលកុមារត្រូវបានជួញដូរ បានទទួលរង និងភាពងាយរងគ្រោះកាន់តែខ្ពស់របស់ពួកគេចំពោះការកេងប្រវ័ញ្ច ទាមទារឱ្យមានការដោះស្រាយជាមួយពួកគេក្នុងលក្ខណៈដោយឡែកពីមនុស្សពេញវ័យដែលត្រូវបានជួញដូរ ពាក់ព័ន្ធនឹងច្បាប់ គោលនយោបាយ កម្មវិធី និងអន្តរាគមន៍ ហើយឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការពិចារណាបឋមនៅក្នុងគ្រប់ដំណាក់ការទាំងអស់ពាក់ព័ន្ធនឹងកុមារដែលត្រូវបានជួញដូរ។

កុមារដែលមានទំនាស់នឹងច្បាប់ទំនងជាបានជួបប្រទះនឹងអំពើហិង្សា ឬភាពខ្សត់ខ្សោយច្រើនជាងកុមារដទៃទៀត។ ការសិក្សានានាបានបង្ហាញថា កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌បានរងភាពរងគ្រោះដោយសារអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទពីសំណាក់តួអង្គខុសៗគ្នានៅក្នុងប្រព័ន្ធយុត្តិធម៌ (រួមទាំងនគរបាល និងមន្ត្រីកែប្រែ) ព្រមទាំងអ្នកជាប់ឃុំជាមនុស្សពេញវ័យនៅក្នុងមណ្ឌលឃុំឃាំង។ ការប៉ះទង្គិចផ្លូវចិត្តដែលត្រូវបានទទួលរង អាចបង្កគ្រោះថ្នាក់ក្នុងរយៈពេលវែងចំពោះកុមារ ការអភិវឌ្ឍអារម្មណ៍អំពីតម្លៃខ្លួនឯង និងអនាគតរបស់ពួកគេ។

កុមាររងគ្រោះ និងកុមារសាក្សីដែលមានទំនាក់ទំនងជាមួយនឹងប្រព័ន្ធយុត្តិធម៌ អាចជួបប្រទះនឹងភាពថប់បារម្ភជុំវិញការបង្ហាញខ្លួននៅតុលាការ និងភ័យខ្លាចចំពោះការប្រឈមមុខនឹងការឈឺចាប់ ឬការរងការឈឺចាប់ពីចុងចោទ ភាពអាម៉ាសពីការយំ ឬការមិនអាចឆ្លើយសំណួរបាន។ ពួកគេរមែងតែងរងគ្រោះសារជាថ្មី និងទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មីម្តងទៀតពីសំណាក់តួអង្គក្នុងវិស័យយុត្តិធម៌ ដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងស្ថានភាព និងនីតិវិធីនានាដែលសមស្រប។

សេវា និងការអនុវត្តផ្នែកយុត្តិធម៌ដែលយកចិត្តទុកដាក់ចំពោះកុមារមានគុណតម្លៃជាពិសេសក្នុងការការពារកុមារនៅក្នុងស្ថានភាពងាយរងគ្រោះ គាំទ្រពួកគេឱ្យយល់ និងគ្រប់គ្រងភាពរំជួលចិត្ត ទប់ស្កាត់ (និង/ឬឆ្លើយតបចំពោះ) វិវាទ និងអំពើហិង្សា និងផ្តល់ដល់ពួកគេនូវលំហរសុវត្ថិភាព ដើម្បីបង្ហាញអំពីខ្លួនពួកគេ និងត្រូវបានគេស្តាប់លឺ នៅពេលដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងពួកគេ រួមទាំងក្នុងនាមជាជនរងគ្រោះ ឬសាក្សី។

គោលការណ៍ណែនាំ គោលនយោបាយ យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងយន្តការការពារសុវត្ថិភាពដទៃទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ចាំបាច់ត្រូវបានរៀបចំ ដើម្បីទប់ស្កាត់ រកឃើញ កំណត់រក រាយការណ៍ និងដោះស្រាយសំណុំរឿងអំពើហិង្សាលើកុមារប្រកបដោយសុវត្ថិភាព។

កុមារងាយរងគ្រោះ និងត្រូវការកិច្ចការពារ ជំនួយ និងការគាំទ្រពិសេស ដែលសមស្របទៅតាមអាយុ កម្រិតនៃភាពចាស់ទុំ និងតម្រូវការដោយឡែករបស់ពួកគេ ដើម្បីទប់ស្កាត់បន្ថែមទៀតចំពោះការលំបាក និងការប៉ះទង្គិចផ្លូវចិត្ត ដែលអាចបង្កឡើងមកពីការចូលរួមរបស់ពួកគេនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ កុមាររងគ្រោះដោយអំពើជួញដូរមនុស្សគប្បីទទួលបានជំនួយ និងកិច្ចការពារសមស្រប និងគប្បីមានការពិចារណាយ៉ាងពេញលេញទៅដល់សិទ្ធិ និងតម្រូវការពិសេសរបស់ពួកគេ។

---

៤៩ មាត្រា ២(យ) នៃអនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ACTIP)

តុលាការចាំបាច់ត្រូវអនុវត្តអភិក្រមដែលយកចិត្តទុកដាក់លើជនរងគ្រោះ ដែលគិតគូរទៅដល់អាយុ[៥០] បំណងប្រាថ្នា ការយល់ដឹង យេនឌ័រ ចំណង់ចំណូលផ្លូវភេទ សាវតាជាតិពន្ធុ វប្បធម៌ សាសនា ភាសាសង្គម វណ្ណៈ ស្ថានភាពសង្គមសេដ្ឋកិច្ច និងស្ថានភាពទេសន្តរប្រវេសន៍ ឬជនភៀសខ្លួនរបស់កុមារ ព្រមទាំងគិតគូរអំពីតម្រូវការពិសេសរបស់កុមារ រួមទាំងសុខភាព លទ្ធភាព និងសមត្ថភាព។ អ្នកវិជ្ជាជីវៈគប្បីទទួលបានការបណ្តុះបណ្តាល និងការអប់រំអំពី ភាពខុសៗគ្នាទាំងនេះ។[៥១]

កុមារគប្បីទទួលបានព័ត៌មានយ៉ាងពេញលេញអំពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ស្ថានភាពនៃសំណុំរឿង និងមានសិទ្ធិបង្ហាញទស្សនៈរបស់ពួកគេដោយសេរីនៅក្នុងគ្រប់បញ្ហា ដែលមានឥទ្ធិពលលើពួកគេ។ តុលាការគប្បីស្វាគមន៍ការចូលរួមរបស់កុមារនៅក្នុងការបង្ហាញទស្សនៈ និងគោរពសេចក្តីសម្រេចចិត្តរបស់ពួកគេក្នុងការចូលរួម ឬមិនចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

បន្ថែមលើសូចនាករទាំងឡាយ ដែលមានរាយនៅក្នុងសូចនាករ ២ និង ៤ នៅពេលអាចអនុវត្ត តុលាការគប្បីផ្តល់កិច្ចការពារចាំបាច់ដល់កុមាររងគ្រោះ ដោយអនុញ្ញាតឱ្យកុមារផ្តល់សក្តីកម្មតាមរយៈប្រព័ន្ធទូរទស្សន៍ ឬតាមរយៈអន្តរការី ធ្វើឱ្យកុមារលែងសូវខ្លាចបន្ទប់សវនាការ និងនីតិវិធីនានា និងផ្តល់ការណែនាំចំពោះព្រះរាជអាជ្ញា និងមេធាវីការពារចុងចោទ ដើម្បីធានាថា ការសួរសំណួរយកចិត្តទុកដាក់ទៅលើអាយុ និងតម្រូវការពិសេសរបស់កុមារ ដើម្បីជៀសវាងហានិភ័យនៃភាពរងគ្រោះជាថ្មីម្តងទៀត។[៥២]

## គោលការណ៍

### *តើគប្បីអនុវត្តអ្វីខ្លះ?*

៧.១. តុលាការគប្បីផ្តល់ការការពារសុវត្ថិភាព ដើម្បីការពារកុមារសាក្សី កុមាររងគ្រោះ និងកុមារចុងចោទ តាមរយៈ៖

ក) ការធានាថា មានវិធានការនានា ដើម្បីកាត់បន្ថយការពន្យារពេលនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ (អនុសញ្ញា ACTIP មាត្រា ១៦.៣)

ខ) ការការពារឯកជនភាពរបស់កុមារ តាមរយៈការហាមឃាត់ចំពោះការកំណត់សញ្ញាណកុមាររងគ្រោះ/កុមារសាក្សី ឬកុមារចុងចោទ (អនុសញ្ញា ACTIP មាត្រា ១៤.៥ ១៤.៦ និង ១៦.៧)

គ) ការបន្តផ្តល់ព័ត៌មានដល់កុមារអំពីតួនាទី និងវិសាលភាពរបស់ពួកគេ ពេលវេលា និងវឌ្ឍនភាពនៃដំណើរការនេះ (អនុសញ្ញា ACTIP មាត្រា ១៤.៩ ១៤.១០(ខ) និង ១៤.១២)

ឃ) ការរៀបចំ និងការអនុវត្តគ្រោងការណ៍ត្រៀមលក្ខណៈកុមារសាក្សី ដើម្បីឱ្យកុមារយល់អំពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ នៅមុនពេលពួកគេផ្តល់ភ័ស្តុតាង (អនុសញ្ញា ACTIP មាត្រា ១៤.៩)

ង) ការផ្តល់ព័ត៌មានបែបយកចិត្តទុកដាក់ចំពោះកុមារ និងសមស្របតាមអាយុទៅដល់កុមារអំពីដំណើរការជំនុំជម្រះ តួនាទីរបស់ពួកគេនៅក្នុងសំណុំរឿងនេះ ការរំពឹងទុករបស់តុលាការពីពួកគេ និងព្យាយាមដោះស្រាយកង្វល់នានា ដែលពួកគេមាននៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ (អនុសញ្ញា ACTIP មាត្រា ១៤.៩ ១៤.១០(ខ) និង ១៤.១២)

---

៥០ អាយុមិនគួរជាឧបសគ្គចំពោះសិទ្ធិរបស់កុមារនៅក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការយុត្តិធម៌ឡើយ។ កុមារគ្រប់រូបគប្បីទទួលបានការប្រព្រឹត្តចំពោះក្នុងនាមជាសាក្សីប្រកបដោយសមត្ថភាព អាស្រ័យលើការត្រួតពិនិត្យ ហើយសក្ខីកម្មរបស់ពួកគេមិនគួរត្រូវបានសន្មតជាមុនថាគ្មានសុពលភាព ឬមិនអាចជឿជាក់បាន ដោយសារមូលហេតុអាយុតែមួយមុខនោះឡើយ ដរាបណាអាយុ និងភាពចាស់ទុំរបស់ពួកគេអនុញ្ញាតឱ្យមានការផ្តល់សក្ខីកម្ម ដែលយល់បាន និងជឿជាក់បានដោយមាន ឬគ្មានជំនួយក្នុងការទំនាក់ទំនង និងជំនួយដទៃទៀត។

៥១ គោលការណ៍ណែនាំសហប្រជាជាតិស្តីពី កុមាររងគ្រោះ និងកុមារសាក្សី។ សូមមើលផងដែរ គោលការណ៍ណែនាំសម្រាប់ការផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាពចំពោះបទល្មើសលើកុមារ (វិទ្យាស្ថានព្រះរាជអាជ្ញាអន្តរជាតិ) ដែលមាននៅ www.iap.nl.com និងការិយាល័យសិទ្ធិកុមារអន្តរជាតិ ដែលមាននៅ www.ibcr.org

៥២ សៀវភៅណែនាំអំពី ភាពយុត្តិធម៌សម្រាប់ជនរងគ្រោះ UNODCCP

ច) ការអនុញ្ញាតឱ្យមានការផ្តល់ខ្សែរអាត់វីដេអូដែលត្រូវបានថតទុកជាមុនអំពីសក្ខីកម្មរបស់កុមាររងគ្រោះ/កុមារសាក្សី ដើម្បីចាក់នៅតុលាការ ក្នុងនាមជាបំណែកផ្លូវការនៃភស្តុតាង (អនុសញ្ញា ACTIP មាត្រា ១៤.៥ និង ១៤.៦)

ឆ) ការអនុញ្ញាតឱ្យមាន (ក្នុងនាមជាបទដ្ឋានអប្បបរមា) ការផ្តល់នាំងការពារឯកជនភាព ដើម្បីដាក់នៅចន្លោះរវាងកុមាររងគ្រោះ/កុមារសាក្សី និងជនត្រូវចោទ នៅក្នុងអំឡុងពេលជំនុំជម្រះ (អនុសញ្ញា ACTIP មាត្រា ១៤.៥ និង ១៤.៦)

ជ) ការអនុញ្ញាតឱ្យកុមាររងគ្រោះ/កុមារសាក្សីផ្តល់សក្ខីកម្ម តាមរយៈប្រព័ន្ធទូរទស្សន៍ ប្រសិនបើកុមារចាំបាច់ត្រូវចូលរួមនៅក្នុងការជំនុំជម្រះសម្រាប់ការសាកសួរពីភាគីបដិបក្ខ (អនុសញ្ញា ACTIP មាត្រា ១៤.៥ និង ១៤.៦)

ញ) ការធ្វើឱ្យបន្ទប់សវនាការ និងនីតិវិធីមិនសូវមានលក្ខណៈបំភិតបំភ័យចំពោះកុមារសាក្សី (អនុសញ្ញា ACTIP មាត្រា ១៤.១២)

ដ) ការបិទបន្ទប់សវនាការពីការចូលរួមរបស់សាធារណជន នៅពេលដែលសំណុំរឿងនេះពាក់ព័ន្ធនឹងកុមាររងគ្រោះ/កុមារសាក្សី ឬកុមារចុងចោទ (អនុសញ្ញា ACTIP មាត្រា ១៤.៥ ១៤.៦ និង ១៦.៧)

ឋ) ការប្រើប្រាស់អន្តរការី ដើម្បីសាកសួរកុមាររងគ្រោះ (ឧទា. បុគ្គលិកសង្គម អ្នកជំនាញខាងកុមារ មេធាវី/អ្នកតំណាងជនរងគ្រោះ) នៅក្នុងការជំនុំជម្រះ និងដើម្បីជួយដល់ការ សម្ភាសរបស់នគរបាល និងព្រះរាជអាជ្ញា (អនុសញ្ញា ACTIP មាត្រា ១៤.១២)

ឌ) ការផ្តល់សេចក្តីណែនាំដល់ព្រះរាជអាជ្ញា និងមេធាវីការពារចុងចោទ ដើម្បីធានាថា ការសាកសួរពិចារណាលើអាយុ និងតម្រូវការរបស់កុមារ ដើម្បីជៀសវាងហានិភ័យនៃភាពរងគ្រោះជាថ្មីម្តងទៀត[៥៣] (អនុសញ្ញា ACTIP មាត្រា ១៤.១២)

ឍ) ធានាថា "ឧត្តមប្រយោជន៍របស់កុមារ" គឺជាការពិចារណាខ្ពស់បំផុតនៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ (អនុសញ្ញា ACTIP មាត្រា ១៤.១២)

៧.២. "អាណាព្យាបាល" ត្រូវបានចាត់តាំង ដើម្បីអមដំណើរកុមារនៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ (អនុសញ្ញា ACTIP មាត្រា ១៤.១០(ខ))

៧.៣. តុលាការបានអនុវត្ត និងធ្វើស្ថាប័នីយកម្មការកសាងសមត្ថភាពឯកទេស សម្រាប់បុគ្គលិកវិស័យយុត្តិធម៌ និងចៅក្រម ដែលធ្វើការងារជាមួយកុមាររងគ្រោះ និងកុមារសាក្សីនៃអំពើជួញដូរមនុស្ស[៥៤] (អនុសញ្ញា ACTIP មាត្រា ១២(ច) និង (ឆ) និង ១៦.១)។

## ឧទាហរណ៍៖




**ព័ត៌មាន សម្រាប់ជនល្មើសវ័យក្មេង** - នៅប្រទេសថៃតុលាការភូមិន្ទថៃបានផលិតវីដេអូនៅលើហ្វេសបុករួមជាមួយនឹងកូនសៀវភៅគាំទ្រអំពី ដំណើរការជំនុំជម្រះពាក់ព័ន្ធនឹងកុមារ។ វីដេអូនេះនិយាយអំពី ដំណើរការជំនុំជម្រះ និងពន្យល់អំពី សិទ្ធិមួយចំនួនរបស់កុមារ រួមមាន៖ សិទ្ធិរបស់កុមារក្នុងការទទួលបានមេធាវី សិទ្ធិក្នុងការមានឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេអមដំណើរពួកគេ សិទ្ធិទទួលបានអ្នកបកប្រែ និងសិទ្ធិទទួលបានកិច្ចការពារ និងឯកជនភាព។[៥៥]

---

៥៣ ចំណុចនេះពាក់ព័ន្ធជាពិសេស ប្រសិនបើជនត្រូវចោទមិនមានអ្នកតំណាងស្របច្បាប់។ គប្បីធ្វើកិច្ចខិតខំប្រឹងប្រែងទាំងអស់ក្នុងការទប់ស្កាត់ចុងចោទពីការសាកសួរកុមាររងគ្រោះ/កុមារសាក្សីដោយផ្ទាល់ ប្រសិនបើពួកគេធ្វើការការពារខ្លួនឯង។

៥៤ ឧទាហរណ៍ សូមមើល ក្រុមអនុវត្តច្បាប់អឺរ៉ុបនៃវគ្គបណ្តុះបណ្តាល ១០ របស់ ECPAT ស្តីពី អំពើជួញដូរមនុស្សពាក់ព័ន្ធនឹងកុមារ នៅ www.ecpat.net/eng/pdf/Trafficking_Report.pdf

៥៥ https://www.facebook.com/watch/?v=872023606597713

**សម្ភារសម្រាប់កុមារតូចៗអំពី ការទៅកាន់តុលាការ** - នៅប្រទេសសឹង្ហបុរី និងអូស្ត្រាលី តុលាការបានរៀបចំកូនសៀវភៅសម្រាប់កុមារ ដែលត្រូវចូលរួមជាមួយតុលាការ។ កូនសៀវភៅទាំងនេះ (ដែលមានជាច្រើនភាសាខុសៗគ្នា) មានព័ត៌មាន ដែលមានលក្ខណៈសមស្របទៅតាមអាយុអំពី អ្វីដែលតុលាការធ្វើ អ្វីដែលកុមារអាចរំពឹងទទួលបានអ្វីពីការទៅកាន់តុលាការ និងអ្វីដែលតុលាការត្រូវការពីកុមារ។ កូនសៀវភៅទាំងនេះជួយត្រៀមលក្ខណៈកុមារ សម្រាប់ការជំនុំជម្រះ និងក៏ជួយជាមួយនឹងការទទួលបានភ័ស្តុតាងដ៏ល្អបំផុតផងដែរ។ ប្រទេសសឹង្ហបុរីក៏មានវីដេអូ ដែលត្រូវបានផលិតយ៉ាងជាក់លាក់ សម្រាប់កុមារដែលចូលរួមនៅក្នុងតុលាការគ្រួសារ ដែលមានចំណងជើងថា "ថ្ងៃរបស់អ៊ិមីលីនៅក្នុងតុលាការគ្រួសារ"។ វីដេអូនេះជួយកុមារក្នុងការយល់អំពី ហេតុការណ៍នៅតុលាការ ដែលពួកគេអាចជួបប្រទះនៅក្នុងដំណើរការតុលាការគ្រួសារ។[៥៦]







**តុលាការគ្រួសារនៃប្រទេសអូស្ត្រាលី** - កម្រងនៃសៀវភៅស្តីពី"ហេតុអ្វីបានជាខ្ញុំនឹងជួបជាមួយនឹងទីប្រឹក្សាគ្រួសារ"[៥៧] ដែលមានសម្រាប់ក្រុមអាយុចំនួនពីរខុសគ្នា និងមានជាច្រើនភាសា។ សៀវភៅទាំងនេះផ្តល់ព័ត៌មានដល់កុមារអំពី ដំណើរការតុលាការគ្រួសារ និងតួនាទីរបស់ទីប្រឹក្សាគ្រួសារ (បុគ្គលិកសង្គម និងចិត្តវិទូកុមារ) នៅក្នុងដំណើរការនេះ។ សៀវភៅទាំងនេះជួយលុបបំបាត់ភាពថប់បារម្ភ និងការភ័យខ្លាចមួយចំនួន នៅពេលកុមារដឹងថា ពួកគេត្រូវតែទៅកាន់តុលាការ និងនិយាយរៀបរាប់អំពីហេតុការណ៍ដ៏លំបាក។

៥៦ https://www.judiciary.gov.sg/docs/default-source/attending-court-docs/sara_goes_to_court_english.pdf

៥៧ https://www.fcfcoa.gov.au/resources/publications/fl/why-family-consultant-5-8

**ការផ្លាស់ប្តូរបរិយាកាសក្នុងបន្ទប់សវនាការ** - នៅប្រទេសអូស្ត្រាលី តុលាការរដ្ឋនៅរដ្ឋវិចតូរីយ៉ាបានអនុវត្តតុលាការឯកទេសសម្រាប់កុមារ។ តុលាការនេះត្រូវបានរចនា ដើម្បីឱ្យមានលក្ខណៈផ្លូវការតិចតួច ហេតុនេះវាមិនសូវធ្វើឱ្យកុមារភ័យខ្លាច ហើយតុលាការមានចៅក្រម និងបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលពិសេសក្នុងការបើកសវនាការសំណុំរឿងទាំងនេះ។






**អន្តរការីកុមារសាក្សី** - បន្ថែមលើឧទាហរណ៍នៃការប្រើប្រាស់អន្តរការីដែលត្រូវបានពិភាក្សានៅផ្នែកមុននៅក្នុងឯកសារនេះ មាន "អ្នកគាំទ្រកុមារ" ឬអន្តរការីកុមារឯកទេស (ជាពិសេស សម្រាប់សំណុំរឿង ដែលពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទលើកុមារ) ដែលសម្របសម្រួលទំនាក់ទំនងជាមួយកុមារសាក្សីតាមរយៈដំណើរការជំនុំជម្រះ និងពង្រីកការប្រើប្រាស់ភ័ស្តុតាងថតទុកជាមុននៅក្នុងដំណើរការតុលាការព្រហ្មទណ្ឌ។ គោលបំណងនៃអន្តរការី គឺដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តរបស់កុមារសាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ស្របពេលដែលរក្សាសិទ្ធិរបស់ជនត្រូវចោទចំពោះការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។ រូបភាពនៅទីនេះ គឺជាគោលការណ៍ណែនាំ និងសៀវភៅណែនាំនីតិវិធី ដែលត្រូវបានរៀបចំឡើងដោយរដ្ឋាភិបាល New South Wales នៅប្រទេសអូស្ត្រាលី ដើម្បីធានាថា ឧត្តមប្រយោជន៍របស់កុមារទទួលបានការការពារ និងដើម្បីបង្ហាញអំពី ដែលកំណត់នៃតួនាទីនេះ។

៥៨ ទំនាក់ទំនងជាមួយកុមារនៅក្នុងតុលាការ - មគ្គុទ្ទេសក៍ប្រកបដោយសារប្រយោជន៍នៅក្នុងសំណុំរឿងកិច្ចការពារកុមារ ដែលត្រូវបង្កើតឡើងដោយបណ្ឌិត Kenneth Burns បណ្ឌិត Conor O'Mahony, Carly McAuley (Triangle), បណ្ឌិត Fiachra Ó'Súilleabháin និងបណ្ឌិត Elaine O'Callaghan, មហាវិទ្យាល័យច្បាប់ និងមហាវិទ្យាល័យសិក្សាសង្គមបែបអនុវត្ត សាកលវិទ្យាល័យ Cork ប្រទេសអៀរឡង់ និង Triangle ដែលសហការផ្តល់មូលនិធិដោយកម្មវិធីសិទ្ធិ សមភាព និងពលរដ្ឋភាព (REC) នៃសហភាពអឺរ៉ុប។
https://www.ucc.ie/en/media/research/ideachildrights/Communicatingwithchildrenincourt.pdf

## ៣. ចូលរួម ការនិយាយទៅកាន់កុមារ និងការសួរសំណួរកុមារនៅក្នុងតុលាការ

នៅក្នុងផ្នែកនេះ យើងផ្តល់ឧទាហរណ៍អំពី អភិក្រមសួរសំណួរ។ អត្ថបទពណ៌ផ្កាឈូក បង្ហាញរបៀបដែលមិនត្រូវសួរកុមារ និងអត្ថបទពណ៌ខៀវ គឺជាឧទាហរណ៍នៃសំណួរបែបកុមារមេត្រី។ កុមារម្នាក់ៗ មានលក្ខណៈមិនដូចគ្នាទេ ពាក់ព័ន្ធនឹងរបៀបរបបទំនាក់ទំនង និងសមត្ថភាពរបស់ពួកគេ។ អ្នកនឹងត្រូវមានលក្ខណៈបត់បែន និងកែសម្រួលអភិក្រមរបស់អ្នក ដើម្បីបំពេញតម្រូវការរបស់កុមារម្នាក់ៗ។

សូមរៀបចំសំណួរនានាជាមុន។ រៀបចំជាភាសាដែលមានលក្ខណៈសាមញ្ញឱ្យបានច្រើនតាមអាចធ្វើ និងអនុវត្តទៅតាមលំដាប់លំដោយដែលសមហេតុផល និងតាមហេតុការណ៍។ ជួយពន្យល់កុមារនៅពេលមានការផ្លាស់ប្តូរប្រធានបទ។ យើងបានបញ្ចប់ការនិយាយអំពី អ្វីដែលបានកើតឡើងនៅក្នុងថ្នាក់រៀនរបស់អ្នកហើយ។ នៅពេលនេះ ខ្ញុំនឹងសួរអ្នកអំពី អ្វីដែលបានកើតឡើងនៅកន្លែងលេងកំសាន្ត។

កុមារមានភាពសុាំថា មនុស្សពេញវ័យដឹងអំពីចម្លើយចំពោះសំណួរដែលពួកគេសួរ។ នៅក្នុងបរិយាកាសតុលាការ កុមារត្រូវការការនិយាយប្រាប់ និងការរំលឹកថា មនុស្សពេញវ័យមិនដឹងអំពីចម្លើយចំពោះសំណួរដែលបានសួរឡើយ។
ខ្ញុំមិនដឹងទេ ដោយសារខ្ញុំមិនបាននៅទីនោះឡើយ។

នៅពេលដែលអាចធ្វើបាន សូមសួរសំណួរបើក។ ប្រសិនបើ អ្នកត្រូវការសួរសំណួរបិទជាក់លាក់ ឬសំណួរបែបផ្តល់ជម្រើសដោយបង្ខំ ដើម្បីបញ្ជាក់អំពីព័ត៌មានលម្អិត សូមត្រលប់មកប្រើប្រាស់សំណួរបើកវិញឱ្យបានឆាប់តាមអាចធ្វើបាន។ ប្រសិនបើប្រើប្រាស់សំណួរបែបផ្តល់ជម្រើសដោយបង្ខំ សូមផ្តល់ជម្រើសទីបីជានិច្ច។
តើអ្នកបាននៅទីនោះជាមួយម្តាយឬទេ?
សូមប្រាប់ខ្ញុំអំពី អ្វីដែលបានកើតឡើង?
តើវាមានពណ៌ខ្មៅ ឬក្រហម?
តើមានពណ៌ខ្មៅ ក្រហម ឬពណ៌អីផ្សេង?

ប្រសិនបើត្រូវប្រើសំណួរផ្តល់ចម្លើយ បាទចាស់/ទេ សូមព្យាយាមជៀសវាងការសំណួរទាំងនោះជាបន្តបន្ទាប់គ្នា។ ប្រសិនបើនេះជម្រើសតែមួយគត់ សូមសួរបញ្ច្រាស់ចំពោះសំណួរមួយចំនួន ដើម្បីធានានូវចម្លើយចម្រុះគ្នានៃចម្លើយ បាទ/ចាស់ និង ទេ។ ការធ្វើបែបនេះបង្កើនសុក្រិតភាពនៃចម្លើយរបស់កុមារ។
(សំណួរ) តើអ្នក និងលូស៊ី រស់នៅជាមួយម្តាយឬ? (ចម្លើយ) បាទ/ចាស់។
(សំណួរ) តើអ្នក និងលូស៊ី រស់នៅជាមួយឪពុកឬ? (ចម្លើយ) ទេ។
(សំណួរ) តើអ្នក និងលូស៊ី ធ្លាប់រស់នៅជាមួយឪពុកឬ? (ចម្លើយ) បាទ។

នៅសាលារៀន និងនៅផ្ទះ កុមារសុាំនឹងលើកទឹកចិត្តឱ្យទស្សន៍ទាយ ប្រសិនបើពួកគេមិនដឹងចម្លើយចំពោះសំណួរមួយ។ ត្រូវបង្រៀនកុមារឲដឹងថា ការសម្ភាសជាមួយអ្នកវិជ្ជាជីវៈ និងនៅតុលាការគឺមានភាពខុសគ្នា ពីអ្វីដែលពួកគេបានរៀន។
នៅពេលយើងនិយាយជជេកនៅក្នុងបន្ទប់នេះ យើងមិនធ្វើការទស្សន៍ទាយឡើយ។ ប្រសិនបើអ្នកមិនដឹងចម្លើយ អ្នកត្រូវនិយាយថា "ខ្ញុំមិនដឹងទេ"។

កុមារត្រូវការការសួរសំណួរនានាក្នុងលក្ខណៈដែលច្បាស់លាស់ថា សំណួរនេះត្រូវការចម្លើយ។ ជំនួសឱ្យការបង្កើតប្រយោគ ឬមតិយោបល់ ទាំងនេះជា ទម្រង់សំណួរ។
អ្នកព្រួយបារម្ភថា ម្តាយរបស់អ្នកនឹងដឹងអំពីរឿងនេះ។
តើអ្នកព្រួយបារម្ភថា ម្តាយរបស់អ្នកនឹងដឹងអំពីរឿងនេះឬ?

ជានិច្ចកាល គប្បីជៀសវាងសំណួរភ្ជាប់ (នៅពេលដែលមានការបង្កើតប្រយោគមួយ និងភ្ជាប់ជាមួយនឹងការបន្ថែមសំណួរខ្លីមួយ ដើម្បីឲកុមារយល់ស្រប)៖
ពូដេវីដមិនពិតជាបានប៉ះអ្នកទេ មែនទេ?
អ្នកបាននិយាយថា ពូដេវីដបានប៉ះអ្នក។ ពូដេវីដបាននិយាយថា គាត់មិនបានប៉ះអ្នកទេ។ តើពូដេវីដពិតជាបានប៉ះអ្នកដែរឬទេ?

កុមាររមែងតែងគិតអំពីសំណួរនានាក្នុងលក្ខណៈដោយត្រង់ៗ។ ពួកគេរមែងតែងមិនអាចគិតឃើញអំពី មូលហេតុនៃការសួរសំណួរមួយឡើយ។
(សំណួរ) នៅពេលនេះ តើអ្នកនៅសាលារៀនឬ? (ចម្លើយ) ទេ ខ្ញុំនៅតុលាការជាមួយអ្នក។ តើអ្នកទៅសាលារៀនឬទេ?
(សំណួរ) តើអ្នកអាចប្រាប់ខ្ញុំអំពី អ្វីដែលបានកើតឡើងនៅសាលារៀនរបស់អ្នកបានដែរឬទេ? (ចម្លើយ) បាទ/ ចាស់។
សូមប្រាប់ខ្ញុំអំពី អ្វីដែលបានកើតឡើងនៅសាលារៀន នៅពេលដែល X បានកើតឡើង។

សូមមានភាពជាក់លាក់។ កុមារមិនសូវជាអាចយល់ពីអត្ថន័យសំណួរនានាឡើយ ជាពិសេស នៅពេលដែលពួកគេមិនយល់អំពីមូលហេតុនៃការសួរសំណួរ។ នៅពេលរៀបចំសំណួរ សូមគិតអំពីថាតើអាចមានការបកស្រាយខុសដែរឬទេ។
(សំណួរ)នៅពេលនោះ តើអ្នកបានស្លៀកសម្លៀកបំពាក់របស់អ្នកដែរឬទេ?(ចម្លើយ)ទេ។
(អាចមានន័យថា ពួកគេកំពុងស្លៀកឯកសណ្ឋានសិស្សរបស់ពួកគេ ឬសម្លៀកបំពាក់ដេករបស់ពួកគេ)។ តើអ្នកបានស្លៀកពាក់អ្វី?

កុមារតូចៗអាចភ្ជាប់ទំនាក់ទំនងនៃពាក្យ "ប៉ះ" ជាមួយចំពោះតែដៃ ឬម្រាមដៃប៉ុណ្ណោះ។
(សំណួរ) តើហារីបានប៉ះអ្នកដែរឬទេ? (ចម្លើយ) ទេ។
តើផ្នែកណានៃរាងកាយរបស់ហារី ដែលបានប៉ះរាងកាយរបស់អ្នក?
កុមារមិនទំនងជាអាចកំណត់អំពី ការជំរុញទឹកចិត្តរបស់អ្នកដទៃឡើយ។ គប្បីជៀសវាងសំណួរបែបនេះ ប្រសិនបើអាចធ្វើបាន ដោយសារសំណួរទាំងនោះអាចបង្កើតនូវចម្លើយដែលមិនអាចជឿជាក់បាន។ ជាពិសេស កុមារតូចៗពិបាកឆ្លើយសំណួរ ដែលចាប់ផ្តើមជាមួយនឹង "ហេតុអ្វី"។
(សំណួរ) ហេតុអ្វីជាដេនីសនាំអ្នកទៅកាន់សួននោះ? (ចម្លើយ) ខ្ញុំមិនដឹងទេ។
តើអ្វី ដែលធ្វើឱ្យដេនីសនាំអ្នកទៅកាន់សួននោះ នៅថ្ងៃនោះ?

កុមារអាចគិតថាការឆ្លើយសំណួរអំពីពេលវេលានៃអ្វីមួយបានកើតឡើង គឺជាការពិបាក។ កុមារមួយចំនួនអាចនិយាយថា "ម្សិលម៉ិញ" ឬ "អាទិត្យមុន" ចំពោះអ្វីមួយ ដែលបានកើតឡើងពីអតីតកាល។
តើវាជាថ្ងៃទៅរៀនឬ? តើវាបានកើតឡើងនៅមុន ឬក្រោយពេលទទួលទានអាហារពេលល្ងាច? តើវាភ្លឺ ឬងងឹត ឬអ្នកមិនដឹងទេ?

**ការសាកសួរដោយភាគីបដិបក្ខ** - នៅពេលដែលកុមារសាក្សីត្រូវបានសាកសួរដោយភាគីបដិបក្ខ ការសាកសួរបែបនេះគប្បីត្រូវធ្វើតាមប្រព័ន្ធទូរទស្សន៍ជាជាងពីក្នុងបន្ទប់សវនាការ។ការផ្តល់ភ័ស្តុតាងក្នុងលក្ខណៈបែបនេះអនុញ្ញាតឱ្យកុមារសាក្សីបន្តស្ថិតនៅក្នុងបន្ទប់មួយទៀតដោយឡែកពីជនត្រូវចោទ និងត្រូវបានបិតបាំងពីស្ថានភាពអមិត្ត និងរបៀបរបបផ្លូវការនៃបន្ទប់សវនាការ។ នៅវៀតណាម កុមាររងគ្រោះដោយអំពើជួញដូរ គឺត្រូវបាន "ឱ្យនៅដោយឡែកពីចុងចោទ"។ ជនរងគ្រោះចូលរួមនៅក្នុងការជំនុំជម្រះពីបន្ទប់ដោយឡែក ដែលដំណើរការនេះត្រូវបានបញ្ជូនតាមប្រព័ន្ធអនឡាញតាមរយៈប្រព័ន្ធទូរទស្សន៍។ អ្នកតំណាងផ្លូវច្បាប់ អាណាព្យាបាល បុគ្គលិកចិត្តសង្គមរបស់កុមារ ឬបុគ្គលិកកិច្ចការពារកុមារត្រូវតែមានវត្តមាននៅក្នុងបន្ទប់នេះ។

នៅតុលាការកុមារនៃរដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី កុមារអាចផ្តល់ភ័ស្តុតាងតាមរយៈប្រព័ន្ធទូរទស្សន៍ក្រោមការគាំទ្រពីបុគ្គលគាំទ្រ ដែលជាជម្រើសរបស់ពួកគេ។ ម៉ាស៊ីនថតស្ថិតនៅកន្លែង ដែលកុមារសាក្សីមិនអាចមើលឃើញជនត្រូវចោទបាន ប៉ុន្តែចៅក្រម ព្រះរាជអាជ្ញា និងមេធាវីចុងចោទអាចមើលឃើញកុមារបាន។[៥៩]

៥៩ សូមមើលផងដែរនូវវេបីណានៃ ASEAN ACT ស្តីពី របៀបផ្សេងជំនួសឱ្យការផ្តល់សក្ខីកម្មជនរងគ្រោះ នៅ https://aseanactpartnershiphub.com/event/evidence-presentation

**ការបង្កើតបន្ទប់សវនាការ "បែបកុមារមេត្រី" -** ប្រទេសវៀតណាម ប្រធានផ្នែកយុត្តិធម៌នៃតុលាការប្រជាជនកំពូលបានចេញសារាចរណ៍លេខ ០១ និង ០២/២០១៧/TT-TANDTC ដែលតម្រូវឱ្យបន្ទប់សវនាការ ដែលត្រូវបានប្រើប្រាស់ ពាក់ព័ន្ធនឹងកុមារមានលក្ខណៈ [កុមារមេត្រី] ដោយធានានូវឧត្តមប្រយោជន៍របស់ [កុមារ] និងតម្រូវឱ្យចៅក្រមស្លៀកពាក់ឯកសណ្ឋានរដ្ឋបាលរបស់តុលាការប្រជាជនជាជាងអាវផាយចៅក្រម។ សារាចរណ៍នេះចែងបន្ថែមទៀតថា សំណុំរឿងរបស់កុមារដែលពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទ អំពើហិង្សា ឬអំពើជួញដូរ តុលាការត្រូវតែធ្វើការជំនុំជម្រះបែបបិទទ្វារ។



**គោលការណ៍ណែនាំជាក់លាក់ ការបណ្តុះបណ្តាល និងច្បាប់គំរូ សម្រាប់សំណុំរឿងពាក់ព័ន្ធនឹងកុមារ -** ក្នុងភាពជាដៃគូជាមួយយូនីសេហ្វ UNODC បានរៀបចំគោលការណ៍ណែនាំ ការបណ្តុះបណ្តាល[៦០] និងច្បាប់គំរូ ដើម្បីជួយនគរបាល ព្រះរាជអាជ្ញា និងចៅក្រមក្នុងការបើកសវនាការសំណុំរឿង ដែលពាក់ព័ន្ធនឹងកុមារ។













**គោលការណ៍ណែនាំស្តីពី វិស័យយុត្តិធម៌បែបកុមារមេត្រី -** ក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តគោលការណ៍ណែនាំស្តីពី វិស័យយុត្តិធម៌បែបកុមារមេត្រីយ៉ាងជាក់លាក់ ដើម្បីធានាថា៖ ១) កុមារអាចចូលរួមនៅក្នុងដំណើរការតុលាការបាន ២) ឧត្តមប្រយោជន៍របស់កុមារ គឺជាពិចារណាចម្បងនៅក្នុងគ្រប់បញ្ហា ដែលមានឥទ្ធិពលលើពួកគេ (៣) កុមារទទួលបាន ការយកចិត្តទុកដាក់ ភាពឆាប់យល់ដឹងអំពីតម្រូវការ សមភាព និងការគោរព (៤) ពួកគេទទួលបានកិច្ចការពារពីការរើសអើង និង (៥) គោលការណ៍នីតិរដ្ឋត្រូវបានអនុវត្តដោយស្មើភាពគ្នាចំពោះកុមារដូចគ្នានឹងមនុស្សពេញវ័យ។[៦១]

៦០ https://www.unodc.org/documents/justice-and-prison-reform/Training_Programme_on_the_Treatment_of_Child_Victims_and_Child_Witnesses_of_Crime_-_Prosecutors_anf_Judges.pdf

៦១ សូមមើល https://rm.coe.int/CoERMPublicCommonSearchServices/DisplayDCTMContent?documentId=09000016804b2cf3

សូចនាករ

# ៨

បញ្ញត្តិពិសេសសម្រាប់ជនពិការ

## សូចនាករ ៨៖ បញ្ញត្តិពិសេសសម្រាប់ជនមានពិការភាព

### ទស្សនៈរួម

ជនរងគ្រោះដោយអំពើជួញដូរអាចមានពិការភាពពីការរំលោភបំពាននៅពេលដែលពួកគេស្ថិតនៅក្នុងដៃរបស់ជនជួញដូរមនុស្ស ហើយជនមានពិការភាពអាចជាមុខសញ្ញាជាក់លាក់របស់ជនជួញដូរមនុស្ស ដោយសារពួកគេងាយរងគ្រោះ។ ជនមានពិការភាពរមែងតែងប្រឈមមុខនឹងឧបសគ្គផ្លូវកាយ ឧបសគ្គក្នុងការទំនាក់ទំនង និងឧបសគ្គផ្នែកឥរិយាបថនានា នៅពេលដែលពួកគេប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ឧទាហរណ៍ ភាពពិការរបស់ជនម្នាក់អាចនាំឱ្យអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌមើលរំលងពួកគេក្នុងនាមជាសាក្សីដែលអាចជឿជាក់បាន ជនដែលមានបញ្ហាពាក់ព័ន្ធចលនាអាចប្រឈមមុខនឹងឧបសគ្គផ្លូវកាយនៅក្នុងការទៅកាន់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ ហើយសេវាគាំទ្រលក្ខណៈផ្តោតគោលដៅមិនតែងតែមានសម្រាប់ជនរងគ្រោះដែលមានពិការភាពឡើយ។ ហេតុនេះ វាជាការចាំបាច់ ដែលត្រូវកំណត់អត្តសញ្ញាណជនមានពិការភាពតាំងពីដំបូង និងមានការផ្តល់ការគាំទ្រនានា ដើម្បីធានាថា ពួកគេអាចចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងត្រូវបានរួមបញ្ចូលនៅក្នុងសេចក្តីសម្រេចចិត្ត និងបញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងពួកគេ។

DISABILITY IS NOT A BARRIER

DISCRIMINATION IS

បន្ថែមលើនេះ ពិការភាពមិនតែងតែត្រូវបានអ្នកដទៃមើលឃើញឡើយ ហេតុនេះតុលាការចាំបាច់ត្រូវចាត់វិធានការយ៉ាងសកម្មក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ/សាក្សី និងចុងចោទដែលមានពិការភាព ដើម្បីអាចធ្វើការសម្របសម្រួលយ៉ាងសមស្របក្នុងការធានាថា ពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងទទួលបានសិទ្ធិរបស់ពួកគេ។



## គោលការណ៍

### *តើគប្បីអនុវត្តអ្វីខ្លះ?*

ចៅក្រម និងមន្ត្រីរដ្ឋបាលតុលាការគប្បីធានាថា សេវានានា *ដែលត្រូវបានផ្តល់ដល់ជនរងគ្រោះមានពិការភាព មានលក្ខណៈបត់បែន និងត្រូវបានរៀបចំស្របទៅតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ តាមរយៈការធានាថា៖*

**៨.១.** មានការរៀបចំសមស្រប ដើម្បីធានាថា ជនមានពិការភាពអាចទៅកាន់តុលាការ និងចូលរួមនៅក្នុងដំណើរការនេះប្រកបដោយប្រសិទ្ធភាព តាមរយៈ៖

ក) ការធានាថា តុលាការ និងបន្ទប់សវនាការមានការបង្កលក្ខណៈងាយស្រួលសម្រាប់ជនរងគ្រោះដែលមានពិការភាព (ឧទា. សម្រាប់ជនរងគ្រោះប្រើប្រាស់រទេះរុញ គប្បីពិចារណារៀបចំការជំនុំជម្រះនៅជាន់ផ្ទាល់ដី ពីចម្ងាយ ឬប្រើប្រាស់ភ័ស្តុតាងជាវីដេអូ ធានាថា មានទីធ្លា គ្រប់គ្រាន់សម្រាប់ជនរងគ្រោះក្នុងការធ្វើដំណើរចូល និងផ្លាស់ទីជុំវិញបន្ទប់សវនាការ។ តើរទេះរុញរបស់ពួកគេអាចចូលទៅកាន់វេទិកាសាក្សីបានដែរឬទេ?) (អនុសញ្ញា ACTIP មាត្រា ១៤.១២)

ខ) ការលុបបំបាត់ឧបសគ្គទាំងអស់នៅក្នុងតុលាការ/បន្ទប់សវនាការ ដែលអាចបង្កការរារាំងចំពោះសាក្សីដែលពិការភ្នែក ឬមានបញ្ហាពាក់ព័ន្ធនឹងចលនា (អនុសញ្ញា ACTIP មាត្រា ១៤.១២)

គ) ការបំពាក់ស្លាកសញ្ញានៅក្នុងតុលាការ ដែលប្រើប្រាស់និមិត្តសញ្ញាសកលពាក់ព័ន្ធនឹងការបង្កលក្ខណៈងាយស្រួល ដើម្បីណែនាំ លើកកម្ពស់ និងផ្សព្វផ្សាយអំពីទ្រង់ទ្រាយនៃការបង្កលក្ខណៈងាយស្រួលនៃទីកន្លែង កម្មវិធី និងសេវានានានៅតុលាការ សម្រាប់ជនមានពិការភាព (អនុសញ្ញា ACTIP មាត្រា ១៤.១០(ខ) និង ១៤.១២)

ឃ) ការផ្តល់ព័ត៌មានអំពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់សំណុំរឿងជួញដូរមនុស្សនៅក្នុងទម្រង់ដែលបង្កលក្ខណៈងាយស្រួលប្រភេទខុសៗគ្នា ដូចជា អក្សរស្ទាប មាតិកាវីដេអូសម្លេងបែបពណ៌នាជាមួយចំណងជើង និងចំណងជើងរង សម្ភារបោះពុម្ព ដែលប្រកាន់យ៉ាងខ្ជាប់ខ្ជួនទៅតាមគោលការណ៍ណែនាំពាក់ព័ន្ធនឹងការបង្កលក្ខណៈងាយស្រួល (អនុសញ្ញា ACTIP មាត្រា ១៤.១០(ខ) និង ១៤.១២)

ង) ការធានាថា មានអ្នកបកប្រែភាសាសញ្ញា ដែលទទួលបានការបណ្តុះបណ្តាលយ៉ាងសមស្រប[៦២] ដើម្បីជួយជនមានពិការភាពក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងការជំនុំជម្រះ (អនុសញ្ញា ACTIP មាត្រា ១៤.១០(ខ) និង ១៤.១២)

ច) ការប្រើប្រាស់អន្តរការីសម្រាប់ជនមានពិការភាពផ្នែកការចេះដឹង ដើម្បីសាកសួរជនរងគ្រោះនៅក្នុងតុលាការ និងជួយនគរបាល និងព្រះរាជអាជ្ញានៅពេលសម្ភាសន៍[៦៣] (អនុសញ្ញា ACTIP មាត្រា ១៤.១០(ខ) និង ១៤.១២)

**៨.២.** តុលាការប្រមូលទិន្នន័យដែលត្រូវបានបំបែកទៅតាមពិការភាព តាមរយៈការប្រើប្រាស់សំណួរខ្លីៗរបស់ Washington Group (អនុសញ្ញា ACTIP មាត្រា ១៤.១០ និង ១៤.១២)

**៨.៣.** តុលាការបានបង្កើតភាពជាដៃគូជាមួយអង្គការផ្តល់សេវាពិការភាព (DPO) ដើម្បីស្វែងយល់កាន់តែច្បាស់អំពី តម្រូវការរបស់ជនរងគ្រោះ/សាក្សី/ចុងចោទ ដែលមានពិការភាព (អនុសញ្ញា ACTIP មាត្រា ១៤.១០)

**៨.៤.** តុលាការបានអនុវត្តការកសាងសមត្ថភាពសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកតុលាការ ដើម្បីដោះស្រាយតម្រូវការជាក់លាក់របស់ជនមានពិការភាព (អនុសញ្ញា ACTIP មាត្រា ១៤.១២ និង ១៦.១២)

---

៦២ អ្នកបកប្រែគប្បីជាអ្នកណាម្នាក់ ដែលទទួលបានការផ្តល់គុណវុឌ្ឍិជាក់លាក់ និងគ្មានភាពលម្អៀង ហើយតុលាការ និងជនរងគ្រោះអាចទទួលយកបាន។ សូមមើល "សៀវភៅតុលាការស្តីពី ការប្រព្រឹត្តចំពោះដោយស្មើភាពគ្នា" រៀបចំដោយតុលាការចក្រភពអង់គ្លេស ដែលផ្តល់ដំបូន្មានដល់ចៅក្រមអំពី របៀបទំនាក់ទំនងតាមរយៈអ្នកបកប្រែ។ https://www.judiciary.uk/wp-content/uploads/2021/12/Equal-Treatment-Bench-Book-December-2021-interim-update.pdf

៦៣ ចំណុចនេះមានភាពពាក់ព័ន្ធជាពិសេស ប្រសិនបើជនត្រូវចោទគ្មានអ្នកតំណាងផ្លូវច្បាប់។ គ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់គប្បីត្រូវបានធ្វើ ដើម្បីទប់ស្កាត់ចុងចោទពីការសាកសួរសំណួរដោយផ្ទាល់ដល់ជនរងគ្រោះ ប្រសិនបើចុងចោទកំពុងធ្វើជាអ្នកការពារខ្លួនឯងផ្ទាល់។

## ឧទាហរណ៍៖










Supporting People with Intellectual Disability through the Justice System

**និមិត្តសញ្ញាជាសកលនៃការបង្កលក្ខណៈងាយស្រួល**-ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅជុំវិញពិភពលោកនៅក្នុងតុលាការ អាកាសយានដ្ឋាន មន្ទីរពេទ្យ និងស្ថាប័នរដ្ឋាភិបាល ព្រមទាំងនៅលើបណ្ដាញទំនាក់ទំនងសង្គម ដូចជា Twitter និង Facebook គេហ៍ទំព័របង្ហោះវីដេអូ។[៦៤]

**វីដេអូអនឡាញអំពីការបង្កលក្ខណៈងាយស្រួល៖** - នាយកដ្ឋានយុត្តិធម៌ នៅរដ្ឋ New South Wales ប្រទេសអូស្ត្រាលី បានផលិតវីដេអូសម្រាប់ជនមានពិការភាពផ្នែកការយល់ដឹង ដែលត្រូវទៅតុលាការ។ វីដេអូនេះប្រើប្រាស់តួអង្គនានា ដែលមានពិការភាពផ្នែកការចេះដឹង និងជនមានពិការភ្នែក និងពន្យល់ដំណើរការនៃការទៅតុលាការ និងអ្វីដែលចាំបាច់។

**ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្ដល់សេវាឯកទេសនៅក្នុងសហគមន៍** - ការភ្ជាប់ទំនាក់ទំនងរបស់សាក្សីជាមួយសេវាគាំទ្រ ដូចជា អ្នក គាំទ្រផ្នែកពិការភាព អ្នកប្រឹក្សាយោបល់ ជាដើម ដែលមានជំនាញក្នុងការធ្វើការងារជាមួយក្រុមងាយរងគ្រោះនេះ។ តាមរយៈការប្រើប្រាស់អ្នក គាំទ្រ ឬការភ្ជាប់ទំនាក់ទំនងរបស់បុគ្គលនេះជាមួយអង្គការមិនមែនរដ្ឋាភិបាល សាក្សីនឹងមានការគាំទ្រ ដែលពួកគេត្រូវការដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការនេះ។ សេវានេះអាចជួយពួកគេក្នុងការយល់អំពីជម្រើសនានា ដែលមានសម្រាប់ពួកគេ ទទួលបានដំបូន្មានផ្លូវច្បាប់ និងពន្យល់ ព្រមទាំងគាំទ្រពួកគេឆ្លងកាត់ដំណើរការយុត្តិធម៌។

**សម្ភារជាលាយលក្ខណ៍អក្សរដែលមានការបង្កលក្ខណៈងាយស្រួល** - នាយកដ្ឋានយុត្តិធម៌នៅរដ្ឋ NSW ប្រទេសអូស្ត្រាលី បានបង្កើតកូនសៀវភៅ សម្រាប់ជនរងគ្រោះ និងសាក្សីដែលមានពិការភាព។ កូនសៀវភៅនេះផ្ដល់ការណែនាំដល់ជនមានពិការភាពអំពី កម្រងនៃសេវា ដែលតុលាការផ្ដល់ និងដំណើរការនៃស្វែងរក

៦៤ https://www.youtube.com/watch?v=0WaTnsw3UWQ

ជំនួយពីតុលាការ។ កូនសៀវភៅនេះក៏ស្នើឱ្យមានការសុំការយល់ព្រមរបស់សាក្សីផងដែរ ដើម្បីឱ្យតុលាការអាចភ្ជាប់ទំនាក់ទំនងសាក្សីជាមួយនឹងអ្នកផ្តល់សេវាខាងក្រៅដែលអាចជួយពួកគេបាន។ កូនសៀវភៅនេះមាន និងអាចរកបាននៅអង្គការមិនមែនរដ្ឋាភិបាល និងអង្គការគាំទ្រពិការភាព និងនៅលើគេហ៍ទំព័ររបស់តុលាការ។[៦៥]




**បណ្តាញទំនាក់ទំនងសង្គម និងជនមានពិការភាព** - តុលាការត្រូវធានាថា សម្ភារទាំងអស់មានភាពបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព រួមទាំងការបង្ហោះនៅលើបណ្តាញទំនាក់ទំនងសង្គម។ Twitter ផ្តល់សេចក្តីណែនាំអំពី របៀបធ្វើឱ្យរូបភាពនានាមាន លក្ខណៈងាយស្រួលចំពោះជនពិការភ្នែក ឬជនមានបញ្ហាកំសោយចក្ខុវិញ្ញាណ។[៦៦]

**Washington Group ស្តីពី សំណួរស្ថិតិពិការភាព**[៦៧] - នឹងជួយតុលាការក្នុងការយល់អំពីសមត្ថភាពរបស់ជនរងគ្រោះ/សាក្សី និងចុងចោទជាមនុស្សពេញវ័យ (ដែនកំណត់ក្នុងការបំពេញមុខងារ) និងឧបសគ្គផ្នែកបរិស្ថានណាមួយ (ផ្លូវកាយ សង្គម វប្បធម៌ ឬផ្លូវច្បាប់) ដែលអាចធ្វើឱ្យការចូលរួមរបស់ពួកគេមានកម្រិត។ មានសំណួរជាក់លាក់ សម្រាប់កុមារអាយុ ៥ឆ្នាំ និងក្រោមនេះ និងសម្រាប់កុមារ និងយុវជនអាយុពី ៥ ដល់ ១៧ឆ្នាំ។[៦៨]

### កម្រងសំណួរខ្លីមួយនៃ WG ពាក់ព័ន្ធនឹងការបំពេញមុខងារ

បុព្វកថាចំពោះ WG-SS៖
អ្នកសម្ភាសន៍អាន៖ "សំណួរបន្ទាប់សួរអំពី ការលំបាកនានា ដែលអ្នកមាន ក្នុងការធ្វើសកម្មភាពជាក់លាក់ ដោយសារបញ្ហាសុខភាព។"

ការមើល
VIS_SS [តើ][អ្នក/គាត់] មានការលំបាកក្នុងការមើល សូម្បីតែនៅពេលពាក់វ៉ែនតា ដែរឬទេ? តើអ្នកនឹងនិយាយថា... [សូមអានប្រភេទចម្លើយ]
១. មិនលំបាកទេ
២. លំបាកខ្លះៗ
៣. លំបាកខ្លាំង
៤. មិនអាចធ្វើបានទាល់តែសោះ
៧. រងការបដិសេធ
៩. មិនដឹង

ការស្តាប់
HEAR_SS [តើ][អ្នក/គាត់] មានការលំបាកក្នុងការស្តាប់ សូម្បីតែនៅពេលប្រើប្រាស់ឧបករណ៍ជំនួយដល់ការស្តាប់ ដែរឬទេ? តើអ្នកនឹងនិយាយថា... [សូមអានប្រភេទចម្លើយ]
១. មិនលំបាកទេ
២. លំបាកខ្លះៗ
៣. លំបាកខ្លាំង
៤. មិនអាចធ្វើបានទាល់តែសោះ
៧. រងការបដិសេធ
៩. មិនដឹង

ការធ្វើចលនា
MOB_SS [តើ][អ្នក/គាត់] មានការលំបាកក្នុងការដើរ ឬបោះជំហានឡើងដែរឬទេ? តើអ្នកនឹងនិយាយថា... [សូមអានប្រភេទចម្លើយ]
១. មិនលំបាកទេ
២. លំបាកខ្លះៗ
៣. លំបាកខ្លាំង
៤. មិនអាចធ្វើបានទាល់តែសោះ
៧. រងការបដិសេធ
៩. មិនដឹង

---

៦៥ https://www.justice.nsw.gov.au/diversityservices/Documents/Request4CourtTransFinalAccess.pdf

៦៦ https://help.twitter.com/en/using-twitter/picture-descriptions

៦៧ សំណួររបស់មានជាច្រើនភាសា សូមមើល៖ https://www.washingtongroup-disability.com/resources/translations-of-wg-question-sets/

៦៨ សម្រាប់កុមារអាយុ ៥-១៧ឆ្នាំ សូមមើល៖ https://www.washingtongroup-disability.com/fileadmin/uploads/wg/Documents/Washington_Group_Questionnaire__5_-_WG-UNICEF_Child_Functioning_Module__ages_5-17_.pdf និងជាភាសាដទៃទៀត សូមមើល៖ https://data.unicef.org/resources/module-child-functioning/

**ការកសាងសមត្ថភាព សម្រាប់បុគ្គលិកតុលាការ** - ជំហានដំបូង ដើម្បីធ្វើឱ្យតុលាការកាន់តែមានលក្ខណៈបរិយាប័ន្នពិការភាព គឺត្រូវធានាថា បុគ្គលិកតុលាការអាចកំណត់អត្តសញ្ញាណជនមានពិការភាព និងដឹងអំពីរបៀបស្វែងរកជំនួយ ដែលពួកគេត្រូវការ។ នៅក្នុងតារាងខាងក្រោម ដែលរៀបចំដោយគំនិតផ្តួចផ្តើមពង្រឹងតុលាការនៅប្រទេសណូវែលសេឡង់ប៉ាស៊ីហ្វិក (PJSI) គឺកត្តាមួយចំនួនក្នុងចំណោមកត្តានានា ដែលបុគ្គលិកតុលាការគប្បីពិចារណា នៅពេលធ្វើឱ្យតុលាការកាន់តែមានលក្ខណៈបរិយាប័ន្នពិការភាព។



### ៨.៣.៦ ផ្លូវកាយ និងញាណ

ឧបសគ្គផ្លូវកាយអាចរាំងជនមានពិការផ្លូវកាយពីការទៅកាន់តុលាការ ឬធ្វើដំណើរទៅកាន់ ឬនៅក្នុងបន្ទប់សវនាការដោយខ្លួនឯង។ ឧបសគ្គផ្នែកញាណអាចរាំងជនមានពិការភ្នែក ឬថ្លង់ពីការអាចយល់ តាម និងចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការនេះ។

### ៨.៤ ការបង្កើតតុលាការបែបបរិយាប័ន្នពិការភាព

ជំហានដំបូង ដើម្បីធ្វើឱ្យតុលាការកាន់តែមានលក្ខណៈបរិយាប័ន្នពិការភាព គឺត្រូវធានាថា បុគ្គលិកតុលាការអាចកំណត់អត្តសញ្ញាណជនមានពិការភាព និងដឹងអំពីរបៀបស្វែងរកជំនួយ ដែលពួកគេត្រូវការបាន។ នៅក្នុងតារាងខាងក្រោម គឺកត្តាមួយចំនួនក្នុងចំណោមកត្តានានា ដែលបុគ្គលិកតុលាការគប្បីពិចារណា នៅពេលអ្នករៀបចំផែនការរបស់អ្នក ដើម្បីធ្វើឱ្យតុលាការរបស់អ្នកកាន់តែមានលក្ខណៈបរិយាប័ន្នពិការភាព។

| ៨.៤.១ សមត្ថភាពរបស់ជនមានពិការភាពក្នុងការចូល និងផ្លាស់ទីនៅក្នុងតុលាការ និងតាមដានអំពីដំណើរការនេះ | |
|---|---|
| **ប្រភេទពិការភាព** | **កត្តានានា សម្រាប់ការពិចារណា** |
| **ភាពទន់ខ្សោយពាក់ព័ន្ធនឹងការធ្វើចលនា** | • តើបន្ទប់សវនាការស្ថិតនៅជាន់ផ្ទាល់ដី ឬអាចទៅដល់តាម រយៈជណ្តើរយន្ត (យោង) ដែរឬទេ?<br>• ប្រសិនបើបន្ទប់សវនាការស្ថិតនៅជានផ្ទាល់ដី - តើនៅតែមានកាំជណ្តើរ ដើម្បីចូលទៅកាន់បន្ទប់សវនាការ ឬមានជម្រាល ដែរឬទេ?<br>• តើទ្វារតុលាការមានទំហំធំគ្រប់គ្រាន់ ដើម្បីឱ្យរទេះរុញចូលបានដែរឬទេ?<br>• តើមានទីធ្លាសម្រាប់អ្នកប្រើប្រាស់រទេះរុញ ដើម្បីផ្លាស់ទីនៅជុំវិញបន្ទប់សវនាការដែរឬទេ?<br>• តើបុគ្គលអង្គុយនៅលើរទេះរុញ អង្គុយនៅកន្លែងណានៅក្នុងបន្ទប់សវនាការ នៅពេលដែលពួកគេកំពុងផ្តល់ភ័ស្តុតាង?<br>• តើផ្លូវដើរនៅក្នុងតុលាការធំ និងគ្មានសម្ភារ ឬរបស់របរនៅតាមផ្លូវទាំងនោះដែរឬទេ?<br>• តើមានបង្គន់ ដែលអ្នកប្រើប្រាស់រទេះរុញ អាចប្រើប្រាស់បានដែរឬទេ? |
| **ភាពទន់ខ្សោយពាក់ព័ន្ធនឹងភ្នែក** | • តើបុគ្គលិកតុលាការទាំងអស់ដឹងថា សុនខនាំផ្លូវអាចចូលក្នុងបន្ទប់សវនាការដែរឬទេ?<br>• តើបុគ្គលិកតុលាការនឹងជួយជាមួយការនាំផ្លូវ និង/ឬដើរជាមួយអតិថិជនទៅកាន់បន្ទប់សវនាការដែរឬទេ?<br>• តើជណ្តើរយន្តមានអក្សរស្ទាបនៅលើប៊ូតុង ឬប្រព័ន្ធសម្លេង ដើម្បីប្រកាសអំពីជាន់នីមួយៗដែរឬទេ?<br>• សម្រាប់ឯកសារអាន តើឯកសារនេះត្រូវបានបញ្ជូនតាមអ៊ីម៉េលទៅកាន់អតិថិជន ក្នុងលក្ខណៈជាឯកសារមួយ ដែលអ្នកមានភាពទន់ខ្សោយពាក់ព័ន្ធនឹងភ្នែក ឬពិការភ្នែកអាចអានបាន ដោយប្រើប្រាស់កម្មវិធីសូហ្វវែរសមស្របដែរឬទេ? |
| **ពិការភាពគ្រប់ប្រភេទ** | • តើនៅតុលាការមានស្លាកសញ្ញាបង្ហាញច្បាស់ៗដែរឬទេ?<br>• តើមានបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាល ដើម្បីជួយអ្នកប្រើប្រាស់ស្វែងរកផ្លូវរបស់ពួកគេនៅជុំវិញតុលាការដែរឬទេ? |
| ៨.៤.២ សមត្ថភាពរបស់ជនមានពិការក្នុងការត្រៀមលក្ខណៈ និងចូលរួមនៅក្នុងដំណើរការនេះ | |
| **ពិការភាពគ្រប់ប្រភេទ** | • តើមានព័ត៌មានបែបបរិយាប័ន្នពិការភាពដែរឬទេ៖ តាមរយៈទូរស័ព្ទ? អ៊ីម៉េល? ជួបដោយផ្ទាល់នៅពេលបុគ្គលនេះនៅការិយាល័យក្រឡាបញ្ជី? តាមរយៈគេហ៍ទំព័ររបស់តុលាការ? - តើវាមានព័ត៌មានអំពីច្បាប់ ដំណើរការ និងជំនួយដែលមានដែរឬទេ? (ពីតុលាការ ជំនួយផ្នែកច្បាប់ និងសេវាឯកទេសដទៃទៀត?) |
| **ភាពទន់ខ្សោយពាក់ព័ន្ធនឹងការស្តាប់** | • តើមានអ្នកបកប្រែភាសាសញ្ញា ឬមាន "ប្រព័ន្ធសម្លេងពិសេស" នៅក្នុងតុលាការដែរឬទេ?<br>• តើមានអ្នកណាម្នាក់ ដើម្បីឆ្លើយនឹងសំណួរនានាអំពី អ្វីដែលនឹងកើតឡើងនៅថ្ងៃនោះ តាមរយៈទូរស័ព្ទ អ៊ីម៉េល Skype ឬសេវាផ្ញើសារមួយចំនួនដទៃទៀតដែរឬទេ? |

NEW ZEALAND
FOREIGN AFFAIRS & TRADE
Aid Programme

PJSI is funded by the New Zealand Government and implemented by the Federal Court of Australia

# ឧបសម្ព័ន្ធ ១៖
# ឧបករណ៍ស្វ័យវាយតម្លៃអំពី សូចនាករនៃតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ



## ឧបករណ៍ស្វ័យវាយតម្លៃសូចនាករនៃតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ

- 'បៃតង' – ប្រទេសដែលបានបំពេញ និងអនុវត្តទៅតាមលក្ខណៈវិនិច្ឆ័យនៃសូចនាករ ទាំងអស់នេះ។
- 'ទឹកក្រូច' – ប្រទេសកំពុងធ្វើអន្តរកាល និងបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនៃសូចនាករមួយចំនួនប៉ុណ្ណោះ។ វិស័យមួយចំនួនមិនទាន់សម្រេចបានឬអនុវត្តបានពេញលេញនៅឡើយ។
- 'ក្រហម' – ប្រទេសដែលមិនទាន់បំពេញទៅតាមលក្ខណៈវិនិច្ឆ័យនៃសូចនាករទាំងនេះ និងមានភាពខ្សោយនៅក្នុងវិស័យនេះ។
- 'ខៀវ' – ស្ថានភាពមិនច្បាស់ ឬមិនដឹង។

### -- សូមជ្រើសរើសប្រទេសនៅទីនេះ --

### សូចនាករ ១

### សុវត្ថិភាព និង ឯកជនភាព

**ការធានាសុវត្ថិភាព និងឯកជនភាពរបស់ជនត្រូវបានជួញដូរ**

១.១ មានបទប្បញ្ញត្តិចំពោះការផ្តល់សក្ខីកម្មជាសម្ងាត់ពីជនរងគ្រោះទៅតុលាការ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

១.២ មានការវាយតម្លៃហានិភ័យ/ផែនការសុវត្ថិភាព ដែលលម្អិតអំពី ជំហាននានា ដើម្បីការពារជនរងគ្រោះ/សាក្សីក្នុងអំឡុងពេលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

១.៣ រៀបចំសេចក្តីសម្រេច/សាលក្រមនៅក្នុងសំណុំរឿងជួញដូរមនុស្សជាលក្ខណៈអនាមិក និងផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

១.៤ មាននីតិវិធីតុលាការ ដើម្បីហាមឃាត់ការផ្សព្វផ្សាយព័ត៌មានលម្អិតអំពីអត្តសញ្ញាណរបស់ជនរងគ្រោះ/សាក្សីនៅតាមប្រព័ន្ធផ្សព្វផ្សាយ ឬនៅលើបណ្តាញទំនាក់ទំនងសង្គម

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

### សូចនាករ ២

### ភស្តុតាង និង ដំណើរការ

២.១ ការចាត់អាទិភាព និងអនុវត្តយ៉ាងរហ័សលើសំណុំរឿងជួញដូរមនុស្ស

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

២.២ មានវិធានការនានា ដើម្បីធានាថា ជនរងគ្រោះទទួលបានឱកាស និងការគាំទ្រនៅក្នុងដំណើរការព្រហ្មទណ្ឌ តាមរយៈ៖

ក) ការប្រើប្រាស់សាក្សីជំនាញ (ដូចជាអន្តរការី) ដើម្បីផ្តល់ភស្តុតាង នៅពេលចាំបាច់

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ស្តង់ដារ ២ ត

# ភស្តុតាង និង ដំណើរការ

## ភស្តុតាងល្អបំផុត - វិធីដែលជនត្រូវបានជួញដូរកត់ត្រា និងបង្ហាញភស្តុតាងនៅក្នុងដំណើរការនេះ

ខ) ការអនុញ្ញាតឱ្យជនរងគ្រោះមានបុគ្គលគាំទ្រ ដែលជាជម្រើសរបស់ពួកគេ នៅជាមួយពួកគេ នៅពេលដែលពួកគេផ្តល់សក្ខីកម្មនៅ តុលាការ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

គ) ការធានាថា មានអ្នកបកប្រែភាសាប្រកបដោយគុណវុឌ្ឍិ សម្រាប់ជនរងគ្រោះ/សាក្សី ដើម្បីឱ្យពួកគេអាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការនេះ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

២.៣ មានវិធានការការពារ ដើម្បីធានាថា ជនរងគ្រោះ/សាក្សីអាចផ្តល់ភស្តុតាង ដោយមិនមើលឃើញជនត្រូវចោទ តាមរយៈការប្រើប្រាស់៖

ក) ផ្ទាំងស្ក្រីនសម្រាប់សាក្សី ដើម្បីបង្ហាញអំពីជនត្រូវចោទ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ខ) ការប្រើប្រាស់បច្ចេកវិទ្យាវីដេអូខុនហ្វឺរិន ដើម្បីឱ្យសាក្សីអាចផ្តល់ភស្តុតាងពីចម្ងាយពីកន្លែងមួយទៀត ឬបន្ទប់ផ្សេងមួយទៀត

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

គ) ភស្តុតាងជាវីដេអូដែលបានថតទុកជាមុន ត្រូវបានបញ្ចាំងនៅក្នុងតុលាការ ដែលជនរងគ្រោះរៀបរាប់ពីភស្តុតាង

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ឃ) មានច្រកចូល និងបន្ទប់រង់ចាំដោយឡែក សម្រាប់ជនរងគ្រោះ/សាក្សីនៃអំពើជួញដូរមនុស្សក្នុងអំឡុងពេលនៃការជំនុំជម្រះទាំងមូល និងជាពិសេស នៅមុន និងក្រោយពេលផ្តល់ភស្តុតាង

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

២.៤ ការប្រើប្រាស់ "របាយការណ៍អំពីផលប៉ះពាល់លើជនរងគ្រោះ" ដើម្បីធានាថា ចៅក្រមមានការវាយតម្លៃគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់លើជនរងគ្រោះ ដែលបង្កឡើងដោយជនល្មើស (ដើម្បីទទួលបានសំណងចំពោះការខូចខាត)

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ស្តង់ដារ ៣

## បុគ្គលិកវិស័យ យុត្តិធម៌

**ទំនាក់ទំនង - តើបុគ្គលិក នៃទីភ្នាក់ងារវិស័យយុត្តិធម៌ផ្លូវការ និងចៅក្រមទំនាក់ទំនងជាមួយជនរងគ្រោះ/សាក្សីដោយរបៀបណា**

៣.១ មានអង្គភាព/បុគ្គលពិសេស ដើម្បីដោះស្រាយសំណុំរឿងជួញដូរមនុស្សនៅក្នុងតុលាការ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៣.២ តុលាការមានសេចក្តីណែនាំ និងនីតិវិធីប្រតិបត្តិបទដ្ឋាន (SOPs) សម្រាប់មន្ត្រីតុលាការ និងចៅក្រមទាំងអស់ស្តីពីរបៀបដោះស្រាយសំណុំរឿងជួញដូរមនុស្ស។

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៣.៣ តុលាការមានលិខិតបទដ្ឋានគតិយុត្តិ និងក្រមប្រតិបត្តិជាក់លាក់ ដែលកំណត់អំពី បទដ្ឋានដែលត្រូវរំពឹងទុកអំពីអាកប្បកិរិយារបស់ចៅក្រម និងបុគ្គលិកតុលាការ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៣.៤ ការបណ្តុះបណ្តាលអំពី អំពើជួញដូរមនុស្ស ដែលត្រូវបានផ្តល់ គឺផ្អែកលើអភិក្រមដែលយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ស្តង់ដារ ៤

## ព័ត៌មាន និង សេវា

៤.១ តុលាការផ្តល់ព័ត៌មាន និងសម្ភារសមស្របក្នុងទម្រង់ចម្រុះគ្នាដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងលក្ខណៈងាយៗ គ្មានពាក្យពេជន៍ច្បាប់ និងជាភាសាដែលពួកគេអាចយល់បានពាក់ព័ន្ធនឹង៖

ក) តើអំពើជួញដូរមនុស្សជាអ្វី ដំណើរការព្រហ្មទណ្ឌ រួមទាំងតួនាទីផ្លូវច្បាប់របស់ជនរងគ្រោះ សិទ្ធិរបស់ពួកគេ ជម្រើសរបស់ពួកគេ (ដើម្បីចូលរួម ឬមិនចូលរួម) សេវាគាំទ្រដែលមានចំពោះជនរងគ្រោះ និងការប៉ាន់ស្មានអំពីពេលវេលានៃអំពើជួញដូរមនុស្ស

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ខ) គោលការណ៍គ្មានទណ្ឌកម្ម ដើម្បីឱ្យជនរងគ្រោះយល់ថាពួកគេនឹងគ្មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬរដ្ឋបាលចំពោះសកម្មភាពខុសច្បាប់ ដែលពួកគេបានប្រព្រឹត្តប្រសិនបើ សកម្មភាពទាំងនោះមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងអំពើជួញដូរ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

សូចនាករ ៤ ត

## ព័ត៌មាន និង សេវា

**ព័ត៌មាន និងសេវានានា ដែលត្រូវបានផ្តល់ដល់ជនត្រូវបានជួញដូរ នៅពេលពួកគេទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ផ្លូវការ**

គ) សិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សក្នុងការទាមទារបដិទាន/ សំណង (ប្រសិនបើមាន) ព្រមទាំងដំណើរការដាក់ពាក្យសុំ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៤.២ តុលាការបានចាត់តាំងជនបង្គោល/អ្នកគ្រប់គ្រងករណី/អ្នកសម្របសម្រួលសាក្សីជនរងគ្រោះ ដែលនឹងបន្តទំនាក់ទំនងជាមួយជនរងគ្រោះ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពី ស្ថានភាពសំណុំរឿង និងផ្តល់

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

សូចនាករ ៥

## ការស្តារផ្លូវកាយ ផ្លូវចិត្ត និងសង្គម របស់ជនរងគ្រោះ

**សូចនាករនានា ដែលពាក់ព័ន្ធនឹងវិធានការ ដើម្បីផ្តល់សម្រាប់ភាពធូរស្បើយឡើងវិញផ្នែកផ្លូវកាយ ផ្លូវចិត្ត និងសង្គម របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស**

៥.១ គប្បីមាន MOU ឬកិច្ចព្រមព្រៀងរវាងតុលាការ និងអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកទឹកចិត្ត និងសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងកិច្ចសហការសម្រាប់ការផ្តល់សេវា និងគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៥.២ គប្បីមានពិធីសារអន្តរទីភ្នាក់ងារ សម្រាប់សេវា″ច្រកចេញចូលតែមួយ″ ដែលមានលក្ខណៈសម្របសម្រួលគ្នា សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្សពាក់ព័ន្ធនឹងការពិគ្រោះយោបល់ វេជ្ជសាស្ត្រ ផ្ទះសម្បែង ការអប់រំ និងការបណ្តុះបណ្តាល ផ្លូវច្បាប់

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

## សូចនាករ ៦

### សេវាវេជ្ជសាស្ត្រ និងកោសល្យវិច្ច័យ

**សូចនាករ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាវេជ្ជសាស្ត្រ និងកោសល្យវិច្ច័យ សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស**

៦.១ ព្រះរាជអាជ្ញា និងចៅក្រមទទួលបានការបណ្តុះបណ្តាលជាក់លាក់ស្តីពី ភាពខ្លាំង និងភាពខ្សោយនៃភស្តុតាងកោសល្យវិច្ច័យពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងផ្លូវកាយ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៦.២ ពិធីសារជាតិ សម្រាប់ការពិនិត្យកោសល្យវិច្ច័យលើការរំលោភផ្លូវភេទ ត្រូវបានរៀបចំ និងផ្អែកលើគោលការណ៍ណែនាំរបស់ WHO

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៦.៣ ការផ្លាស់ប្តូរព័ត៌មានជាផ្លូវការជារៀងរាល់ឆ្នាំរវាងស្ថាប័នជួញដូរមនុស្សថ្នាក់តំបន់ និងស្ថាប័នកោសល្យវិច្ច័យឯកទេសនៅក្នុងតំបន់អាស៊ាន ដើម្បីរៀបចំជំនាញឯកទេសប្រចាំតំបន់ និងជំរុញកិច្ចសហការ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

## សូចនាករ ៧

### បញ្ញត្តិពិសេសសម្រាប់កុមារ

**សូចនាករពិសេស ដែលពាក់ព័ន្ធយ៉ាងជាក់លាក់ចំពោះកុមារ ក្នុងនាមជាជនរងគ្រោះ ឬសាក្សីនៃអំពើជួញដូរមនុស្ស**

៧.១ តុលាការផ្តល់ការការពារសុវត្ថិភាព ដើម្បីការពារកុមាររងគ្រោះ/កុមារសាក្សី/កុមារចុងចោទ តាមរយៈ

ក) ការធានាថា មានវិធានការ ដើម្បីកាត់បន្ថយការពន្យារពេលនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ខ) ការការពារឯកជនភាពរបស់កុមារ តាមរយៈការហាមឃាត់ការកំណត់អត្តសញ្ញាណរបស់កុមាររងគ្រោះ/កុមារសាក្សី ឬកុមារចុងចោទ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

គ) ការបន្តផ្តល់ព័ត៌មានដល់កុមារអំពី តួនាទីរបស់ពួកគេ និងវិសាលភាព ពេលវេលា និងវឌ្ឍនភាពនៃដំណើរការនេះ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ឃ) ការរៀបចំ និងការអនុវត្តគ្រោងការណ៍ស្តីពីការត្រៀមលក្ខណៈកុមារសាក្សី ដើម្បីធ្វើឱ្យកុមារយល់អំពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ មុនពេលពួកគេផ្តល់ភស្តុតាង

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ស្តង់ដារ ៧ ត

# បញ្ញត្តិពិសេសសម្រាប់កុមារ

## សូចនាករពិសេស ដែលពាក់ព័ន្ធយ៉ាងជាក់លាក់ចំពោះកុមារ ក្នុងនាមជាជនរងគ្រោះ ឬសាក្សីនៃអំពើជួញដូរមនុស្ស

ង) ការផ្តល់ព័ត៌មានបែបយកចិត្តទុកដាក់ចំពោះកុមារ និងសមស្របតាមអាយុដល់កុមារអំពី ដំណើរការជំនុំជម្រះ តួនាទីរបស់ពួកគេនៅក្នុងសំណុំរឿង សេចក្តីរំពឹងទុករបស់តុលាការពីពួកគេ និងស្វែងរកការដោះស្រាយលើកង្វល់ណាមួយ ដែលពួកគេមាន នៅទូទាំងដំណើរការជំនុំជម្រះព្រហ្មទណ្ឌ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ច) ការអនុញ្ញាតឱ្យមានការផ្តល់ខ្សែរអាត់វីដេអូដែលត្រូវបានថតទុកជាមុនអំពី សក្ខីកម្មកុមាររងគ្រោះ/កុមារសាក្សី ដើម្បីបញ្ចាំងនៅក្នុងតុលាការ ក្នុងនាមជាបំណែកមួយនៃភស្តុតាងផ្លូវការ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ឆ) ការអនុញ្ញាតឱ្យមាន (បទដ្ឋានអប្បបរមា) ការផ្តល់របាំងឯកជនភាព ដើម្បីដាក់នៅចន្លោះកុមាររងគ្រោះ /

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ជ) ការអនុញ្ញាតឱ្យកុមាររងគ្រោះ/កុមារសាក្សីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធទូរទស្សន៍ ប្រសិនបើកុមារចាំបាច់ត្រូវចូលរួមនៅក្នុងការជំនុំជម្រះសម្រាប់ការសាកសួរពីភាគីបដិបក្ខ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ឈ) ការរៀបចំឱ្យបន្ទប់សវនាការ និងនីតិវិធីនានា លែងសូវមានលក្ខណៈបំភិតបំភ័យចំពោះកុមារសាក្សី

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ញ) ការបិទបន្ទប់សវនាការពីសាធារណជន នៅពេលដែលសំណុំរឿងពាក់ព័ន្ធនឹងកុមាររងគ្រោះ/ កុមារសាក្សី ឬកុមារចុងចោទ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ដ) ការប្រើប្រាស់អន្តរការី ដើម្បីសាកសួរកុមាររងគ្រោះ (ឧទា. បុគ្គលិកសង្គម អ្នកឯកទេសផ្នែកកុមារ មេធាវី/អ្នកតំណាងជនរងគ្រោះ) នៅក្នុងការជំនុំជម្រះ និងដើម្បីជួយដល់ការសម្ភាសរបស់នគរបាល និងព្រះរាជអាជ្ញា

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ឋ) ការផ្តល់សេចក្តីណែនាំ និងមេធាវីការពារ ដើម្បីធានាថា ការសាកសួរពិចារណាលើអាយុ និងតម្រូវការពិសេសរបស់កុមារ ដើម្បីជៀសវាងហានិភ័យនៃភាពរងគ្រោះឡើងវិញ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

## ស្តង់ដារ ៧ ត

# បញ្ញត្តិពិសេស សម្រាប់កុមារ

ឌ) ធានាថា ឧត្តមប្រយោជន៍របស់កុមារ គឺជាការពិចារណាខ្ពស់បំផុត នៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៧.២ "អាណាព្យាបាល" ម្នាក់ត្រូវបានចាត់តាំងឱ្យអមដំណើរកុមារ នៅទូទាំងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៧.៣ តុលាការបានអនុវត្ត និងធ្វើស្ថាប័និយកម្មការកសាងសមត្ថភាពឯកទេស សម្រាប់បុគ្គលិកតុលាការ និងចៅក្រម ដែលធ្វើការងារជាមួយកុមាររងគ្រោះ និងកុមារសាក្សីនៃអំពើជួញដូរមនុស្ស

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

## ស្តង់ដារ ៨

# បញ្ញត្តិពិសេស សម្រាប់ជនពិការ

**បញ្ញត្តិពិសេស សម្រាប់ជនមានពិការភាព**

៨.១ មានការរៀបចំសមស្រប ដើម្បីធានាថា ជនមានពិការភាពអាចទៅតុលាការ និងចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការនេះបានតាមរយៈ៖

ក) ការធានាថា តុលាការ និងបន្ទប់សវនាការមានការបង្កលក្ខណៈងាយស្រួលចំពោះជនរងគ្រោះដែលមានពិការភាព

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ខ) ការលុបបំបាត់ឧបសគ្គទាំងអស់នៅក្នុងតុលាការ/បន្ទប់សវនាការ ដែលអាច

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

គ) ការបំពាក់ផ្លាកសញ្ញានៅតុលាការ ដែលប្រើប្រាស់សញ្ញាសកលនៃការបង្កលក្ខណៈងាយស្រួល

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ឃ) ការផ្តល់ព័ត៌មានអំពី ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់សំណុំរឿងជួញដូរមនុស្សនៅក្នុងទម្រង់ចម្រុះគ្នា ដែលមានការបង្កលក្ខណៈងាយស្រួល

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ង) ការធានាថា មានអ្នកបកប្រែភាសាសញ្ញា ដែលទទួលបានការបណ្តុះបណ្តាលសមស្រប ដើម្បីជួយជនមានពិការភាពឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការជំនុំជម្រះ
(ACTIP មាត្រា ១៤.១០(ខ) និង ១៤.១២)

ស្តង់ដារ ៨ ត

## បញ្ញត្តិពិសេស សម្រាប់ជនពិការ

### បញ្ញត្តិពិសេស សម្រាប់ជនមានពិការភាព

ប្រសិនបើជនរងគ្រោះថ្លង់ ឬមានភាពអន់ខ្សោយពាក់ព័ន្ធនឹងការស្តាប់ ពួកគេនឹងមិនអាចចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងនៅក្នុងការជំនុំជម្រះបានឡើយ ប្រសិនបើ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

អ្នកបកប្រែគប្បីជាជន ដែលមានគុណវុឌ្ឍិសមស្រប គ្មានភាពលម្អៀង និងអាចទទួលយកបាន

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

ច) ការប្រើប្រាស់អន្តរការី សម្រាប់ជនមានពិការភាពផ្នែកការចេះដឹង ដើម្បីសាកសួរជនរងគ្រោះនៅក្នុងតុលាការ និងជួយ

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៨.២ តុលាការប្រមូលទិន្នន័យដែលត្រូវបានបំបែកទៅតាមពិការភាព តាមរយៈការប្រើប្រាស់សំណួរខ្លីៗរបស់ Washington Group

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៨.៣ តុលាការបានបង្កើតភាពជាដៃគូជាមួយអង្គការផ្តល់សេវាពិការភាព (DPOs) ដើម្បីយល់កាន់តែច្បាស់អំពីតម្រូវការរបស់ជនរងគ្រោះ/សាក្សី/ចុងចោទដែលមានពិការភាព

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ

៨.៤ តុលាការបានអនុវត្តការកសាងសមត្ថភាពសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកតុលាការក្នុងការដោះស្រាយតម្រូវការជាក់លាក់របស់ជនមានពិការភាព

ព័ត៌មានលម្អិត
*ប្រសិនបើអាចធ្វើបាន កំណត់អំពីក្រម/នីតិវិធី/បទប្បញ្ញត្តិនៅទីនេះ








Australian Aid | ASEAN-Australia Counter Trafficking

# តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ

## សៀវភៅណែនាំសម្រាប់រដ្ឋសមាជិកអាស៊ាន